ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា
- ក្រោយរបបខ្មែរក្រហម បួសជាសង្ឃដើម្បីរៀន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦៥ ខែកញ្ញា ឆ្នាំ២០១៣

# ស្វែងរកការពិត

លេខ១៦៥ ខែកញ្ញា ឆ្នាំ២០១៣


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ ....................................១

◆ ពលីកម្មនៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ....................................២

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព គង់ សុផល ....................................៣

◆ បទខទ្ទេសនាមរបស់សមមិត្តតំណាង ....................................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សង្គ្រោះផ្សើកដោយខ្មែរក្រហម ....................................១៥

◆ ចិន និង របបខ្មែរក្រហម ....................................១៧

◆ អក្សរសាស្ត្រអ៊ីស្លាមដែលកប់ ....................................២៨

**ផ្នែកច្បាប់**

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ....................................៣៤

◆ សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញា ....................................៣៨

**វេទិកាពិភាក្សាសាធារណៈ**

◆ អង្គជំនុំជម្រះវិសាមញ្ញសម្រេចទទួលយក....................................៤២

◆ សហព្រះរាជអាជ្ញាស្នើសុំការបញ្ជាក់អំពី ....................................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទណ្ឌិតផ្ដៃល្អោ ....................................៤៨

◆ សាច់រឿងរ៉ាវរបស់ឪពុកម្ដាយខ្ញុំ....................................៥៥

◆ ខ្ញុំចង់រៀនសូត្រពីប្រវត្តិខ្មែរក្រហមឲ្យ ....................................៥៧

◆ អតីតទាហាន លន់ នល់ រួចរស់ជីវិត....................................៥៩

◆ ក្រោយរបបខ្មែរក្រហម បួសជាសង្ឃ....................................៦០


*រូបក្របមុខ៖ ផ្លូនសំអឿ សូមអាននៅទំព័រទី៦០*



*អេនឌ្រូ ខេលី និង ឆាំង យុ នៅរំលេច ខេត្តពោធិ៍សាត់ ឆ្នាំ២០១១*


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ចន ឆរឆីអារី, រីកុ គុរុមីយ៉ាអូកាវ៉ា, រ៉េនឌល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ, លន់ដាលីន, អេនឌ្រូ ខេលី, អាន ហាញឌល, ឆាយ ស៊ូឆាត្រ, ដូ ជុំបូរ៉ា, អៀង ណារី, ហ៊ាន សុជាតា, គីម ឡេង **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ ៖** នង ច័ន្ទមល្លិកា, ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ភាគព្វកិច្ចរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ថវិកាលើដំណើរការស្វែងរកយុត្តិធម៌

បន្ទាប់ពីរង់ចាំការជំនុំជម្រះមេដឹកនាំខ្មែរក្រហមអស់ពេលជាច្រើនឆ្នាំកន្លងមក អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងតែសម្លឹងមើលដោយក្តីនឹកភ្នកថា ក្តីសង្ឃឹមរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌កំពុងតែរសាត់អណ្តែតទៅឆ្ងាយជាបណ្តើរៗហើយ ។ វិបត្តិផ្នែកហិរញ្ញវត្ថុ និងការជាប់គាំងផ្នែកនយោបាយដែលកើតមានជាបន្តបន្ទាប់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បាននាំទៅរកការជំនុំជម្រះក្តីដែលបានចំណាយពេលយ៉ាងយូរ មុននិងសាលាក្តីមួយនេះកើតឡើង ព្រមទាំងចំណាយពេលយ៉ាងយូរដោយមិនដឹងថាសាលាក្តីនេះបញ្ចប់នៅពេលណា ។

វិបត្តិថ្មីៗនេះគឺថា បុគ្គលិកផ្នែកជាតិដែលមិនទទួលបានប្រាក់កម្រៃ កំពុងតែធ្វើការតវ៉ាដោយមិនចូលមកធ្វើការ ។ មន្ត្រីអង្គការសហប្រជាជាតិ បានគូសបញ្ជាក់អំពីកាតព្វកិច្ចរបស់កម្ពុជាក្នុងការផ្តល់ថវិកាដល់បុគ្គលិកផ្នែកជាតិរបស់ខ្លួន ។ មន្ត្រីកម្ពុជាបានឆ្លើយតបវិញថា ខ្លួនត្រូវការជំនួយយ៉ាងចាំបាច់ពីម្ចាស់ជំនួយដើម្បីសម្រេចនូវកាតព្វកិច្ចទាំងនោះ ។ ស្របពេលជាមួយគ្នានេះដែរ កិច្ចការរបស់សាលាក្តីខ្មែរក្រហមបានពន្យារពេលជាថ្មីម្តងទៀត ដែលធ្វើឲ្យខកចិត្តដល់ការរំពឹងទុករបស់ជនរងគ្រោះរាប់លាននាក់ចំពោះដំណើរការនេះ ។

ទន្ទឹមពេលដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មានបំណងបញ្ជាក់អំពីកាតព្វកិច្ចរបស់ខ្លួនរៀងៗខ្លួន ភាគីទាំងពីរនេះត្រូវចងចាំឲ្យបានច្បាស់អំពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ភាគីទាំងពីរត្រូវតែរួមចំណែកជម្នះលើភាពជាប់គាំងនាពេលបច្ចុប្បន្ននេះ និងសំណុំរឿង០០២នាំទៅរកភាពផ្លែផ្កា ។

ប្រសិនបើសាលាក្តីខ្មែរក្រហមទទួលបរាជ័យដោយសារតែបញ្ហាកង្វះថវិកា អ្នកសង្កេតការណ៍កម្ពុជាភាគច្រើននឹងដាក់បន្ទុកការទទួលខុសត្រូវនេះទៅលើភាគីទាំងពីរគឺអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។ ប្រសិនបើសាលាក្តីខ្មែរក្រហមត្រូវបានបញ្ចប់ ប្រជាជនកម្ពុជាភាគច្រើននឹងផ្តល់កិត្តិយសដល់ភាគីទាំងពីរ ។ សញ្ញាណនៃការបន្តការប្តេជ្ញាចិត្តថ្មីរបស់ភាគីទាំងពីរនឹងជួយស្តារទំនុកចិត្តសាធារណជនលើដំណើរការព្យាបាលស្នាមរបួសអតីតកាលដែលនឹងបង្កើតនូវឱកាសដល់ការរួមចំណែកបន្ថែមរបស់ផ្នែកជាតិនិងម្ចាស់ជំនួយ ។ ទាំងមន្ត្រីអង្គការសហប្រជាជាតិនិងថ្នាក់ដឹកនាំកម្ពុជាត្រូវតែប្តេជ្ញាធ្វើការងារនេះដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាដោយមិនត្រូវធ្វើឲ្យបាត់បង់ឱកាសនោះឡើយ ។



សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ឆាំង យុ**

# ពលីកម្មនៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស

អំឡុងពេលនៃការតវ៉ាដោយបាតុកម្មនៅទីក្រុងភ្នំពេញកាលពីពេលថ្មីៗកន្លងទៅនេះ ពលរដ្ឋកម្ពុជាម្នាក់ទៀតបានបាត់បង់ជីវិត ខណៈពេលដែលទាមទារឲ្យមានភាពប្រសើរជាងមុនឆ្ពោះទៅរកការលើកកំពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ។ ជនរងគ្រោះ ម៉ៅ សុខច័ន្ទ គ្រាន់តែជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ដែលបានធ្វើការតវ៉ាដើម្បីបង្ហាញនូវឆន្ទៈអំពីការមិនពេញចិត្តទៅនឹងលទ្ធផលនៃការការបោះឆ្នោតដែលបានប្រកាសកាលពីពេលថ្មីៗនេះ ។ ការស្លាប់របស់ ម៉ៅ សុខច័ន្ទ បានបន្សល់ទុកនូវប្រពន្ធនិងកូនបួននាក់របស់គាត់ដែលនឹងមិនអាចរីកលូតលាស់បានឡើយដោយគ្មានឪពុក ។

វាហាក់ដូចជាមិនសូវឡូតម្លៃចំពោះសោកនាដកម្មនៃការស្លាប់របស់ ម៉ៅ សុខច័ន្ទ ដោយសារតែប្រទេសកម្ពុជាធ្លាប់ជួបរឿងរំលោភសិទ្ធិមនុស្សយ៉ាងជូរចត់ និងអំពើកាប់សម្លាប់យ៉ាងធ្ងន់ធ្ងរជាងនេះ កាលពីជាងពាក់កណ្តាលសតវត្សរ៍កន្លងទៅ ប៉ុន្តែវាជារឿងសំខាន់ណាស់ដែលយើងត្រូវដឹងថា ការធ្វើទុក្ខបុកម្នេញកាលពីអតីតកាលគឺមិនត្រូវយកមកដោះសារសម្រាប់អំពើហិង្សាណាមួយនាពេលបច្ចុប្បន្ន និងអនាគត និងសម្រាប់ការរំលោភគោលការសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរជាមូលដ្ឋានរបស់មនុស្សឡើយ ។ ម៉ៅ សុខច័ន្ទ ព្រមទាំងគ្រួសាររបស់គាត់ និងប្រជាជនកម្ពុជាគ្រប់រូបសមនឹងទទួលបាននូវភាពយុត្តិធម៌ចំពោះអំពើហិង្សាដែលមិនអាចអត់ទោសឲ្យបាន ។ ដោយសារតែប្រជាជនកម្ពុជារាប់ម៉ឺននាក់បានសម្លាប់មនុស្សរាប់លាន់នាក់ផ្សេងទៀតកាលពីរបបខ្មែរក្រហមក្តី ឬដោយសារតែជនដែលបង្កឲ្យមានសង្គ្រាមស៊ីវិលនៅកម្ពុជាអាចគេចផុតពីការកាត់ទោស នេះមិនមានន័យថាជនដែលបង្កឲ្យ ម៉ៅ សុខច័ន្ទ ស្លាប់និងទទួលបាននិទ្ទណ្ឌភាពចំពោះទង្វើរបស់ខ្លួននោះឡើយ ។

ទោះបីជានៅតែមិនច្បាស់ត្រង់ថា ម៉ៅ សុខច័ន្ទ ខ្លួនឯងអាចត្រូវបានចាត់ទុកថាជាទុក្ករបុគ្គល ដែលបានលះបង់យ៉ាងធំធេងដើម្បីបុព្វហេតុប្រជាធិបតេយ្យសម្រាប់ប្រទេសជាតិរបស់គាត់យ៉ាងណាក៏ដោយ ក៏ជីវិតរបស់គាត់ត្រូវបានបាត់បង់ខណៈពេលដែលព្រឹត្តិការណ៍កំពុងតវ៉ាទាមទារឲ្យមានអនាគតប្រសើរជាងមុនសម្រាប់ប្រទេសជាតិរបស់គាត់ដែលគាត់នឹងមិនមានឱកាសរស់រានមានជីវិតដើម្បីមើលភាពប្រសើរនោះបាន ។ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សគឺជាបុព្វហេតុទាំងឡាយ ទោះបីជាបុព្វហេតុទាំងនោះជាសេចក្តីប្រាថ្នាដ៏អង់អាច និងថ្លៃថ្នូក៏ដោយ វាជាការគួរឲ្យសោកស្តាយដែលវាតម្រូវឲ្យមានការលះបង់ជីវិតមនុស្សនិងការបូជាជាច្រើននៅក្នុងប្រទេសកម្ពុជានិងនៅទីកន្លែងផ្សេងទៀតមុននិងប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សចេញជារូបរាងឡើង ។ លើកទីមួយនៅក្នុងប្រវត្តិសាស្ត្រដែលពោរពេញទៅដោយចលាចល កម្ពុជាពេលនេះកំពុងតែបណ្តុះនូវមូលដ្ឋានប្រជាធិបតេយ្យរបស់ខ្លួនតាមរយៈកិច្ចខិតខំប្រឹងប្រែង និងការបូជាជីវិតរបស់ ម៉ៅ សុខច័ន្ទ និងប្រជាជនកម្ពុជាផ្សេងទៀតដែលបានលះបង់ដូចជារូបគាត់ដែលបានក្រោកឈរឡើងដើម្បីទាមទារឲ្យប្រទេសជាតិរបស់ខ្លួនមានភាពប្រសើរជាងមុន ។ ខណៈពេលដែលគោលដៅចុងក្រោយនៃការធ្វើឲ្យប្រទេសជាតិមួយទៅជាប្រទេសប្រជាធិបតេយ្យពិតប្រាកដដែលគោរពសិទ្ធិមនុស្សជាមូលដ្ឋានគ្រឹះអាចមិនទាន់ទទួលបានសម្រាប់ពេលបច្ចុប្បន្ននេះក្តី យើងមិនគួរភ្លេច ម៉ៅ សុខច័ន្ទ ដែលបានលះបង់ជីវិតដើម្បីយើងទាំងអស់គ្នាមិនថា ពេលបច្ចុប្បន្នឬពេលអនាគតក្តី នៅពេលដែលឧត្តមគតិមួយដែលគាត់ស្លាប់ដោយសារ ហើយទីបំផុតយើងទាំងអស់គ្នាសម្រេចបានឧត្តមគតិទាំងនោះក្នុងពេលអនាគត ។ **ឆាំង យុ**

- **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ចម្លើយសារភាព គង់ សុផល ក្មួយរបស់អាចារ្យ ហែម ចៀវ

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៩៩០១៥***

ខ្ញុំឈ្មោះ គង់ សុផល ឈ្មោះប្រើក្នុងបដិវត្តន៍ គឺ កើតនៅឆ្នាំ១៩២៧ នៅកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ។ នៅរវាងឆ្នាំ១៩៣២ ពេលខ្ញុំអាយុ៥ឆ្នាំ ឪពុកម្តាយខ្ញុំបាននាំខ្ញុំមករស់នៅបាតដឹង ស្រុកឧត្តុង្គ ដែលជាស្រុកកំណើតគាត់វិញ ។ រវាងឆ្នាំ១៩៣៤-៣៥ ម្តាយខ្ញុំបានយកខ្ញុំមករៀននៅវត្តដំបូកមានល័ក្ខ ។ ដល់ឆ្នាំ១៩៣៧ ឪពុកធំខ្ញុំឈ្មោះអាចារ្យ ហែម ចៀវ បាននាំខ្ញុំ និងប្អូនជីដូនមួយមកនៅភ្នំពេញដើម្បីរៀនភាសាបារាំង និងភាសាបាលីនៅវត្តខណ្ឌលោម កុដិ ជួន ណាត ។ ខ្ញុំរស់នៅជាមួយឪពុកមាខ្ញុំជាងបួនឆ្នាំ ។ ដល់ឆ្នាំ១៩៤០ ឪពុកមាខ្ញុំត្រូវអាណានិគមបារាំងចាប់ខ្លួនជាមួយ ប៉ាច ឈឿន ហើយបានស្លាប់ទៅ ។ ខ្ញុំបន្តរស់នៅវត្តរហូតដល់ឆ្នាំ១៩៤៥ ទើបប្រឡងចូលវិទ្យាល័យស៊ីសុវត្ថិ ។

រវាងឆ្នាំ១៩៤៩-៥០ ខ្ញុំបានសុំចេញពីវិទ្យាល័យស៊ីសុវត្ថិ ទៅធ្វើគ្រូបង្រៀននៅសាលាជីកូ ខេត្តស្វាយរៀង ។ រហូតដល់ឆ្នាំ១៩៥២ ខ្ញុំបានផ្លាស់មកបង្រៀននៅកំពង់កន្ទួត និងរៀបគ្រួសារនៅទីនោះ ។ នៅឆ្នាំដែលខ្ញុំបានស្គាល់ឈ្មោះ ថាច់ ខេត ធ្វើជាគ្រូបង្រៀន បានអប់រំខ្ញុំឲ្យស្រឡាញ់ សឺង ង៉ុកថាញ់ ។ មកដល់ពេលបោះឆ្នោតគាត់ក៏បបួលខ្ញុំឲ្យឧបត្ថម្ភ សឺង ង៉ុកថាញ់ ទៀត ។ នៅឆ្នាំ១៩៥៥ ថាច់ ខេត បានបញ្ចូលខ្ញុំជាខ្មែរសេរី និងណែនាំឲ្យខ្ញុំចាត់តាំងកម្លាំងថ្មីទៀតដើម្បីពង្រីកខ្មែរសេរី ។

នៅឆ្នាំ១៩៥៥-៥៦ ខ្ញុំបានពង្រីកអ្នកដែលមានសមានចិត្តចំពោះខ្មែរសេរី នៅសាលាយុគន្ធរមានឈ្មោះ ស៊ឹម សុន សាស្ត្រាចារ្យ សព្វថ្ងៃធ្វើទូតនៅកូរ៉េ និងឈ្មោះ ឌិម បូរី សាស្ត្រាចារ្យ នៅសាលាយុគន្ធរ ។ ឯនៅភូមិទឹកល្អក់ ខ្ញុំក៏បានចាត់តាំង ជី ហាយ ហៅ ហំ ឲ្យធ្វើខ្មែរសេរីដែរ ។

នៅឆ្នាំ១៩៥៧ ទុំ សុនហេង ធ្វើអេកូណូម (កាន់ខាងបើកលុយ) នៅអនុវិទ្យាល័យយុគន្ធរ បានហៅខ្ញុំទៅជួបហើយស្នើឲ្យខ្ញុំជួយធ្វើការងារសុត (កាយាឫទ្ធិ) ។ ឯប្រាក់ដែលខ្ញុំធ្លាប់ជំពាក់គាត់ចំនួន២០០រៀល គាត់ថាបើមានក៏សងបើគ្មានក៏មិនអីដែរ ។ មួយអាទិត្យក្រោយមក ទុំ សុនហេង និង គ្រួច ស៊ីណារាក់ បានចាត់តាំងខ្ញុំឲ្យចូល សេ.អ៊ី.អា ចក្រពត្តិអាមេរិក ។

នៅអំឡុងខែឧសភា ឆ្នាំ១៩៥៧ ថាច់ ខេត បាននាំខ្ញុំទៅជួបខៀវ ធ្វើការងារបង្កោល ។ ខ្ញុំក៏សួរ ខេត ថា ចុះក្រែងចូលសេអ៊ីអាហើយ ហើយចូលអង្គការផ្សេងទៀតកាន់តែច្រើន? គាត់ញញឹមហើយឆ្លើយមកវិញថា សេ.អ៊ី.អា ត្រូវមានកម្លាំងបង្កប់គ្រប់កន្លែង ព្រោះក្នុងសមាគមទឹកល្អក់ ក៏មាន វន (វ៉ន វ៉េត) ធ្វើគយ និង អ៊ុច វ៉ែន មកពីបារាំងជា សេអ៊ី.អា ដែរ ។ ចំណែកខាងយុវជនក៏មានឈ្មោះ ផៃ ហៅទុំ ឈ្មោះ កែ គិមហួត ។

នៅឆ្នាំ១៩៥៨ ខ្ញុំត្រូវបានចាត់តាំងជាបក្ខជននៃបក្សពលករកម្ពុជា នៅផ្ទះបង ខៀវ (សុន សេន) ក្រោយវិទ្យាល័យស៊ីសុវត្ថិ ដែលមាន បងខៀវ និង បងវ៉ាន់ (អៀង សារី) ជាអ្នកឧទ្ទេសនាម ហើយបង ប៉ុល (ប៉ុល ពត) ជាថ្នាក់លើទទួលស្គាល់ ។ ក្រោយពីចូលជាបក្ខជនហើយ អង្គការបានចាត់តាំងខ្ញុំឲ្យចូលក្នុងសាខានៅវិទ្យាល័យស៊ីសុវត្ថិ និងយុគន្ធ ហើយនាំពាក្យ បងវ៉ាន់ ទៅសមមិត្ត ពៅ យូឡេង ខាងសាលាសិល្បៈរបស់ ហង់ ធុនហាក់ ។

នៅឆ្នាំដដែល ខ្ញុំបានចូលរួមធ្វើសកម្មភាពជាដួងបក្សជាមួយគណៈកម្មាធិការក្រុងរបស់យុវជន យុវនារី ដែលមានខ្ញុំជា


វ៉ន វ៉េត ហៅ វន


សុន សេន ហៅ ខៀវ

ប្រធាន មានសមមិត្ត ហុក នៅវិជ្ជាស្ថានជាតិគរុកោសល្យ មិត្តគី នៅសាលាកម្ពុជបុត្រ មិត្តទុំ និង មិត្តសោម នៅចំរើនវិជ្ជា ។ ខ្ញុំបាន ខិតខំកសាងអ្នកទាំងអស់ ក្នុងដំហររៀបចំលក្ខណៈសម្បត្តិចូលជា ចាត់តាំង ។ នៅឆ្នាំ១៩៥៩ ខាងក្រុមប្រជាជនមានឈ្មោះ កែវ មាស ខុទ្ទេសនាមខ្ញុំឲ្យទៅប្រធានយាយជី ខាងគ្រិស្តសាសនា ។ ខាងក្រុមប្រជាជនក៏ចាប់ផ្តើមកសាង សេ.អ៊ី.អា ឯរូបខ្ញុំគ្រាន់តែ ជួយរួមចំណែកពិនិត្យព្រោះនៅអង្គភាពជាមួយគ្នា ។ ឯខាងផ្លូវ បក្សរូបខ្ញុំជាប្រធាន ។

ឆ្នាំ១៩៦២ គិញហោ និង គិញមុខខ្វូត តាមសម្លុតខ្ញុំជាប់ ។ ដូច្នេះនៅចុងឆ្នាំដដែល ខ្ញុំក៏ចូលធ្វើការសម្ងាត់ក្រោមការសម្រេច របស់ ទុំ សុនហេង និងត្រូវប្តូរផ្ទះពីទឹកល្អក់មកផ្សារអូរឬស្សីវិញ ។ ក្រោយមក ខ្ញុំបានប្តូរទៅនៅទួលប្រស្រី នៅបូរីកីឡា ។ ខ្ញុំបានទាក់ ទងគ្រប់កម្លាំង ដោយខាងកម្លាំងកាសែតឯកភាពមានឈ្មោះ សឹម ដឹងហាយ ខាងកាសែតមេគង្គឈ្មោះ ហឹម វ៉េត ឯផ្នែកខាងកម្មករ មានឈ្មោះ វន ។ ខាងកម្លាំងយុវជនទាក់ទង នារីស៊ុំ និង នារីជា (កូនតា សោ ឆុំ) និងឈ្មោះ ហេង គី ។ អង្គការឲ្យខ្ញុំទៅទាក់ទង ទីវ អុល ហៅ សោម និង ហុក នៅសាលាគរុកោសល្យទៀត ។ នៅ ឆ្នាំ១៩៦២ដដែល ខ្មាំងរាតត្បាតទ្រង់ទ្រាយធំ ក្រុមវ៉ាញ នៅ តាកែវ សមមិត្ត ហុក នៅភ្នំពេញត្រូវចាប់ ចំណែកសមមិត្ត អន ត្រូវរត់ចោលផ្ទះ ។

នៅឆ្នាំ១៩៦៣ បងនួន (នួនជា) បងប៉ាង បងវន និងខ្ញុំបាន ជជែកគ្នា និងឯកភាពគ្នាលើការបញ្ចេញ បញ្ញាជន និងសិស្សដែល បែកមុខ (បែកការណ៍) ទៅក្រៅ ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៤ ខ្ញុំបានទៅបាត់ដំបងតាមផ្លូវបក្ស ដោយមាននីរសារឈ្មោះ ទាត់ នាំផ្លូវទៅដល់មន្ទីរ ។ ខ្ញុំបាននៅ ធ្វើការជាមួយនីរសាររបស់ ញឹម ឈ្មោះ ស៊ុយ ជាប្រធានមន្ទីរ និង ឈ្មោះ សុខ ។

នៅខែកុម្ភៈ ដដែល ខ្សែថ្មីចេញពីក្រុងបានទៅដល់ រួមមាន ថាប់ គឹមសឹង, ខែក ប៉ែន, និង វ៉ាញ បានទៅជួបខ្ញុំនៅផ្ទះសំណាក់ នីរសារ ហើយខុទ្ទេសនាមខ្ញុំថា ឈ្មោះ សាយ និង វន ឲ្យទាក់ទង តំបន់៣០៤ ខាង កុយ ធួន ជាសេអ៊ីអាដែរ ។

នៅឆ្នាំ១៩៦៤ ដដែលអង្គការបានកោះហៅមកធ្វើសន្និបាត


កុយ ធួន អតីតលេខាភូមិភាគឧត្តរនៅក្នុងមន្ទីរឃុំឃាំងស-២១

នៅក្នុងព្រៃស្មួង បំពាក់ពីការតស៊ូហិង្សា និងខ្លួនទីពឹងខ្លួន ដោយខ្ញុំ, ធុច, ពឹម, ស៊ី, ចុង, ភឹម និង ទុំ មានជំនឿថាចលនានេះនឹងពិតជា ទៅមុខ ។ ក្រោយមកយើងក៏ចុះមករៀបនៅមូលដ្ឋានវិញ ។

នៅឆ្នាំ១៩៦៥ ខ្ញុំ និង ញឹម បានបញ្ជាឲ្យវាយស្ពានអូដាំ ។ នៅពេលអង្គការហៅឈ្មោះ ញឹម ឲ្យទៅជួបខាងលើ ខ្ញុំធ្វើឲ្យចលនា នេះគ្រប់គ្រងលែងបាន និងបាត់ម្ចាស់ការ ។ រហូតដល់ពេល ហឹង, ស៊ុយ និង សាយ មកសួរខ្ញុំ ខ្ញុំបានសម្រេចថា ប្រើហិង្សាដើម្បីរៀបចំ ធ្វើកុបកម្មរឹបយកអាវុធតាមភូមិទៀត ធ្វើឲ្យខ្មាំងតាមបង្អត់បាយ ប្រជាជន និងបាញ់សម្លាប់ប្រជាជនតាមព្រៃជាប់ ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៧ ញឹម បានត្រឡប់ទៅដល់កន្លែង អង្គការក៏បានកោះហៅខ្ញុំមកធ្វើការវិញ ។ បក្សបានសម្រេចឲ្យ ផ្អាកការតស៊ូភ្លាមព្រោះបើបាត់ដំបងផ្ទុះតែម្នាក់ឯង ខ្មាំងនឹងកម្ទេច កម្លាំងបដិវត្តន៍ទាំងអស់ ។

នៅចុងឆ្នាំ១៩៦៧ បងនួន កោះហៅខ្ញុំមកធ្វើការនៅផ្ទះ ដែលខ្ញុំធ្លាប់នៅ គឺផ្សារអូរឬស្សី ដែលនៅទីនោះមាន ប៉ាង និង វន

សម្រេចឲ្យផ្ទុះអាវុធទៀត ។ ក្រោយពីប្រជុំចប់នៅម៉ោង៨យប់ ខ្ញុំក៏ត្រឡប់មកមូលដ្ឋានដោយយកដំណឹងទៅផ្សព្វផ្សាយ ដោយមានត្រៀមអាវុធ និងកម្លាំង ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៨ កម្លាំងបដិវត្តន៍ផ្ទុះកាំភ្លើងនៅបាយដំរាម ហើយពេលល្ងាច កម្លាំងយើងបានធ្វើដំណើរទៅដល់សាំងរាំង និងភ្នំវាយចាប ។ នៅខែមេសា ឆ្នាំដដែល សេក សំអៀត បាននាំកម្លាំងមកព័ទ្ធភ្នំវាយចាប ។ ពេលនោះឈ្មោះ សយ, ទាត់ និង យ៉ន បញ្ជាការឈ្លបស្រុក បានមកសុំយោបល់ដោះស្រាយ ខ្ញុំក៏បានឲ្យប្រមូលកម្លាំងទាំងអស់វាយទីតាំងយោធារបស់ លន់ នល់ នៅភូមិកណ្តាល ប៉ុន្តែបានបរាជ័យ ។

នៅខែឧសភា ខ្ញុំសម្រេចឲ្យប្រមូលប្រជាជនទម្លាយផ្លូវខាងថ្មក្រោក ដើម្បីរកច្រកចេញទៅ ទឹកផ្អឹម និងស្ទឹងតូច ។ កម្លាំងជាង ៨.៥០០ បានចេញផុតពីភ្នំវាយចាប នៅសល់តែ៥០នាក់ ។ ខ្ញុំក៏ឲ្យប្រជាជននៅទីនោះដីកដំឡូងហូប និងរស់នៅជាក្រុមសិន ។ រហូតដល់ខែសីហា ឆ្នាំ១៩៦៨ យើងប្រមូលកម្លាំងបានពីរវរសេនាធំ ដើម្បីដើររកខ្មាំងវាយយកអាវុធ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៦៨ ខ្ញុំបានទៅដល់មន្ទីរនៅក្រញូង និងបានជួប ខែក ប៉ែន ហៅ ស៊ូ, សាន, ហឹង និង ញឹម ។ ពីរថ្ងៃក្រោយមក កន្តុល ក៏មកដល់ដែរ ។ បរិយាកាសនៅមន្ទីរនេះមានទំនាស់គ្នាច្រើនពីរឿងស៊ីចុក ។

ខែធ្នូ ឆ្នាំដដែល សាយ, ទាត់, កុក និង ស៊ុយ ក៏មកដល់ទៀត ហើយដំណឹងទាក់ទងរបស់ ស៊ុយ ជាមួយភ្នំពេញក៏ទាក់ទងបានតាមភ្នំវាយចាប ។ នៅឆ្នាំ១៩៦៩ ខ្ញុំបានត្រឡប់មកភ្នំវាយចាបវិញ ក្រោយមកខ្ញុំបានឡើងទៅទាក់ទងផ្ទាល់ជាមួយអង្គការ ដោយខ្ញុំឲ្យមិត្ត ប៉ូ នីរសារកាន់ខាងទូរស័ព្ទ ជូនខ្ញុំទៅរកប្រពន្ធខ្ញុំនៅខត្តុង្គ ដោយមាន តេង និង ឌុច ទទួលយកខ្ញុំទៅលាក់នៅស្រែអូ ។ ខ្ញុំបានជួបប្រពន្ធខ្ញុំនៅទីនោះ តែខ្ញុំចាប់ផ្តើមក្អកធ្លាក់ឈាមយ៉ាងច្រើន ។ បងស្រីខ្ញុំឈ្មោះ ដេន បានរៀបចំឡានមកយកខ្ញុំទៅព្យាបាលនៅខត្តុង្គវិញ ។ ស្រាប់តែម៉ោង១២យប់ ឡានរបស់ មិត្តសេង បានមកកន្លែងខ្ញុំ ព្រោះដឹងច្បាស់ថាខ្ញុំមានជំងឺ ដោយ បងនួន និង បងវ៉ន ឲ្យមកយក ។ សេង បាននាំខ្ញុំទៅជួប បងវ៉ន នៅបុរីកីឡា ។ ក្រោយពីសួរសុខទុក្ខហើយ បងវ៉ន ឲ្យខ្ញុំស្នាក់នៅទីនោះមួយថ្ងៃ ទើបបញ្ជូន ខ្ញុំមកផ្លូវអូហ៊ីយេ កន្លែងសមមិត្ត យ៉ាត សម្រាក ហើយពេទ្យព្យាបាល បងនួន ក៏មកជួបខ្ញុំ ។

ខ្ញុំសម្រាកព្យាបាលបានជាងមួយអាទិត្យ បងនួន បានណែនាំឲ្យចាប់ខ្សែឡើងវិញកុំឲ្យដាច់ ហើយសម្រេចផ្តល់គ្រាប់ឲ្យពាយ័ព្យជាងមួយឡាន ឲ្យកាំភ្លើងខ្លីប៉េអាកុលមួយដើម និងប្រាក់មួយចំនួនមកខ្ញុំ ។ នៅខែកុម្ភៈ ឆ្នាំ១៩៦៩ ខ្ញុំ និងគ្រាប់បានមកដល់ភ្នំវាយចាប ហើយក៏ធ្វើការបែងចែក ។ នៅឆ្នាំដដែល បងនួន បានហៅខ្ញុំទៅធ្វើការនៅភ្នំពេញវិញ ។ នៅទីនោះខ្ញុំបានជួបសមមិត្ត ម៉ុក និងធ្វើការអស់មួយថ្ងៃ ស្តីពីទស្សនៈ សភាពការណ៍ និងវិធានការខាងខ្ញុំដោយត្រូវដាក់ខ្សែនីរសារកាត់ពីឱរ៉ាល់ទៅមោង ។ បន្ទាប់ពីប្រជុំចប់ ខ្ញុំក៏ចុះតាមផ្លូវជាតិលេខ៤ មកព្រៃធំវិញដោយសរសេរសំបុត្រឲ្យ វ៉ែន ប្រធានយោធាភ្នំវាយចាប និងឈ្មោះ ខ្វង មកនាំផ្លូវ ។

ពេលចាំនីរសារនៅកំពង់ឆ្នាំង ខ្ញុំបានជួប មិត្តស៊ុំ, សឿង និង មិត្តវ៉ន ។ ស្នាក់នៅទីនោះបានមួយរយៈ ខ្ញុំបានជម្រាប បងម៉ុក ធ្វើដំណើទៅបាត់ដំបងកាត់តាមពោធិ៍សាត់ ដោយមានកម្មាភិបាលមកពីបស្ចិមមកជាមួយផង ។ បងម៉ុក ក៏បានរៀបចំកាំភ្លើង និងគ្រាប់ឲ្យមកខាងខ្ញុំទៀត ។

យើងធ្វើដំណើរអស់១៣យប់ ១៣ថ្ងៃទើបមកដល់ពាយ័ព្យ ខ្ញុំបានរាយការណ៍មកភ្នំពេញថា ខាងព្រៃដើរបានហើយ ។ ខាងលើក៏សម្រេចឲ្យនាំ ញឹម និងកម្មាភិបាលគ្រប់ផ្នែកមានឈ្មោះ កន្តុល, វ៉ាង, សាន, វ៉ាញ, អ៊ីន, ទាត់, តូច, គូ និងខ្ញុំទៅធ្វើការនៅនិរតី ។

យើងធ្វើដំណើរអស់៨យប់ បានមកដល់ឱរ៉ាល់ជួបនឹង បងនួន និង បងវ៉ន នៅខែតុលា ឆ្នាំ១៩៦៩ ។ ខ្ញុំធ្វើការនៅទីនោះអស់រយៈពេល១០ថ្ងៃ ទាំងរៀនសូត្រទស្សនបដិវត្តន៍ ។ ចប់វគ្គ បងនួន បានឲ្យខាងបាត់ដំបងត្រឡប់ទៅវិញដោយទុកតែខ្ញុំម្នាក់ដើម្បីទប់ទល់នឹងខ្មាំងរាតត្បាត ។ ខ្មាំងវាយយកឱរ៉ាល់មិនបាន ។ បងនួន ឈឺត្រូវចេញដំណើរទៅផុត ចំណែក បងវ៉ន ដែលឈឺធ្ងន់ដែរនោះ ក៏ជាប់លើកំពូលភ្នំឱរ៉ាល់ ។ ស្ថានភាពធូរស្រាល ខ្ញុំបានឡើងទៅលើភ្នំលា បងវ៉ន និង បងម៉ុក ត្រឡប់ទៅពោធិ៍សាត់វិញ ដោយទាំងពីរនាក់យល់ព្រមបន្ថែមកាំភ្លើងឲ្យខាងខ្ញុំ ។

នៅថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ផ្ទុះរដ្ឋប្រហារ ប្រជាជនបានកាត់មករកបដិវត្តន៍រាប់រយពាន់នាក់ ចំណែកខ្មាំងមកប្រមូល

ជុំគ្នាតែនៅផ្លូវជាតិ និងទីប្រជុំជនប៉ុណ្ណោះ ។ ពេលនោះ មានយួនមកពីបាក់ចិញៀន ឈ្មោះ សាវ មកសុំជួបខ្ញុំផ្ទាល់ ដើម្បីចាត់តាំងគណៈកម្មាធិការចម្រុះ ។ ខ្ញុំបានសរសេរលិខិតមួយទៅ បងវន ដើម្បីសុំការណែនាំ ។ បីថ្ងៃក្រោយមក ខ្ញុំឃើញក្រុមវិទ្យុយួន១០នាក់ដឹកនាំដោយ ណាំ ឌិម និង ហៃ សុិញ មកជួបខ្ញុំថា បាននាំទ័ពមួយវរៈសេនាតូចមកភាគពាយ័ព្យ តាមការណែនាំរបស់ បងម៉ុក ដោយមានទូរលេខមួយអម ចុះហត្ថលេខាដោយ បងនួន ផ្ញើមកខាងពាយ័ព្យឲ្យទទួលស្គាល់យួន និងសហការគ្នាឲ្យបានជិតស្និទ្ធ ។ ខ្ញុំបានទទួលទូរលេខមួយទៀតថា ឲ្យទៅជួបនៅអមលាំងវិញ ។ ដេកនៅអមលាំងមួយយប់ យួនឈ្មោះ ហៃសុី បានអញ្ជើញខ្ញុំ និង បងម៉ុក ទៅហូបសាច់ឆ្កែ និងផឹកស្រា ។

ស្អែកឡើង ខ្ញុំបានធ្វើដំណើរជាមួយ បងម៉ុក រហូតដល់ស្រែចាន ធ្វើឲ្យឡោកឡានឡង់រ៉ូវ៉ែរមួយគ្រឿង ព្រោះខុះខ្សែជ្និតទឹក ។ ខ្ញុំធ្វើដំណើរជាមួយ បងម៉ុក បន្តរហូតដល់កំពង់ថ្មទើបជួបឈ្មោះ វ៉ា ហើយជិះត្រាក់ទ័ររហូតដល់បឹងល្វាទើបជួប បងពក ។ បងពក បានឆែកខ្ញុំហើយ ទើបជូនចូលរហូតដល់កន្លែង បងនួន ។ ខ្ញុំត្រូវរង់ចាំរហូតដល់១៥ថ្ងៃ ទើបជួប បងប៉ុល ។ ក្រោយមក ទើប បងប៉ុល បើកសាលារៀន ។ ខ្លឹមសារសំខាន់ គឺសភាពការលោតផ្លោះរបស់បដិវត្តន៍ ការរលំរលាយរបស់ចក្រពត្តិអាមេរិក និង លន់នល់ និង យួនដែលចង់ឆក់ឱកាសគ្រប់គ្រងកម្ពុជា ។ ពេលត្រឡប់មកដល់កន្លែងវិញ ខ្ញុំឃើញយួនមានឥទ្ធិពលមែន ហើយកម្មាភិបាលភ្លឹតភ្លើនទាំងសម្ភារ និងសិទ្ធិអំណាចទៀត ។

ខណៈនោះ ញឹម ត្រូវបានអង្គការកោះទៅរៀនជាមួយ បងវន ។ រយៈពេល១៥ថ្ងៃក្រោយមក ញឹម បានត្រឡប់មកវិញ រួចរៀបចំមន្ទីរនៅរួមគ្នានៅខាងភ្នំពាក់ត្រយោង ដោយមានឈ្មោះ មាស និង សូត្រ មកពីវៀតណាមខាងជើងធ្វើជាប្រធានមន្ទីរនីរសារ ហើយ ញឹម ទទួលខុសត្រូវរៀបចំកងទ័ព ។

នៅឆ្នាំ១៩៧១ មជ្ឈិមបក្សបើកសាលាធំមួយខាងកើតទន្លេមេគង្គដោយប្រមូលកម្មាភិបាលនៅទូទាំងប្រទេសមករៀន ។ ក្រោយពេលចប់ ខ្ញុំបានធ្វើដំណើរត្រឡប់មកវិញតាមផ្លូវសូត្រនិគមដោយមានឈ្មោះ ញឹម និង ពក ជូនដល់កំពង់ឃ្លាំង ។ ញឹម ត្រូវបក្សឲ្យទៅបើកសមរភូមិនៅតំបន់៥ និង វ៉ារិន សៀមរាប ។ ចំណែកខ្ញុំមកខាងពាយ័ព្យខាងកើតវិញ ។

ឆ្នាំ១៩៧២ អង្គការឲ្យនាំទ័ពទៅវាយផ្លូវលេខ១០ ដើម្បីកាត់ផ្តាច់ ។ យើងបានទទួលជ័យជម្នះវគ្គទីមួយ ។ ប៉ុន្តែវាយមិនដាច់នៅសមរភូមិបាដាក សង្កែ ទឹកពុះ និងអំពិលប្រាំដើម ដោយសារខ្ញុំអនុវត្តមិនបានត្រឹមត្រូវនូវមាគ៌ាកសាងយោធារបស់បក្ស ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ អង្គការបានដកអ្នកមកពីហាណូយចេញអស់ និងរំសាយមួយអនុសេនាធំទៀតដោយសារមេបញ្ជាការទាំងនោះមានស្រី ។

ក្រោយពេលជ័យជម្នះ ១៧ មេសា ខ្ញុំបានដក វ៉ែន ចេញពីលេខាតំបន់២ដោយគ្មានដាក់ពិន័យ ដោយសារតែសាមីខ្លួនពុករលួយ និងពាលាអាវ៉ាសែ ។ នៅឆ្នាំ១៩៧៦-៧៧ ប្រជាជននៅតំបន់ពោធិ៍សាត់ជាច្រើនបានអត់បាយ ដោយខ្ញុំសម្រិតសម្រាំងសមាសភាពរដ្ឋអំណាចមិនបានល្អ ។

រហូតដល់ឆ្នាំ១៩៧៨ អង្គការបានហៅ ញឹម និង ខ្ញុំមកធ្វើការ តែប្រែជាអត់វិញ ដោយហេតុផលថា មានភ្ញៀវយូហ្គោស្លាវីមក ។ ញឹម និង ខ្ញុំបានឆ្លៀតឱកាសនេះធ្វើសន្និបាតភាគ ហើយខ្លឹមសារគឺស្តីបន្ទោសកម្មាភិបាលដែលដោះស្រាយជីវភាពប្រជាជនមិនបាន ។

រំលងបានពីរថ្ងៃ មានសំបុត្រមួយហៅខ្ញុំ និង ញឹម ទៅភ្នំពេញ ។ ពេលទៅជិតដល់សាង ឡានរបស់ ញឹម ក៏ទៅផុតចំណែកឡានខ្ញុំត្រូវហៅឲ្យឈប់ ។ ខ្ញុំនឹកភ្នកថា រឿងនេះមិនស្រួលទេ ។ ពេលមកដល់ភ្នំពេញខ្ញុំសួរ បងវន ថា ញឹម នៅឯណា? គាត់ឆ្លើយថា ទៅសម្រាកពេទ្យហើយ ។ ញឹម ត្រូវចាប់ខ្លួននៅខែ៨ ឆ្នាំ១៩៧៨ ហើយ បងម៉ុក ឡើងជាលេខាជំនួស ។

នៅពេលនោះ ខ្ញុំមិនដឹងថាខ្លួនឯងគេចរួចឬយ៉ាងណាទេ ។ ផ្លូវមានពីរ គឺមួយរត់ចោលស្រុក ឬមួយឈប់ធ្វើសកម្មភាពក្បត់បក្សទៀត ។ ក្រោយមក ខ្ញុំទទួលមតិណែនាំអំពីបក្សដល់អ្នកទាំងអស់ដែលចូលបក្សតាំងពីឆ្នាំ១៩៥៤ ដល់១៩៧៨ ឲ្យកែប្រែខ្លួន ។ ចាប់ពីនោះមក ខ្ញុំលែងហ៊ានធ្វើសកម្មភាពឲ្យប៉ះពាល់ដល់បក្សទៀត លើកលែងតែធ្វើដំណើរទៅសៀម ។ ក្រោយមក បក្សបានដកខ្ញុំចេញពីមូលដ្ឋានពោធិ៍សាត់ទាំងមូល រហូតដល់អង្គការចាប់ខ្លួនខ្ញុំតែម្តង ។ **សោម ប៊ុនថន**

# បទឧទ្ទេសនាមរបស់សមមិត្តតំណាងអង្គការបក្សក្នុងឱកាសបុណ្យខួបទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន និងខ្លាំងពូកែមហាអស្ចារ្យ

*"ដកស្រង់ចេញពីសៀវភៅ យុវជន និងយុវនារីបដិវត្តន៍ លេខ៥ ខែឧសភា ឆ្នាំ១៩៧៦"*

ថ្ងៃ១៧ មករា ឆ្នាំ១៩៧៧ ជាថ្ងៃបុណ្យរំឭកខួបទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាយើង ។ នៅក្នុងឱកាសនេះ នៅភ្នំពេញមានធ្វើមហាមីទ្ទិញមួយ ដោយមានយុទ្ធជន យុទ្ធនារី នៃកងទ័ពបដិវត្តន៍កម្ពុជា មានសមាជិកគណៈកម្មាធិការគ្រប់កងពល មានតំណាងកងទ័ពប្រចាំភូមិភាគនានា និងមានកម្មាភិបាល និងយុទ្ធជនយុទ្ធនារីគ្រប់ក្រសួង មន្ទីរមកចូលរួមប្រជុំផង ។

ក្នុងឱកាសនោះ សមមិត្តតំណាងអង្គការបក្សបានធ្វើបទឧទ្ទេសនាមមួយ ដែលបង្ហាញឲ្យឃើញច្បាស់នូវទិដ្ឋភាពគ្រប់ផ្នែករបស់កងទ័ពបដិវត្តន៍ យើងឃើញអនុភាពខ្លាំងក្លានៃកងទ័ពបដិវត្តន៍យើង នៃបដិវត្តន៍យើង នៃបក្សយើង នៃប្រជាជនយើង នាំឲ្យយើងមានពន្លឺ និងមានជំនឿជឿជាក់ និងច្បាស់លាស់លើបក្សយើង លើកងទ័ពយើង លើបដិវត្តន៍យើង លើមាគ៌ាគ្រប់ផ្នែករបស់បក្សយើង និងលើប្រជាជនយើង ។

យើងខ្ញុំសូមដកស្រង់ចំណុចសំខាន់ៗនៃបទឧទ្ទេសនាមនេះមកចុះផ្សាយដើម្បីជូនសមមិត្តយើងសិក្សារៀនសូត្រដូចតទៅៈ

ខ្ញុំសូមតាងនាមនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយសូមតាងនាមគណៈកម្មាធិការយោធានៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាយើង សូមសម្តែងនូវអំណរគុណសាទរចំពោះសមមិត្តជាតំណាងទាំងអស់នៃកងទ័ពទាំងបីប្រភេទ និងគ្រប់ផ្នែកទាំងជើងគោក ជើងទឹក និងជើងអាកាស ព្រមទាំងសមមិត្តជាតំណាងនៃកងទ័ពប្រចាំនៅតាមភូមិភាគនានា ហើយនឹងអបអរសាទរចំពោះសមមិត្តតំណាងគ្រប់ក្រសួង គ្រប់មន្ទីររបស់បក្សនៃរដ្ឋធានីទាំងអស់ដែលបានមកជួបជុំគ្នាថ្ងៃនេះដើម្បីធ្វើពីធីបុណ្យខួបឆ្នាំទី៩នៃកំណើតកងទ័ពបដិវត្តន៍យើង ។ ក្នុងថ្ងៃនេះ តាំងនាមគណៈកម្មាធិការយោធានៃមជ្ឈិមបក្សយើង ខ្ញុំសូមឧទ្ទេសនាមបញ្ហាមួយចំនួនដែលទាក់ទងដល់ប្រវត្តិនៃកងទ័ពបដិវត្តន៍យើង ។

**បញ្ហាទី១** គឺការចាប់អារម្មណ៍របស់យើងក្នុងឱកាសធ្វើពិធីបុណ្យខួបឆ្នាំទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាយើង ។

**បញ្ហាទី២** សុំជម្រាបអំពីប្រវត្តិនៃការកកើតកងទ័ពបដិវត្តន៍កម្ពុជាយើង ។

**បញ្ហាទី៣** សុំជម្រាបអំពីទស្សនៈមួយចំនួនស្តីអំពីមាគ៌ាយោធារបស់បក្ស មាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស និងមាគ៌ាប្រយុទ្ធរបស់បក្ស ។

**បញ្ហាទី៤** សុំជម្រាបអំពីភារកិច្ចកសាងពង្រីង និងពង្រីកកងទ័ពបដិវត្តន៍កម្ពុជាយើងតទៅទៀត ។

សំណូមពរនៃការឧទ្ទេសនាមបញ្ហាទាំងអស់នេះ ដើម្បីបង្ហាញឲ្យឃើញនូវទិដ្ឋភាពគ្រប់ផ្នែករបស់កងទ័ពបដិវត្តន៍យើង ។ ទិដ្ឋភាពនៃការកកើតកងទ័ព ទិដ្ឋភាពនៃភារកិច្ចរបស់កងទ័ពបច្ចុប្បន្ន និងអនាគត ដើម្បីឃើញឲ្យច្បាស់ ក្តាប់ឲ្យច្បាស់នូវទស្សនៈនេះ សម្រាប់មានពន្លឺ និងជំនឿច្បាស់លាស់ចំពោះបដិវត្តន៍យើង និងភារកិច្ចរបស់កងទ័ពបដិវត្តន៍យើង ។

តទៅនេះ ខ្ញុំសូមចូលក្នុងបញ្ហានីមួយៗដែលបានជម្រាបអម្បាញ់មិញ ។

### ១) ការចាប់អារម្មណ៍របស់យើងក្នុងឱកាសធ្វើពិធីបុណ្យខួបទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាយើង

ក្នុងឱកាសដែលយើងជួបជុំគ្នានៅទីនេះ ហើយក្នុងក្របខ័ណ្ឌ

ក្នុងកាលៈទេសៈនេះ ទូទាំងប្រទេស ក៏ជួបជុំគ្នាដើម្បីធ្វើពិធីបុណ្យខួបឆ្នាំទី៩ នៃការកកើតកងទ័ពយើងដែរ ក្នុងកាលៈទេសៈនេះ យើងចាប់អារម្មណ៍ពីរយ៉ាងសំខាន់ដូចតទៅៈ

ចាប់អារម្មណ៍ទី១របស់យើង គឺថ្ងៃខួបនៃការកកើតកងទ័ពយើងអស់រយៈ៩ឆ្នាំនេះ នាំឲ្យយើងនឹកឃើញដល់វីរភាពដ៏ខ្ពង់ខ្ពស់ដ៏ឧត្តុង្គឧត្តមបំផុតរបស់កងទ័ពបដិវត្តន៍យើង ។ ជាឱកាសដែលយើងស្មឹងស្មាធិ៍ដោយរំជួលចិត្តយ៉ាងជ្រាលជ្រៅ ដោយមនោសញ្ចេតនាបដិវត្តន៍វណ្ណៈ ចំពោះយុទ្ធមិត្តរបស់យើង ជាយុទ្ធជន ជាយុទ្ធនារី ជាកម្មាភិបាលនៃកងទ័ពយើង ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងក្នុងការតស៊ូប្រជាជាតិក្នុងការតស៊ូវណ្ណៈដ៏តឹងតែងស្មុគស្មាញ បត់បែន លំបាកវេទនាជាបន្តបន្ទាប់មក រហូតមកដល់រំដោះប្រទេសកម្ពុជាបានទាំងស្រុង និងជាស្ថាពរ ហើយរំដោះវណ្ណៈកម្មករ កសិករ មកកាន់ឋានៈជាម្ចាស់ប្រទេស ម្ចាស់វាសនារបស់ខ្លួន បានទាំងស្រុង ហើយក៏ជាស្ថាពរដែរ ។

ការចាប់អារម្មណ៍ទី២របស់យើងក្នុងឱកាសនេះ គឺយើងទាំងអស់គ្នា កាលបើនឹកឃើញដល់កងទ័ពបដិវត្តន៍យើងតាំងពីបាតដៃទទេមកដល់ពេលនេះ យើងទាំងអស់គ្នាមានសេចក្តីរីករាយសោមនស្សឥតឧបមា ដោយពីដើម យើងមិនដែលមានកងទ័ពទេ ។ យើងស្ថិតនៅក្នុងក្រញាំនៃចក្រពត្តិនិយម និងវណ្ណៈជិះជាន់ផ្សេងៗទៀត ។ ប៉ុន្តែឥឡូវនេះ កងទ័ពបដិវត្តន៍យើងបានពង្រីងពង្រីកខ្លួនឡើងតាំងពីកងការពារសម្ងាត់ រហូតមកដល់កងឈ្លបកងតំបន់ រហូតមកដល់កងស្រួច ធ្វើសង្គ្រាមឈ្លប ធ្វើសង្គ្រាមសម្បូរបែប ធ្វើសង្គ្រាមផ្ទៃក្នុង និងសង្គ្រាមបដិវត្តន៍រំដោះជាតិរំដោះប្រជាជន ប្រឆាំងចក្រពត្តិអាមេរិក និងបរិវាររហូតដណ្តើមបានមហាជ័យជម្នះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ហើយយើងបានពង្រីងពង្រីកកងទ័ពនេះ ឲ្យខ្លាំងក្លាថែមទៀត ទាំងខាងនយោបាយ ទាំងខាងសតិអារម្មណ៍ ទាំងខាងចាត់តាំង ហើយថ្ងៃនេះ កងទ័ពយើងទៅជាកងទ័ពមួយ មានលក្ខណៈពីរយ៉ាងច្បាស់លាស់ គឺជាកងទ័ពមានធាតុពិតបដិវត្តន៍ផង ជាឧបករណ៍ផ្តាច់ការរបស់បក្សដ៏បរិសុទ្ធផង ហើយជាកងទ័ពមានការចាត់តាំងគ្រប់បែបយ៉ាង ទាំងជើងគោក ទាំងជើងទឹក ទាំងជើងអាកាស ការពារប្រទេស ទាំងព្រំដែនជើងគោក ទាំងព្រំដែនជើងទឹក ទាំងព្រំដែនអាកាស ហើយទាំងលើផ្ទៃប្រទេសកម្ពុជាទាំងមូល ។

ជាប្រវត្តិរាប់ពាន់ឆ្នាំមកហើយ យើងមិនដែលមានកងទ័ពរបស់យើងទេ ។ ឃើញយ៉ាងនេះ បានយើងមានមោទកភាពបានយើងពេញចិត្ត ពេញថ្លើមនឹងប្រជាជនយើង និងកងទ័ពយើង និងបក្សយើង ដែលបានតស៊ូដ៏យូរលង់ ដើម្បីកសាងកម្ពុជាប្រជាធិបតេយ្យ កសាងប្រជាជនកម្មករ កសិករ សមូហភាព កសាងរដ្ឋអំណាចបដិវត្តន៍ ហើយកសាងកងទ័ពបដិវត្តន៍មួយដ៏អង់អាចក្លាហានបំផុត ។

អារម្មណ៍ទាំងពីររបស់យើងក្នុងឱកាសនេះ គឺអារម្មណ៍ដែលយើងគោរពនូវវីរភាពរបស់កងទ័ពយើង ហើយយើងពេញចិត្ត ពេញថ្លើម កងទ័ពបដិវត្តន៍យើង ។

តើក្នុងឱកាសនេះ យើងបានអ្វីតបស្នងសងគុណដល់វីរបុរសយើង? វីរបុរសទាំងនេះ ជាយុទ្ធជន ជាយុទ្ធនារី ជាកម្មាភិបាលនៃកងទ័ពបដិវត្តន៍យើង ដែលបានពលិកម្មទៅ ដ៏អង់អាចក្លាហានដើម្បីបុព្វហេតុរំដោះជាតិ រំដោះប្រជាជន ហើយនិងកងទ័ពបដិវត្តន៍យើង ដែលកំពុងបំពេញភារកិច្ចបច្ចុប្បន្ននេះ ការពារប្រទេសកសាងប្រទេស ពិសេស គឺការពារប្រទេស នៅតាមព្រំដែនគោកនៅតាមព្រំដែនទឹក ហើយនិងនៅលើផ្ទៃប្រទេស ។ តើយើងមានអ្វីតបស្នងសងគុណដល់កងទ័ពយើង ចំពោះបញ្ហានេះ ខ្ញុំសូមជម្រាបដូចតទៅៈ

ទី១ ដើម្បីតបស្នងសងគុណដល់កងទ័ពបដិវត្តន៍យើង ។ គណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការយោធាមជ្ឈិមបក្ស ក្នុងការប្រជុំនាខែ៥ ឆ្នាំ១៩៧៥ គឺ១ខែ ក្រោយពេលដែលយើងរំដោះប្រទេសទាំងស្រុង មជ្ឈិមបក្ស និងគណៈកម្មាធិការយោធា បានសម្រេចថានឹងកសាងវិមាន ឬប្រាសាទមួយ ធ្វើដោយថ្មើមថ្ម ជានិមិត្តរូបតំណាងវីរភាពដ៏ឧត្តុងឧត្តមរបស់វីរបុរសយើងទាំងអស់ ហើយជាពិសេស ចំពោះវីរបុរសនៃកងទ័ពបដិវត្តន៍យើង ។ យើងហៅថាប្រាសាទ ពីព្រោះត្រូវធ្វើឲ្យសមនឹងឋានៈដ៏ខ្ពង់ខ្ពស់ ដែលកងទ័ពបដិវត្តន៍យើងបានលះបង់ដើម្បីជាតិ និងប្រជាជន ។ ឯទីតាំងដែលត្រូវធ្វើនេះគឺធ្វើនៅភ្នំពេញ ជារដ្ឋធានីនៃកម្ពុជាប្រជាធិបតេយ្យយើង តំណាងទូទាំងប្រទេស ហើយធ្វើកន្លែងណា? គឺធ្វើកន្លែងណាដែលខ្ពស់ជាងគេនៅទីក្រុងភ្នំពេញនេះ ។ តាមគម្រោងជាបឋមដែលមជ្ឈិមបក្ស និងគណៈកម្មាធិការយោធា បានសម្រេច បាន

ស្មើ បានលើកបញ្ហាឡើង គឺត្រូវវាយរំលំសំណង់ចាស់នៅវត្តភ្នំ សព្វថ្ងៃនេះ ហើយរៀបចំសំណង់ប្រាសាទថ្មីជានិមិត្តរូបរបស់កងទ័ព យើងនៅលើវត្តភ្នំនេះ ។ ដូច្នេះ យើងបោះទីតាំងនិមិត្តរូបនៃកងទ័ព បដិវត្តន៍យើងលើកន្លែងខ្ពស់ជាងគេបំផុតនៅរដ្ឋធានីភ្នំពេញនៃ ទូទាំងប្រទេស ។

ដូច្នោះ ជាកន្លែងមួយ ដែលជំនាន់យើងសព្វថ្ងៃនេះ ជាកងទ័ពក្តី ជាប្រជាជនក្តី ជាយុទ្ធជន យុទ្ធនារីក្តី ក្មេង ចាស់ក្តី ទៅគោរពទៅ រៀនសូត្រ ទៅគោរពវិញ្ញាណក្ខន្ធ យុទ្ធមិត្ត យុទ្ធជន យុទ្ធនារី កម្មាភិបាលរបស់យើង ជារៀងរាល់ថ្ងៃបាន ហើយជំនាន់ក្រោយៗ ទៅទៀត ១ជំនាន់ ២ជំនាន់ រាប់សិបជំនាន់តទៅទៀត ក៏នឹងមក រៀនសូត្រ និងគោរពនូវសព គោរពនូវវិញ្ញាណក្ខន្ធ វីរជន វីរបុរស វីរនារីរបស់យើង នៅរដ្ឋធានីនេះដែរ ។ នេះជាការតបស្នងសងគុណ របស់យើងចំពោះកងទ័ពយើង ។ បញ្ហានេះនៅតែពេលវេលានឹង រៀបចំធ្វើឲ្យបានល្អ ។ ខាងផ្នែកគូរ ជាគម្រោង ក៏រៀបចំដើម្បីឆ្លង មជ្ឈិមបក្ស និងគណៈកម្មាធិការយោធា ដើម្បីរៀបចំសង់ជា បណ្តើរៗ ។ រហូតដល់ឥឡូវនេះ យើងមិនទាន់សង់ ពីព្រោះយើងត្រូវ ដោះស្រាយបញ្ហាជាច្រើនជាបន្ទាន់ ដោះស្រាយជីវភាពប្រជាជន ដោះស្រាយការបង្កបង្កើនផល ដោះស្រាយការពារប្រទេសឲ្យមាន សភាពនឹងន ប៉ុន្តែចាប់ពីពេលនេះទៅ យើងរៀបចំដំណើរគម្រោង របស់យើងបានជាបណ្តើរៗ ហើយ ។

ទន្ទឹមនឹងការតបស្នងសងគុណរបស់យើង តាមការកសាង ប្រាសាទជូនកងទ័ពបដិវត្តន៍យើង យើងមានភារកិច្ចមួយទៀត ដើម្បីនឹងតបស្នងសងគុណកងទ័ពយើង គឺយើងទាំងអស់គ្នា នៅក្នុង កងទ័ពក្តី នៅក្រៅកងទ័ពក្តី យើងប្តេជ្ញាដាច់ខាត ចំពោះមុខនៃទង់បក្ស ចំពោះមុខនៃទង់ជាតិ ចំពោះមុខនៃវិញ្ញាណក្ខន្ធរបស់កងទ័ពយើង របស់ប្រជាជនយើង ។ ខ្ញុំនិយាយថា ចំពោះមុខនៃបក្សយើង និង ទង់បក្សយើង ពីព្រោះទង់បក្ស ជាតំណាងនៃអង្គការដឹកនាំបដិវត្តន៍ យើងជាបន្តបន្ទាប់ រហូតដណ្តើមបានជ័យជម្នះ ។ ជាទង់ប្រយុទ្ធ ជាទង់អង់អាចក្លាហាន រហូតដណ្តើមបានជ័យជម្នះយ៉ាងធំធេង ណាស់ មានលក្ខណៈមហាអស្ចារ្យ នៅក្នុងសកលលោកទាំងមូល ។ យើងគោរពចំពោះមុខនៃទង់បក្ស ។

ខ្ញុំនិយាយថា ចំពោះមុខទង់ជាតិនៃកម្ពុជាប្រជាធិបតេយ្យ ក៏មានន័យដូច្នេះដែរ ។ មិនមែនជាទង់ធម្មតាទេ ។ ទង់យើងដែល មានផ្ទាំងក្រហម ដែលមានសញ្ញាប្រាសាទ ជានិមិត្តរូប ជាប្រពៃណី របស់យើង ទង់នេះដណ្តើមបានឡើង កកើតឡើងដោយសារការ តស៊ូដ៏យូរលង់ណាស់ ។ ដូច្នេះ ជាទង់អង់អាចក្លាហាន ជាទង់ដែល លេចចេញឡើងដោយឈាមស្រស់របស់ប្រជាជនយើង របស់ កងទ័ពយើង ។ ហើយខ្ញុំនិយាយថា យើងប្តេជ្ញាចំពោះវិញ្ញាណក្ខន្ធ របស់ប្រជាជន និងកងទ័ពយើង ពីព្រោះការលះបង់របស់ប្រជាជន យើង ការលះបង់របស់កងទ័ពយើង គឺជ្រាលជ្រៅណាស់ឥតឧបមា ។

ដូច្នោះ ចំពោះមុខនៃទង់បក្ស ចំពោះមុខនៃទង់ជាតិកម្ពុជា ប្រជាធិបតេយ្យ និងចំពោះមុខនៃវិញ្ញាណក្ខន្ធនៃបុព្វបុរសយើង យើងប្តេជ្ញាបន្តប្រពៃណីនៃវីរបុរសយើង ដែលប្រយុទ្ធអង់អាច ក្លាហានកន្លងមក យើងបន្តបំពេញភារកិច្ចបដិវត្តន៍របស់គេទាំង ឡាយឲ្យបានល្អដាច់ខាត បំពេញភារកិច្ចបដិវត្តន៍ ក្នុងរយៈកាលថ្មី គឺភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម និងការពារប្រទេសរបស់យើងឲ្យបានល្អ ។ បើយើងបំពេញភារកិច្ច នេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយយកចិត្តទុកដាក់សម្រេច ឲ្យបានល្អជាអតិបរមានោះសន្មតថា យើងទាំងអស់គ្នាបានតបស្នង សងគុណដល់បុព្វបុរសរបស់យើងបានពេញលេញ ។ នេះជាការ ប្តេជ្ញារបស់យើង ។ យើងប្តេជ្ញានៅពេលនេះ ដើម្បីពង្រឹងពង្រីក ជំហរបដិវត្តន៍យើងថែមទៀត ។ កាលណាយើងទៅធ្វើសកម្មភាព គ្រប់បែបយ៉ាង សកម្មភាពតូច សកម្មភាពធំ ធ្វើការងារបំពេញ ភារកិច្ចតូចក្តី ធំក្តី គឺប្រយុទ្ធ ប្រយុទ្ធដោយយកសេចក្តីប្តេជ្ញានេះ ទៅ ធ្វើជាកម្លាំងជំរុញ យកការប្តេជ្ញានេះចំពោះទង់បក្ស យកការប្តេជ្ញា ចំពោះទង់ជាតិ យកការប្តេជ្ញា ចំពោះវិញ្ញាណក្ខន្ធនៃវីរបុរសរបស់ យើង ជាកម្លាំងជំរុញឲ្យយើងទាំងអស់គ្នាឲ្យកាន់តែខ្លាំងក្លា ។ ខ្លាំង ហើយកាន់តែខ្លាំងថែមទៀត ហើយបើកាលណាមានរវើរវាយ ឬក៏ មានរអាក់រអួល អំពីបញ្ហាអ្វី នីមួយៗ គឺយកការប្តេជ្ញាក្នុងពេលនេះ ដើម្បីពង្រឹងភារកិច្ចរបស់យើងឲ្យកាន់តែល្អថែមទៀត ។ ធ្វើយ៉ាងនេះ យើងបំពេញភារកិច្ចតបស្នងសងគុណដល់វីរបុរសរបស់យើង ជា យុទ្ធជន យុទ្ធនារី ជាកម្មាភិបាលនៃកងទ័ពបដិវត្តន៍យើងដ៏ល្អប្រពៃ ហើយដំណក់ឈាមដែលកងទ័ពបដិវត្តន៍យើងបានលះបង់ទៅ មិនមែន ជាដំណក់ឈាមឥតប្រយោជន៍ ។ ជាដំណក់ឈាម ដែលកើតឡើង

ជាកម្លាំងបដិវត្តន៍ដ៏ខ្លាំងក្លាតទៅទៀត ពីព្រោះដំណក់ឈាមនេះ វាជាកម្លាំងជំរុញបក្សយើង ជំរុញប្រជាជនយើង កាន់តែខ្លាំងក្លាថែមទៀត ក្នុងការបំពេញភារកិច្ចបដិវត្តន៍ក្នុងរយៈកាលថ្មី ។

បំពេញភារកិច្ចបដិវត្តន៍ក្នុងរយៈកាលថ្មី ដើម្បីអ្វី? ដើម្បីកម្ចាត់ជាវៀងរហូតនូវភាពខ្ញុំគេ រាប់សតវត្សរ៍មកហើយ ។ យើងបានរំដោះប្រទេសពីភាពខ្ញុំគេនៅថ្ងៃ១៧ មេសា ១៩៧៥ យើងបានរំដោះប្រជាជនយើងជាស្ថាពរ នៅថ្ងៃ១៧ មេសា ១៩៧៥ ។ ក៏ប៉ុន្តែ តើថារំដោះនេះ ខ្មាំងវាចង់ដណ្តើមប្រទេសយើងយកទៅធ្វើខ្ញុំវាវិញទេ? វាចង់ ។ ខ្មាំងខាងក្រៅប្រទេស ខ្មាំងខាងក្នុងប្រទេស ខ្មាំងជាចក្រពត្តិ ខ្មាំងគ្រប់ប្រភេទផ្សេងទៀត ។ ខ្មាំងវណ្ណៈជិះជាន់ផ្សេងៗ វាធ្វើសកម្មភាពដើម្បីនឹងយកប្រទេសយើងធ្វើជាខ្ញុំវាតទៅទៀត យកប្រជាជនយើង កម្មករ កសិករ ធ្វើជាខ្ញុំវាតទៅទៀត ។ ដូច្នេះ យើងបំពេញភារកិច្ចរបស់យើង ឲ្យបានល្អតទៅទៀតដើម្បីអ្វី?

ដើម្បីក្នុងរយៈដប់ឆ្នាំ ក្នុងរយៈមួយរយឆ្នាំ ក្នុងរយៈមួយពាន់ឆ្នាំ ក្នុងរយៈមួយម៉ឺនឆ្នាំ ក្នុងរយៈមួយសែនឆ្នាំ ការពារកម្ពុជាប្រជាធិបតេយ្យ ការពារកម្មករ កសិករសមូហភាពកម្ពុជាយើងបានវៀងរហូត ។ បើបំពេញភារកិច្ចបានយ៉ាងនេះ ខ្មាំងខាងក្រៅក៏មកដណ្តើមទឹកដីកម្ពុជាប្រជាធិបតេយ្យមិនបានដណ្តើមយកកម្មករ កសិករ ធ្វើជាខ្ញុំវាមិនបានជាវៀងរហូត ។ នេះជាន័យដែលយើងត្រូវបំពេញភារកិច្ចរបស់យើងឲ្យបានល្អ ។

ទន្ទឹមនឹងនេះ យើងបំពេញភារកិច្ចយើងបានល្អ ដើម្បីកិត្តិយសរបស់ជាតិយើង ដែលរាប់ពាន់ឆ្នាំមកហើយ អាប់ឱនណាស់ ហើយឋិតនៅក្នុងសភាពខ្ញុំគេ ។ នៅក្នុងប្រទេសយើងក៏ខ្ញុំគេ នៅក្រៅប្រទេសក៏យើងខ្ញុំគេ មិនដែលមានមុខមានមាត់ទេ ។ ខ្ញុំគេក្នុងន័យថាប្រទេសខ្ញុំគេ ក្នុងន័យថាប្រជាជនខ្ញុំគេ ។ ឥឡូវយើងបានប្រទេសឯករាជ្យ ប្រជាជនឯករាជ្យ ប្រជាជនកម្មករ កសិករមានសេរីភាព ។ តើជាកិត្តិយសទេ? ជាកិត្តិយស ។ មហាជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ ក៏ជាមហាកិត្តិយសរបស់ប្រជាជាតិយើង របស់ប្រជាជនយើង និងរបស់កងទ័ពយើង ។ កិត្តិយសនេះ យើងត្រូវរក្សាកិត្តិយសនេះ យើងត្រូវពង្រឹងពង្រីកវា កុំឲ្យអាប់ឱនទៅវិញ កុំឲ្យវាបាត់ទៅវិញ ។ បើប្រសិនណាជាខ្មាំងខាងក្រៅ វាមកដណ្តើមរដ្ឋអំណាចរបស់យើងបានវិញ កិត្តិយសនេះវាបាត់ទៅវិញ ។

ដូច្នោះ ការបំពេញភារកិច្ចរបស់យើង ម្យ៉ាងជាការតបស្នងសងគុណចំពោះវីរយុទ្ធជន យុទ្ធនារី កម្មាភិបាលយើងដែលបានពលីកន្លងទៅ ហើយម្យ៉ាងទៀត ដើម្បីការពារកិត្តិយសជាតិ កិត្តិយសប្រជាជនយើងជាវៀងរហូត ។ នេះ ទី១ ដែលខ្ញុំសូមជម្រាបស្តីអំពីការចាប់អារម្មណ៍ក្នុងឱកាសពិធីបុណ្យខួបឆ្នាំទី៩ នេះរបស់កងទ័ពបដិវត្តន៍យើង ។

## ២) អំពីប្រវត្តិសង្ខេបនៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា

នៅឆ្នាំ១៩៧០ នាខែតុលា គណៈកម្មាធិការមជ្ឈិមបក្សបានធ្វើសន្និបាតពេញអង្គជាលើកដំបូង ។ សូមជម្រាបថា ពេញអង្គជាលើកដំបូង ពីព្រោះមុនរដ្ឋប្រហារ យើងជួបជុំគ្នាមិនពេញអង្គប៉ុន្មានទេ ពីព្រោះសមមិត្តម្នាក់ៗ នៅតាមភូមិភាគនីមួយៗ ជួបគ្នាបាន៧០ភាគរយ ៨០ភាគរយ ៩០ភាគរយ មិនដែលបានពេញអង្គទេ ពីព្រោះការទាក់ទងពិបាកណាស់ ។ ខ្លះនៅត្បូងឃ្មុំ ខ្លះនៅបូព៌ា ខ្លះនៅពាយ័ព្យ ខ្លះនៅឧត្តរ ។ ដូច្នោះ ការទាក់ទងគ្នាមានការលំបាក ព្រោះខ្មាំងវាធ្វើសកម្មភាពខ្លាំង ប៉ុន្តែ ដល់ឆ្នាំ១៩៧០ នៅខែតុលា យើងបានជួបជុំគ្នាជាលើកដំបូង ដើម្បីរៀបចំយុទ្ធសាស្ត្រ និងយុទ្ធវិធីវាយចក្រពត្តិអាមេរិក និងពួកបរិវារវា ដែលមានអាណុល ជាមេខ្លោង ។ ពេលនោះ យើងបានសម្រេចវិធានការជាច្រើន ជាប្រវត្តិសាស្ត្រ ដែលខ្ញុំបានជម្រាបពីមុនមក ជាបន្តបន្ទាប់ហើយ ។ ក្នុងពេលសន្និបាតលើកនោះ មជ្ឈិមបក្សកំណត់ថា ឈរលើសភាពការណ៍ខ្មាំងនិងយើង យើងមានប្រៀបជាងខ្មាំងខាងនយោបាយ ហើយយើងកាន់តែមានប្រៀបជាងខ្មាំងថែមទៀត ។ យើងមានលទ្ធភាពឈ្នះ ទាំងស្រុង ក្នុងរយៈ៤ ឬ៥ឆ្នាំ ។ យើងបានកំណត់ពីឆ្នាំ១៩៧០ យ៉ាងនេះ ។ បញ្ហានេះ ខ្ញុំបានជម្រាបម្តងជាពីរដងហើយ ។ យើងខំអនុវត្តសេចក្តីសម្រេចចិត្តរបស់មជ្ឈិមបក្សនៅខែតុលា ឆ្នាំ១៩៧០នេះ ដើម្បីឲ្យឈ្នះក្នុង៤ ឬ៥ឆ្នាំ ។ ការសម្រេចរបស់មជ្ឈិមបក្ស ថាឈ្នះក្នុង ៤ ឬ៥ឆ្នាំ គឺជាការពិតជាក់ស្តែង ។ យើងឈ្នះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប្រាំឆ្នាំគត់ ។ ចង់ជម្រាបយ៉ាងនេះ ដើម្បីឲ្យឃើញការប្រជុំលើកនេះ មានលក្ខណៈជាប្រវត្តិសាស្ត្រមួយធំ ។ រៀបចំយុទ្ធសាស្ត្រ និង យុទ្ធវិធី ធ្វើសង្គ្រាមប្រជាជន វាយចក្រពត្តិអាមេរិក និងបរិវារដណ្តើមបានជ័យជម្នះយ៉ាងម៉េច?

ហើយក្នុងពេលនៃសន្និបាតនោះហើយ ដែលគណៈកម្មាធិការមជ្ឈិមបក្ស បានកំណត់បញ្ហាមួយ ជាពិសេសទៀត គឺកំណត់ថាកងទ័ពបដិវត្តន៍យើងកសាងឡើងនៅថ្ងៃ ១៧ មករា ឆ្នាំ១៩៦៨ ។ យើងបានកំណត់យ៉ាងនេះ ។ យ៉ាងដូចម្តេច បានជាមជ្ឈិមបក្សសម្រេចយកថ្ងៃ ១៧ មករា ឆ្នាំ១៩៦៨ ធ្វើជាថ្ងៃនៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាយើង? ខ្ញុំនឹងជម្រាបជាបន្តបន្ទាប់ដូចតទៅនេះ ៈ

ថ្ងៃ១៧ មករា ឆ្នាំ១៩៦៨នេះ ជាថ្ងៃដំបូងបង្អស់ដែលកងការពារសម្ងាត់របស់យើង ប្រែក្លាយទៅជាកងឈ្លបចាត់តាំងជាអង្គភាពមួយ ។ មិនច្រើនទេ ៤-១០-២០ នាក់ នៅភូមិភាគពាយ័ព្យ ខាងបាត់ដំបង ។ ចាត់តាំងជាកងឈ្លបនេះឡើង បំពាក់អាវុធដែលមានក្នុងដៃ ទៅវាយទីតាំងខ្មាំងមួយជាដំបូងដៃបង្អស់ នៅទូទាំងប្រទេស ។ ផ្ទុះអាវុធមុនគេបង្អស់នៅថ្ងៃ១៧ មករា ឆ្នាំ១៩៦៨ នេះ វាយទីតាំងខ្មាំងមួយនៅភូមិបាយដំរាម ។ ខ្ញុំសូមជម្រាបថា ភូមិបាយដំរាមនេះ នៅតាមដងស្ទឹងសង្កែ ។ នៅបាត់ដំបងមានស្ទឹងមួយហៅស្ទឹងបាត់ដំបង ឬ ស្ទឹងសង្កែ ។ នៅខាងលើទីក្រុងបាត់ដំបង ចម្ងាយប្រហែល១០ ទៅ១១ គីឡូម៉ែត្រ មានភូមិមួយហៅថាភូមិបាយដំរាម ។ ដូច្នេះ ១១គីឡូម៉ែត្រពីក្រុងបាត់ដំបង ។ កងឈ្លបរបស់យើងមកវាយទីតាំងនេះ វាយកម្ទេចទីតាំងនេះ ហើយដណ្តើមអាវុធពីខ្មាំងបំពាក់ឲ្យខ្លួន ។ ជាស្នូរកាំភ្លើងមុនគេបង្អស់ បើកឆាកនៃសង្គ្រាមបដិវត្តន៍ប្រឆាំងនឹងពួកប្រតិកិរិយា បរិវារចក្រពត្តិនៅកម្ពុជាយើង ។ តាំងពីពេលនោះមក សង្គ្រាមផ្ទុះឡើងទូទាំងប្រទេស គឺខែមករា ឆ្នាំ១៩៦៨នេះ ផ្ទុះនៅបាត់ដំបង ដូចបានជម្រាបនៅបាយដំរាម ។ ខែ២ ផ្ទុះនៅនិរតី ខែ៣ ផ្ទុះនៅខាងបូព៌ា ផ្ទុះនៅខាងឦសាន ផ្ទុះនៅខាងឧត្តរ ផ្ទុះទូទាំងប្រទេសដែលយើងហៅថា សង្គ្រាមផ្ទៃក្នុងឆ្នាំ១៩៦៨-៦៩ មកទល់នឹងរដ្ឋប្រហារខែ៣ ឆ្នាំ១៩៧០នេះ ។ ដូច្នោះ ផ្ទុះមុនគេនេះ ផ្ទុះនៅថ្ងៃ១៧ មករា ១៩៦៨ នៅភូមិបាយដំរ៉ាម នៅខេត្តបាត់ដំបង ។ យើងយកថ្ងៃជាប្រវត្តិសាស្ត្រនេះ ធ្វើជាថ្ងៃកំណើតនៃកងទ័ពបដិវត្តន៍របស់យើង ។ នេះជាសភាពមួយដែលសូមជម្រាប ។

តទៅនេះ ខ្ញុំសូមជម្រាបថា ការដែលផ្ទុះអាវុធនៅថ្ងៃ១៧ មករា ឆ្នាំ១៩៦៨ មិនមែនជាព្រឹត្តិការណ៍ចៃដន្យទេ ដោយបុគ្គលម្នាក់២នាក់ ៤-១០នាក់ បបួលគ្នា ប្រមូលគ្នាទៅវាយខ្មាំងលេងៗ ទេ ។ ការដែលផ្ទុះអាវុធនៅថ្ងៃ ១៧ មករា ឆ្នាំ១៩៦៨ ហើយបន្តៗមក យើងផ្ទុះអាវុធទូទាំងប្រទេស គឺមកពីការតស៊ូប្រជាជាតិ និងការតស៊ូវណ្ណៈរបស់ប្រជាជនយើង ក្រោមការដឹកនាំរបស់បក្សយើង ដោយអនុវត្តនូវហិង្សាបដិវត្តន៍ ខាងនយោបាយ និងហិង្សាអាវុធ ។ មាគ៌ាជាយុទ្ធសាស្ត្ររបស់បក្ស ដែលបានកំណត់នៅឆ្នាំ១៩៦០ មានកំណត់ថា ត្រូវវាយរំលំចក្រពត្តិនៅប្រទេសកម្ពុជា ពិសេសចក្រពត្តិអាមេរិក ។ ត្រូវវាយរំលំសក្តិភូមិ និងទាយទុនប្រតិកិរិយានៅកម្ពុជា ។ ដើម្បីវាយ លុះត្រាតែកសាងកម្លាំងបដិវត្តន៍របស់ខ្លួនសំខាន់ គឺកសាងកម្លាំងកងទ័ពបដិវត្តន៍របស់ខ្លួន ។ ដើម្បីវាយខ្មាំងសត្រូវ ជាចក្រពត្តិ និងវណ្ណៈជិះជាន់ វាយដៃទទេមិនបានទេ ទាល់តែវាយដោយប្រើហិង្សានយោបាយ វាយដោយប្រើហិង្សាអាវុធ ពីព្រោះខ្មាំងវាមានអាវុធ ។ នេះជាមាគ៌ាត្រឹមត្រូវ ។ បក្សបានកំណត់យ៉ាងនេះ ហើយនៅឆ្នាំ១៩៦១ យើងចាត់តាំងកងការពារសម្ងាត់ ។ នេះជាប្រវត្តិនៃកងទ័ពយើង កងការពារសម្ងាត់នេះបង្កប់នៅតាមភូមិ តាមមូលដ្ឋាន ក៏ដូចជានៅទីក្រុង ។ អ្នកខ្លះមានកាំភ្លើង ក៏ប៉ុន្តែ សំខាន់ យើងបំពាក់អាវុធដោយពូថៅ ដោយផ្កាក់ ដោយដំបង ដោយថ្ម ហៅថាប្រើហិង្សា ។ មានភារកិច្ចការពារកម្មាភិបាល ការពារប្រជាជន វាយកម្ទេចពួកគិញ ពួកខ្មាំងឃោរឃៅ ដែលបំផ្លិចបំផ្លាញប្រជាជន ។ កងការពារសម្ងាត់នេះ មានភារកិច្ចយ៉ាងនេះ ។ សុទ្ធតែយុវជន កម្មករ កសិករ ពលករធម្មតា ។ បើតាមខ្ញុំដឹងមានសមមិត្តជាលេខាកងពលខ្លះដែលនៅទីនេះ ធ្លាប់ធ្វើកងការពារសម្ងាត់ ។ ជានីរសារផង ជាកងការពារសម្ងាត់ផង ជូនកម្មាភិបាលការពារកម្មាភិបាល ។ ឯកសណ្ឋានរបស់កងការពារសម្ងាត់របស់យើងពេលនោះ មានតែខោខ្មៅមួយ ហើយនឹងក្រមាមួយ ហើយក្រៅពីនេះ មានកាំភ្លើង ។ កាំភ្លើងនេះ ជាកាំភ្លើងដែលខ្មាំងវាបំពាក់ប្រជាជន ។ កងការពារសម្ងាត់នេះ បានកកើតឡើងជាបន្តបន្ទាប់ ការពារកម្មាភិបាលយើងបានល្អជាទូទៅ ។ ប៉ុន្តែ កងការពារសម្ងាត់នេះ ក៏ត្រូវគ្រោះថ្នាក់អស់មួយចំនួនដែរ ។ គ្រោះថ្នាក់ច្រើនជាងគេនៅឆ្នាំ១៩៦២ នៅខាងបូព៌ា គឺវាចាប់កងការពារសម្ងាត់ និងកម្មាភិបាលយើងបានមួយចំនួន ។ ឆ្នាំ៦២នេះ ជាស្ថានការណ៍ និងព្រឹត្តិការណ៍ធំមួយ ដែលវាចាប់យើង ។ យុទ្ធជនយើងបំពេញភារកិច្ចពេលនេះ សុទ្ធតែកងការពារសម្ងាត់ ការពារកម្មាភិបាល ការពារកន្លែង

ធ្វើការងារ ការពារកន្លែងធ្វើសន្និបាត នាំសារ គ្រោះថ្នាក់ណាស់ ។ កម្មាភិបាលយើងត្រូវដើរធ្វើការពីភូមិមួយទៅភូមិមួយ ។ កម្មាភិបាលយើង បើគ្មានកងការពារសម្ងាត់ការពារពេលនោះទេ យើងនៅមិនបានទេ ខ្មាំងកម្ទេចអស់ហើយ ប៉ុន្តែកងការពារសម្ងាត់នេះ ក្តាប់សភាពការណ៍ភូមិ ក្តាប់សភាពការណ៍ឃុំ ក្តាប់សភាពការណ៍ទាហានខ្មាំង ក្តាប់សភាពការណ៍ប៉ូលិសខ្មាំង ។ ទាហានលេងបៀយ៉ាងម៉េច ផឹកស្រាយ៉ាងម៉េច ប៉ូលីសលេងបៀយ៉ាងម៉េច ផឹកស្រាយ៉ាងម៉េច ដើរទៅណាមកណា កងការពារសម្ងាត់ក្តាប់ក្រឹត្យក្រមបានទាំងអស់ ។ ខ្មាំងដើរផ្លូវណា មិនដើរផ្លូវណា កងការពារសម្ងាត់ក្តាប់ទាំងអស់ ។ កងការពារសម្ងាត់ជូនផ្លូវ ។ បើកម្មាភិបាលសំខាន់ៗសុទ្ធតែមានអាវុធ ។ អាវុធមកពីណា? គឺអាវុធជីវពល ដែលកងការពារសម្ងាត់ក្តាប់បាន ។ យកអាវុធរបស់ខ្មាំងដើម្បីការពារ ។ បើប្រសិនណាជាខ្មាំងវាឃើញ កងការពារសម្ងាត់យករូបភាពស្របច្បាប់ ថាយាមកាមខ្មាំង ។ ប៉ុន្តែការពិត គឺការពារកម្មាភិបាលយើង ការពារមូលដ្ឋានយើង ឲ្យពង្រឹងពង្រីកខ្លួនបានជាបន្តបន្ទាប់ ។ ដូច្នេះ ភារកិច្ចរបស់កងទ័ពយើង ពេលនោះ ក៏ខ្ពង់ខ្ពស់មែនទែនណាស់ ។ ដូចខ្ញុំជម្រាបអម្បាញ់មិញថា មានតែខោខ្មៅមួយ ហើយនឹងក្រមាមួយ ។ ត្រូវជូនកម្មាភិបាលទៅដល់កន្លែងណាក៏ទៅដែរ ។ នេះជាឧទាហរណ៍ខ្លះ នៃកងការពារសម្ងាត់របស់យើង ។ ស្លាប់រស់ គឺប្រយុទ្ធដាច់ខាត ហើយកាំភ្លើង មានស្អី? គ្មានអ្វីធំជាងអំពៀលហើយនឹងគ្រង់ស៊ីសទេ ។ ជាកាំភ្លើងខ្ពស់ជាងគេបំផុត ។ ប៉ុន្តែ កាលណោះ ក្តាប់កាំភ្លើងបានប៉ុណ្ណេះ គឺពិតជាខ្លាំង ។ ដូច្នោះ កម្មាភិបាលសំខាន់ៗ ដែលដើរធ្វើការងារ មានការកក់ក្តៅនឹងកងការពារសម្ងាត់នេះណាស់ ។ ធានាអះអាងណាស់ ។ ពី១ឆ្នាំ ទៅ១ឆ្នាំ យើងពង្រីកកងការពារសម្ងាត់ជាបន្តបន្ទាប់ ។ ដូច្នោះ ពីឆ្នាំ១៩៦១ មកដល់ឆ្នាំ១៩៦៦ មូលដ្ឋានបដិវត្តន៍ យើងទូទាំងប្រទេស គ្រប់ភូមិភាគសុទ្ធតែមានកងការពារទាំងអស់យ៉ាងតិចមួយពួកបីនាក់ ។ កងការពារសម្ងាត់នេះ ជាស្នូលកងទ័ពរបស់យើងទៅអនាគត ។

នៅឆ្នាំ១៩៦៦ សភាពការណ៍ទំនាស់រវាងបដិវត្តន៍ និងប្រឆាំងបដិវត្តន៍កាន់តែខ្លាំងឡើង ។ ដូច្នោះ មជ្ឈិមបក្សបានសម្រេចថា ស្ថានការណ៍នៅកម្ពុជាវិវត្តមកទំនាស់បដិបក្ខកាន់តែខ្លាំង ទំនាស់ស្លាប់រស់កាន់តែខ្លាំង ស្រួចស្រាវ ។ បក្សត្រូវរៀបចំ ប្រើអាវុធដើម្បីវាយខ្មាំង ។ បើមិនប្រើអាវុធទេ ខ្មាំងកម្ទេចកម្លាំងបដិវត្តន៍បាន ។ ដូច្នេះ យើងលើកមាគ៌ាត្រូវត្រៀមរៀបចំវាយអាវុធ ។ ដើម្បីត្រៀមរៀបចំវាយអាវុធ បក្សកំណត់ថា ត្រូវរៀបចំកងការពារសម្ងាត់ទៅជាកងឈ្លប ។ ដូច្នោះ កងការពារសម្ងាត់របស់យើង ទៅជាកងឈ្លបអស់ហើយ ។ កងការពារសម្ងាត់បានកើតឡើងក្នុងចលានានេះ បានល្អហើយ ។ កងការពារសម្ងាត់ជាប់ប្រជាជន ។ តស៊ូវណ្ណៈ តស៊ូប្រជាជាតិតឹងតែងស្មុគស្មាញ ។ ដូច្នោះ ធ្លាប់ហ៊ឹកហ៊ឺន ។ ដល់ឆ្នាំ១៩៦៧ ផ្ទុះអាវុធនៅបាត់ដំបង ។ តាមចាំ គឺដើមឆ្នាំ៦៧ ។ ផ្ទុះអាវុធនេះ ដោយគ្មានសារាចរណែនាំពីមជ្ឈិមបក្សទេ ។ តែអាវុធមិនទាន់បានរៀបចំគ្រប់ទេ ។ មជ្ឈិមបក្សប្រជុំគ្នាសម្រេចថា ផ្អាកសិន ។ កាលនោះ ផ្ទុះនៅបាត់ដំបង នៅសំឡូត នៅក្រញូង នៅភ្នំវាយចាប តាមផ្លូវពីបាត់ដំបងទៅប៉ៃលិន ។ បក្សយើងឯកភាពគ្នាថាផ្អាកសិន រៀបចំលក្ខណៈសម្បត្តិដើម្បីវាយទូទាំងប្រទេស ។ យ៉ាងម៉េចបានជាយើងផ្អាក ពីព្រោះបើពាយ័ព្យវាយតែម្នាក់ឯង ខ្មាំងវាប្រមូលកម្លាំងធំទៅវាយពាយ័ព្យ ពាយ័ព្យទប់មិនបាន ។ លំបាកខ្លាំង ។ មាគ៌ាវាយរបស់យើងគឺវាយគ្រប់កន្លែង ។ បើវាយអាវុធ សង្គ្រាមប្រជាជនត្រូវផ្ទុះទូទាំងប្រទេស ។ បើសង្គ្រាមប្រជាជនទូទាំងប្រទេសគឺខ្មាំងដកដង្ហើមមិនទាន់ ។ ខ្មាំងមិនដឹងយកកម្លាំងណាទៅវាយឯណាទេ ។ ឈរលើសភាពការណ៍នេះ បក្សឲ្យបាត់ដំបងផ្អាកសិន ។ ផ្អាកដើមឆ្នាំ១៩៦៧ ។ យើងតស៊ូនយោបាយក៏ខ្លាំងដែរ ជំនាន់នោះ ។ ដើមឆ្នាំ១៩៦៨ ថ្ងៃ១៧ មករា យើងផ្ទុះអាវុធជាចាត់តាំង ។ កងការពារសម្ងាត់របស់ពាយ័ព្យវាយទីតាំងខ្មាំងនៅបាយដំរាម ។ ខែ២ នៅនិរតី ធ្វើកុបកម្មទូទាំងភូមិភាគ ។ ភូមិភាគនិរតី បានកាំភ្លើងច្រើនជាងគេ ពីព្រោះធ្វើកុបកម្ម ។ តាមយើងចាំបានរវាង២០០ដើម ។ ២០០ដើម ជំនាន់នោះមិនតិចទេ ។ ខ្លាំងណាស់ ពីព្រោះខុត្តរបានតែ៤ដើម ហើយត្បូងសានបានតែ៧ដើម ។ បូព៌ាខ្ញុំមិនចាំទេ ប្រហែល៨-១០ដើម ពីព្រោះខ្មាំងវាប្រមូលអស់មុន ។ ដូច្នេះ កាំភ្លើងយើងបានតិច ។ ពាយ័ព្យក៏បានតិច ។ ត្បូងសានក៏យកបានតិច ។ បូព៌ាក៏យកបានតិច ។ ឧត្តរក៏យកបានតិច មានតែនិរតី ដែលយកបានច្រើនជាងគេ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ បញ្ហាកំណត់មិនមែនបញ្ហាកាំភ្លើងទេ ។ បញ្ហាកំណត់គឺទាំងអស់គ្នាវាយ ។ ដូចបានជម្រាបអ៊ីចឹង ខែ១ វាយនៅពាយ័ព្យ ខែ២

វាយខាងនិរតី ។ ដូច្នោះ ខ្មាំងប្រមូលកម្លាំងទៅវាយពាយ័ព្យមិនបានដោយនីរតីវាយដែរ ។ ដល់បូព៌ាផ្ទុះទៀត ខ្មាំងត្រូវបំបែកកម្លាំងទៅវាយបូព៌ា ។ ឦសានវាយទៀតត្រូវបំបែកកម្លាំងទៅវាយឦសាន ។ ឧត្តរវាយទៀត ត្រូវបំបែកកម្លាំងទៅវាយឧត្តរ ។ ដល់ខែ៤ ឆ្នាំ១៩៦៨ យើងធ្វើសង្គ្រាមឈ្លបបាន១៧ខេត្ត ក្នុង១៩ខេត្ត ទូទាំងប្រទេសស្ទើរតែទាំងអស់ ។ សង្គ្រាមឈ្លបរាលដាល ១៧ខេត្ត ក្នុង១៩ខេត្តនៃទូទាំងប្រទេស ។ អាវុធយើងមិនច្រើនប៉ុន្មានទេ ប៉ុន្តែយើងវាយទូទាំងប្រទេស យើងធ្វើឲ្យខ្មាំងមានទំនាស់រវាងប្រមូលផ្តុំ និងបំបែកកម្លាំង ។ កងទាហានសំខាន់របស់វាជំនាន់នោះមានជាង៣ម៉ឺននាក់ទេ ។ រួមទាំងតម្រួត កាលនោះគេហៅតម្រួត ហើយនឹងពួកប៉ូលិស កម្លាំងរបស់វាទាំងអស់៦ម៉ឺននាក់ ។ ៦ម៉ឺននាក់ទៅវាយកងឈ្លបរបស់បដិវត្តន៍ទូទាំងប្រទេសយ៉ាងនេះ តើវាយបានឬមិនបាន? ក្នុងសភាពនេះហើយដែលបក្សពិនិត្យថា វាវាយយើងមិនបាន ។ មានតែយើងវាយវា ។ ចង់និយាយថា ថ្ងៃ១៧ មករា ឆ្នាំ១៩៦៨ ដែលយើងកំណត់ជាថ្ងៃនៃការកកើតកងទ័ពបដិវត្តន៍យើងនេះ មិនមែនជាបញ្ហាចៃដន្យទេ មិនមែនបញ្ហាប្រឌិតឡើងទេ ។ វាកកើតឡើងក្នុងចលនាតស៊ូជាបន្តបន្ទាប់មកជាខ្សែសង្វាក់តាមមាគ៌ាជាយុទ្ធសាស្ត្រ យុទ្ធវិធី និងសកម្មភាពរបស់យើង ជាបន្តបន្ទាប់បានកកើតជាកងការពារសម្ងាត់ កងការពារសម្ងាត់ ក្លាយជាកងឈ្លប ឈ្លបនេះបើកឆាកនៅបាត់ដំបង ហើយវាយទូទាំងប្រទេស ធ្វើសង្គ្រាមឈ្លបទូទាំងប្រទេស ខ្មាំងវាទប់អត់បានទេ ។ បើប្រសិនណាជាយើងវាយប្រជុយប្រថានគ្មានផែនការ គ្មានយុទ្ធសាស្ត្រ គ្មានយុទ្ធវិធី ខ្មាំងវា វាយមួយភ្លែតវាវាយបាក់ហើយ ប៉ុន្តែនេះវាវាយយើងមិនបានបាក់ដោយសារអី? ដោយសារយើងរៀបចំជាខ្សែសង្វាក់ ។ នេះសូមបញ្ជាក់ថាកងទ័ពនេះ វាកកើតឡើងដោយមានការរៀបចំច្បាស់លាស់ជាមាគ៌ា ជាយុទ្ធសាស្ត្រ ជាយុទ្ធវិធី មានការចាត់តាំងកងទ័ព តាំងពីសម្ងាត់មក និងការសាកល្បងជាបន្តបន្ទាប់មកបានចេញជាកងទ័ពរហូតមកដល់សព្វថ្ងៃនេះ ។ ដូច្នេះ កងទ័ពយើងដែលចេញពីចលនាគឺខ្លាំងណាស់ ។ ពេលនោះវណ្ណៈកាន់អំណាចនិយាយថា វាយយើងឲ្យលៀនអណ្តាត ។ វារៀបចំយុទ្ធសាស្ត្ររបស់វាយ៉ាងនេះ គឺវាវាយយើងនៅខែប្រាំង១៩៦៨ ប៉ុនប៉ងបង្អត់ទឹក យើងធ្វើឲ្យយើងស្ងួតក លៀនអណ្តាត ។ វាស្មានតែយើងអត់ទឹកផឹក ។ វាទៅយកទីតាំងកន្លែងណាដែលវាថាមានទឹក តែវាមិនស្គាល់ភូមិសាស្ត្រកម្ពុជាដល់យើងទេ វាមិនស្គាល់ទឹកដីកម្ពុជាដល់យើងទេ ពីព្រោះយើងនៅអស់ហើយ ។ ភ្នំយើងនៅអស់ហើយ ។ វាលរាប ស៊ីងបឹងបួ យើងនៅអស់ហើយ ។ ប្រកលួក យើងនៅអស់ហើយ ។ នរណានៅ? ប្រជាជនយើង កងការពារយើង នីរសារយើង កម្មាភិបាល យើងនៅអស់ហើយ ។ ពួកទាហានវាក៏ដោយ ចៅហ្វាយស្រុក ចៅហ្វាយខេត្តវាក៏ដោយ សេនាធិការវាក៏ដោយ អត់ស្គាល់ទេ ។ វាស្គាល់តែភ្នំពេញ វាស្គាល់តែទីរួមខេត្ត ។ វាអត់ស្គាល់ឯណាមានទឹកឯណាគ្មានទឹកទេ ។

យើងបានកំណត់ថា យើងរៀបចំយុទ្ធសាស្ត្រ យុទ្ធវិធី វាយឲ្យវាលៀនអណ្តាតវិញ មិនមែនឲ្យវាវាយយើងលៀនអណ្តាតទេ ហើយដល់ឆ្នាំ៦៩ វាលៀនអណ្តាត ។ ៦៩ វាទៅបើកប្រតិបត្តិការធំនៅរតនគិរី ។ យើងវាយវាលៀនអណ្តាត មិនមែនយើងលៀនអណ្តាតទេគឺយើងវាយវាលៀនអណ្តាត ។

នៅបូព៌ា យើងមិនមែនវាយវាតែនៅម្តុំអន្លង់ក្រឹះ ម្តុំដូនតី ដែលជាមូលដ្ឋានបង្អែករបស់យើងទេ ។ យើងមកវាយវានៅកណ្តាលជ្រៃ នៅក្រែក ។ យុទ្ធវិធីវាយរបស់យើងយ៉ាងនេះ ។ យើងមិនវាយក្នុងឋានៈការពារទេ ។ វាយសម្រុក ។ វាយខាងមុខ បានខ្មាំងវាវាយខាងក្រោយមិនបាន ។ ដើម្បីការពារបាន ទាល់តែវាយសម្រុក ។ ឧទាហរណ៍ដូចជានៅបូព៌ា ដើម្បីការពារដូនតីបាន ការពារអន្លង់ក្រឹះបាន ដែលជាមូលដ្ឋានបង្អែករបស់យើង លុះត្រាតែវាយកន្លែងនោះផង វាយរហូតផ្លូវលេខ៧ ផង ។

ប្រសិនវាយយ៉ាងនេះ ខ្មាំងគ្មានកម្លាំងមកវាយយើងនៅខាងក្រោយទេ ។ វាមកទប់យើងនៅពីខាងមុខ ។ វាឋិតនៅក្នុងសភាពការពារ នៅគ្រប់កន្លែង ។ នៅបូព៌ា នៅនីរតី វាអត់មានពេលទៅបុករុកយើងនៅខាងក្រោយទេ ។ ឦសានក៏ដូច្នោះ នេះជាមាគ៌ាការពារដោយវាយសម្រុក សម្រុកការពារ ។

អាវុធយើងខ្សោយ មនុស្សយើងនៅតិច តែមាគ៌ាសង្គ្រាមឈ្លបរបស់បក្សត្រឹមត្រូវ គឺយើងខ្លាំង ។ អ្នកអនុវត្តមាគ៌ាបក្សបានត្រឹមត្រូវគឺអ្នកដែលបានឆ្លងកាត់ចលនា គឺកងការពារសម្ងាត់ដែលបានលត់ដំក្នុងចលនា ហើយដែលក្តាប់មាគ៌ាសង្គ្រាមឈ្លប

របស់បក្សបានល្អ ។ អ្នកទាំងនេះហើយដែលជាមេឈប ជាស្នូលនៃកងទ័ពរបស់យើងថ្ងៃក្រោយ ។ នេះជាប្រវត្តិនៃកងទ័ព ។ ដូច្នេះ កងទ័ពនេះមិនចេញមកពីបណ្ឌិតសភាយោធាណាទេ គឺចេញពីចលនាតស៊ូបដិវត្តន៍ជាបន្តបន្ទាប់តាំងពីបាតដៃទទេ ។ អ្នកទាំងនេះហើយដែលឯកភាពលើមាគ៌ារបស់បក្ស ក្តាប់មាគ៌ារបស់បក្សបាន ។ អ្នកទាំងនេះហើយដែលអនុវត្តមាគ៌ា ។ ដៃទទេក៏វាយ មានកាំភ្លើងអំពៀលក៏វាយ មានកាំភ្លើងកិបក៏វាយ ។ វាយតាំងពីអីចឹងទៅ កងទ័ពនេះខ្លាំងណាស់ ។ កងទ័ពដែលចេះវាយតែកាំភ្លើងធំសម្បូរបែប កងទ័ពនេះ មិនខ្លាំងទេ ។ កងទ័ពដែលរីកតាំងពីបាតដៃទទេ កកើតពីចលនាបដិវត្តន៍ជាបន្តបន្ទាប់ ពង្រីកខ្លួនជាបន្តបន្ទាប់ កងទ័ពនេះខ្លាំងណាស់ ។ យើងឈ្នះ ១៧ មេសា សកលលោកគេភ្ញាក់ផ្អើលណាស់ ។ ឥឡូវនេះ ក៏មិនទាន់អស់ភ្ញាក់ផ្អើលទេ ។

ដូច្នេះ កងទ័ពយើងខ្លាំងក្លាណាស់ ។ នេះជាប្រវត្តិរបស់កងទ័ពយើង ។ ត្រូវឃើញអនុភាពរបស់កងទ័ពយើង កម្លាំងរបស់កងទ័ពយើង ដើម្បីមានមោទកភាពពីកងទ័ពយើង ពេញចិត្តនឹងកងទ័ពយើង ហើយពង្រឹងពង្រីកថែបំប៉នកងទ័ពរបស់យើងតទៅទៀត ។ បើមិនអីចឹងទេ ឃើញតែកងទ័ពយើងវាអន់ ឃើញតែកងទ័ពយើងខ្សោយ ឃើញតែគេមានកប៉ាល់ហោះ មានកាំភ្លើងធំ មានអី ។ ឃើញតែគេខ្លាំងជាងយើង ។ មិនបានពិនិត្យធាតុពិត និងលទ្ធផលនៃជ័យជម្នះរបស់យើង ។ តើយើងឈ្នះចក្រពត្តិអាមេរិកមានកប៉ាល់ហោះទេ ។ យើងត្រូវចាំ ។ ឆ្នាំនេះក៏ត្រូវចាំ ឆ្នាំក្រោយៗក៏ត្រូវចាំ ឆ្នាំ៨០ក៏ត្រូវចាំ ឆ្នាំ៩០ក៏ត្រូវចាំ ឆ្នាំ២០០០ក៏ចាំ ឆ្នាំ៣០០០ក៏ចាំ គឺយើងឈ្នះចក្រពត្តិអាមេរិក ដែលធំជាងគេនៅក្នុងសកលលោក តើយើងមានកប៉ាល់ហោះទេ? អត់ទេ ។ កប៉ាល់ទឹកក៏គ្មាន ។ រថក្រោះក៏គ្មាន ។ កាំភ្លើងធំ យើងមានជ័យភ័ណ្ឌបន្តិចបន្តួច ។

កងទ័ពនេះ គ្មានកប៉ាល់ហោះ គ្មានរថក្រោះ គ្មានកាំភ្លើងធំគ្រាប់ក៏មិនគ្រប់ទៀត ប៉ុន្តែយើងវាយឈ្នះ ។ ត្រូវចងចាំនូវកាលៈទេសៈនៃមហាជោគជ័យនេះជាបន្តបន្ទាប់ ដើម្បីអ្វី? ដើម្បីឲ្យឃើញអត្តភាព ដែលកងទ័ពនេះខ្លាំង ។ ចំណុចអីដែលខ្លាំងគឺសតិអារម្មណ៍ខ្លាំង នយោបាយខ្លាំង ចាត់តាំងខ្លាំង មាគ៌ាប្រយុទ្ធខ្លាំង មាគ៌ាប្រយុទ្ធត្រឹមត្រូវ ។

តទៅនេះ ខ្ញុំចង់ជម្រាបបញ្ជាក់ទស្សនៈខ្លះថែមទៀត ។ តើម៉េចបានជាយើងមិនយកថ្ងៃខែផ្សេងទៀតជាថ្ងៃខួបកំណើតកងទ័ពរបស់យើង?

បញ្ហានេះក៏ត្រូវបញ្ជាក់ ។ ការពិតខទ្វេសនាមអម្បាញ់មិញច្បាស់លាស់ហើយ ។ តែត្រូវបញ្ជាក់បញ្ហានេះថែមទៀត ដើម្បីឲ្យកាន់តែមានជំនឿអំពីកំណើតនៃកងទ័ពរបស់យើង ។

សូមជម្រាបថា បានជាយើងកំណត់យកថ្ងៃ១៧ មករា ១៩៦៨ ជាថ្ងៃកកើតនៃកងទ័ពបដិវត្តន៍យើង មកពីថ្ងៃនោះ កងទ័ពយើងផ្ទុះអាវុធលើកដំបូង ហើយកងទ័ពនេះ វាកកើតឡើង ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឯកងទ័ពមុនៗ មិនមែនកកើតឡើងក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ហើយវាមិនមែនជាកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជាទេ វាបរាជ័យ ។

ឧទាហរណ៍ ប្រទេសយើងមានប្រវត្តិជាង២០០០ឆ្នាំហើយ ។ ក្នុងប្រវត្តិជាង២០០០ឆ្នាំ នេះ មានរយៈសង្គមដូចតទៅនេះ ៖

សង្គមកម្ពុជាដំបូង ជាសង្គមទាសភាព មានវណ្ណៈ២វណ្ណៈ មួយ គឺម្ចាស់ទាសៈ និងវណ្ណៈមួយទៀត គឺទាសៈ អ្នកខ្ញុំគេ ។ ម្ចាស់ទាសៈ ជិះជាន់គេ ។ ទាសៈត្រូវគេជិះជាន់ បះបោរប្រឆាំងវាយវិញ ។ មានកងទ័ពរបស់ទាសករ វាយម្ចាស់ទាសៈ ។ វាយជាបន្តបន្ទាប់ តែក៏ត្រូវបរាជ័យ ។ កងទ័ពនេះ ត្រូវរលំរលាយ ។ នេះជារយៈមួយ ។

រយៈមួយទៀត គឺសង្គមទាសៈ កសិករ ។ អ្នកជិះជាន់គេគឺម្ចាស់កសិករ ។ ឯអ្នកត្រូវគេជិះជាន់គឺទាសៈ កសិករ ។ អ្នកត្រូវគេជិះជាន់បានចាត់តាំងជាកងទ័ព តស៊ូប្រឆាំងពួកជិះជាន់ តែត្រូវបរាជ័យ ។

រយៈទី៣ គឺសង្គមសក្តិភូមិ មានចែកវណ្ណៈជាពីរ ៖ មួយ សក្តិភូមិម្ចាស់ដី ។ មួយទៀត គឺកសិករ ។ សក្តិភូមិ ម្ចាស់ដី ជិះជាន់កសិករ កសិករចាត់តាំងកម្លាំងទ័ពខ្លួន វាយពួកសក្តិភូមិម្ចាស់ដី ។ តែត្រូវបរាជ័យ ។

រហូតដល់ឆ្នាំ១៨៦៣ ចក្រពត្តិបារាំងចូល ។ តើមានការតស៊ូឬទេ? មានច្រើនណាស់ គឺពោធិ៍កំបោរ អាចារ្យស្វា វិសេសញ៉ូវ ក្រឡាហោមគង់ ។ តែកងទ័ពនេះត្រូវរលំរលាយ បរាជ័យ អត់ឈ្នះបារាំងទេ ។ នេះមកពីគ្មានបក្សដឹកនាំ គ្មានមាគ៌ាត្រឹមត្រូវ ។

**(នៅមានត)**

# សង្ឃផ្សឹកដោយខ្មែរក្រហម

សុ បិ អាយុ៦១ឆ្នាំ ជាអតីតព្រះសង្ឃគង់នៅវត្តគោកខ្ពស់ ក្នុងរបបសាធារណរដ្ឋខ្មែរ លន់ នល់ ។ បិ ត្រូវបានខ្មែរក្រហមបង្ខំឲ្យសឹកក្នុងឆ្នាំ១៩៧៥ ។



សុ បិ ពេលផ្តល់បទសម្ភាសន៍នៅឃុំផ្គាំ ឆ្នាំ២០១១

បិ មានស្រុកកំណើតនៅភូមិយាងវេន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដោយមានឪពុកម្តាយជាកសិករ ។ ម្តាយរបស់គាត់បានស្លាប់ចោលគាត់តាំងពីគាត់នៅតូចម្ល៉េះ ។ បិ មិនបានចូលរៀននៅសាលាដូចក្មេងដទៃទៀតនៅក្នុងភូមិទេ ។ ដូច្នេះហើយពេលចូលដល់វ័យជំទង់ គាត់ចូលបួសជាព្រះសង្ឃនៅវត្តគោកខ្ពស់ (បច្ចុប្បន្នស្ថិតក្នុងភូមិគោកកបិន) ដើម្បីរៀនអក្សរ និងធម៌អាថ៌ ។ បិ បាននិយាយថា ពេលគាត់មកដល់ដំបូង វត្តគោកខ្ពស់មានកុដិពីរខ្នងប៉ុណ្ណោះសម្រាប់ព្រះសង្ឃគង់នៅ ហើយវត្តនេះស្ថិតក្រោមការដឹកនាំរបស់ព្រះចៅអធិការ ប្រាំង លេញ ។

បិ បានបួសរៀននៅវត្តគោកខ្ពស់បានរយៈពេលបីវស្សា ក៏ត្រូវយោធាខ្មែរក្រហមវាយរំដោះបានស្រុកភូមិរបស់គាត់ទាំងមូល ។ ខ្មែរក្រហមបានប្រមូលព្រះសង្ឃពីស្វាយចេក វត្តសីង និងវត្តឧប ប្រមាណ៣០អង្គមកជួបជុំនៅវត្តគោកខ្ពស់ដែលគាត់គង់នៅ ។ បន្ទាប់មក ទើបខ្មែរក្រហមបញ្ជាឲ្យព្រះចៅអធិការ ប្រាំង លេញ ផ្សឹកព្រះសង្ឃទាំងនោះ រួមទាំងព្រះអង្គខ្លួនឯង ដោយពេលនោះគ្មានព្រះសង្ឃអង្គណាហ៊ានតវ៉ានឹងបញ្ជានេះទេ ។ ចាប់តាំងពីពេលនោះមក ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជននៅក្នុងភូមិគោរពប្រណិប័តន៍សាសនាដូចសម័យមុនឡើយ ។

ក្រោយពីផ្សឹកព្រះសង្ឃរួច ខ្មែរក្រហមបានចាត់តាំង បិ ឲ្យចូលទៅក្នុងកងយុវជនបង្កបង្កើនផលនៅក្នុងភូមិ ។ ក្រោយមកទើបអង្គការតែងតាំងគាត់ឲ្យធ្វើជាប្រធានកងតូច គ្រប់គ្រងលើយុវជន ៩០នាក់មកពីភូមិផ្គាំ ភូមិអំពិល និងភូមិយាងវេន ។

នៅឆ្នាំ១៩៧៦ បិ បានដឹកនាំកងយុវជនរបស់គាត់ទៅលើកទំនប់អាងត្រពាំងថ្ម ស្ថិតក្នុងស្រុកភ្នំស្រុក តំបន់៥ ភូមិភាគពាយ័ព្យ រយៈពេលពីរខែ ដោយនៅទីនោះកងរបស់គាត់ទទួលបានរបបបាយបីពេលជាមួយត្រីឆ្អើត ។ ការងាររបស់ បិ ក្រៅពីដឹកនាំកម្លាំងលើកទំនប់ គាត់ត្រូវធ្វើរបាយការណ៍ពីលទ្ធផលការងារប្រចាំថ្ងៃទៅឲ្យប្រធានកងធំទៀត ។

នៅក្នុងឆ្នាំ១៩៧៦ដដែល អង្គការបានដក បិ និងយុវជនមួយចំនួនក្នុងកងរបស់គាត់ពីទំនប់អាងត្រពាំងថ្មឲ្យមកលើកទំនប់ផ្គាំមួយរយៈ ដោយអង្គការបានដំឡើងគាត់ទៅជាប្រធានកងធំ ។ ក្រោយមក អង្គការបានរំសាយកងរបស់ បិ ឲ្យមកច្រូតស្រូវនៅរលួតវិញ ។ នៅទីនោះ អង្គការបានតាមដាន និងតាមចាប់ខ្លួន បិ ព្រោះអង្គការដឹងថា គាត់មានបងប្រុសឈ្មោះ នូ ហាន ធ្វើជាប្រធានភូមិក្នុងសង្គមចាស់ ។ នៅរដូវប្រាំង ឆ្នាំ១៩៧៧ បិ និងបងប្រុសព្រមទាំងប្រជាជនមួយចំនួនដែលអង្គការចោទប្រកាន់ បានរត់គៀសខ្លួនចេញពីភូមិ ។ ប៉ុន្តែបងប្រុសរបស់គាត់ត្រូវបានយោធាខ្មែរក្រហមឈ្មោះ ខន បាញ់សម្លាប់នៅភូមិត្រពាំងស្វាយ ។ ចំណែក បិ បានរត់ទៅលាក់ខ្លួននៅជើងភ្នំខ្ទី ។ ក្រោយមក យោធាខ្មែរក្រហមបានដេញតាមទាន់ បិ រួចហើយបាញ់គាត់បណ្តាលរងរបួស ទើបយោធាទាំងនោះព័ទ្ធចាប់ខ្លួនគាត់ ។ ប៉ុន្តែភ្លាមនោះ គាត់បានយារព្រៃថៅកាប់លើយោធាខ្មែរក្រហមវិញទើបយោធានោះរត់គេចខ្លួនអស់ ។

បិ បានបន្តរស់នៅលាក់ខ្លួនក្នុងព្រៃរហូតដល់រដូវវស្សាទើបគាត់ចូលមកលួចដំឡូងរបស់ប្រជាជនដែលដាំក្នុងភូមិហូប ។ ប៉ុន្តែ

គាត់មិនហ៊ានចូលទៅរស់នៅក្នុងភូមិវិញទេ ។ ក្រោយមក គាត់បានទទួលដំណឹងថា កងទ័ពរដ្ឋកម្ពុជា និងកងទ័ពវៀតណាមបានវាយចូលមកដល់ទីរួមស្រុកស្វាយចេក ទើបគាត់ភៀសខ្លួនទៅទីនោះ ។ កងទ័ពវៀតណាមបានជ្រើសរើស បិ ឲ្យចូលធ្វើជាកងស្វ័យត្រាណ (ឬភាសា វៀតណាម ហៅថា យូកិញ) រួចហើយឲ្យគាត់នាំផ្លូវកងទ័ពរបស់ខ្លួនទៅវាយយោធាខ្មែរក្រហមនៅបុសស្បូវ ស្វាយទីង និងនៅបារាយណ៍ ។ ប៉ុន្តែថ្ងៃមួយ ពេលគាត់រៀបចំហូបបាយជាមួយកងទ័ពវៀតណាម ស្រាប់តែយោធាខ្មែរក្រហមបានចូលមកឡោមព័ទ្ធធ្វើឲ្យកងទ័ពវៀតណាមទាំងអស់រត់ចោលសមរភូមិ ដោយទុកឲ្យគាត់នៅម្នាក់ឯង ។ ដោយមិនដឹងរត់គេចទៅទីណា បិ បានចូលទៅពួនសម្ងំនៅក្នុងគុម្ពឫស្សី ទើបយោធាខ្មែរក្រហមរកគាត់មិនឃើញ ។ កាលនោះ ខ្មែរក្រហមបានដុតបំផ្លាញស្រូវប្រជាជនចោលអស់ជាច្រើន មុនពេលដកកងទ័ពរបស់ខ្លួនចេញពីភូមិ ។

បិ បានចូលមករស់នៅក្នុងភូមិវិញ ហើយរដ្ឋកម្ពុជាក៏បានជ្រើសរើសគាត់ឲ្យធ្វើជាប្រធានកងឈ្លបភូមិ ដើម្បីនាំផ្លូវកងទ័ពទៅពិនិត្យសភាពការណ៍ក្នុងតំបន់ដែលយោធាខ្មែរក្រហមចូលមកលាក់ខ្លួន ឬបោះទីតាំង ដូចជា នៅភូមិតាត្រៃ ព្រោះគាត់ស្គាល់ភូមិសាស្ត្រច្រើន ។

បន្ទាប់មក រដ្ឋកម្ពុជាបានចាត់តាំង បិ ឲ្យធ្វើការងារពង្រឹងមេក្រុម រួចហើយឲ្យធ្វើជាប្រធានសមាគមភូមិទៀត ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ប្រជាជននៅក្នុងភូមិរបស់គាត់នៅតែជួបអសន្តិសុខដដែល ដោយសារតំបន់របស់គាត់ជាតំបន់ប្រទាញប្រទង់រវាងកម្លាំងត្រីភាគី រួមមាន កងទ័ពរដ្ឋកម្ពុជា កងកម្លាំងខ្មែរក្រហម និងកងកម្លាំងប៉ារ៉ា (ឬហៅថា ចលនាតស៊ូមិនមែនកុម្មុយនីស្ត) ដែលទើបបង្កើតក្រោយ ។ កងកម្លាំងទាំងបីក្រុមនោះតែងតែចូលក្នុងតំបន់របស់ បិ រួចហើយបញ្ជា បិ ឲ្យស្វែងរកសម្ភារនិងអាហារសម្រាប់ឧបត្ថម្ភដល់កងទ័ពរបស់ខ្លួន ។ ក្នុងការងារជាប្រធានដឹកនាំប្រជាជន បិ តែងតែងទទួលយកសំណើទាំងនេះដោយមិនប្រកាន់ភាគីខាងណាឡើយ ។ ដោយសារអំពើល្អរបស់ បិ ហើយ ដោយ បិ ធ្លាប់បួស និងរៀនសូត្រធម៌អាថ៌ផង ទើបក្រោយមក ប្រជាជននៅក្នុងភូមិបានជ្រើសគាត់ឲ្យធ្វើជាអាចារ្យភូមិ ដើម្បីប្រជាជនបានគោរពប្រណិប័តន៍សាសនាឡើងវិញ ។ ក្រៅពីការងារសាសនា បិ បានរៃអង្គាស និងយកបច្ច័យដែលប្រជាជនចូលបុណ្យ ទៅជួយដល់ប្រធានភូមិក្នុងការជួសជុលផ្លូវដែលដាច់និងខូចខាតដោយសារសង្គ្រាម ។

បច្ចុប្បន្ន បិ មានកូនទាំងអស់៧នាក់ និងមានប្រពន្ធប្រកបរបរធ្វើស្រែ ។ បិ តែងតែទទួលការស្រឡាញ់ និងរាប់អានពីអ្នកភូមិ ។ បិ បានមានប្រសាសន៍ថា "ដោយសារគាត់ធ្លាប់បួសជាព្រះសង្ឃ ដូច្នេះគាត់មិនចង់បានអ្វីក្រៅតែពីការជួយយកអាសាគ្នា ស្រឡាញ់រាប់អានគ្នា និងរស់នៅក្នុងសុខសន្តិភាពជាមួយគ្នាទេ" ។

**សោម ប៊ុនថន**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ាន ស៊ី ស្នាក់នៅផ្ទះលេខ៤៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសស្វែងរកឈ្មោះ អៀវ ទៀងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅភូមិក្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ពីមុន ទៀងហាវ គឺជាសាស្ត្រាចារ្យរូបវិទ្យា-គីមី នៅវិទ្យាល័យអង្គរ ទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ទៀងហាវ និងភរិយាឈ្មោះ គួច សាយទៀង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញាវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ទៀងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ទៀងហាវ និងភរិយាបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០ ១២ ៩៥៨ ៥៤៦ ឬអ៊ីមែល nhansy04@yahoo.com ។

***សូមអរគុណ!***

# ចិន និងរបប ប៉ុល ពត



គណៈប្រតិភូចិនដឹកនាំដោយ វ៉ាង ដុងស៊ីង (ឆ្វេង) ទស្សនកិច្ចប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ទទួលស្វាគមន៍ និងអមដំណើរពីព្រលានយន្តហោះដោយ ប៉ុល ពត

**(តចប់)**

## ឥទ្ធិពលរបស់ចិននៅតាមមូលដ្ឋាន

របបកម្ពុជាប្រជាធិបតេយ្យបានរក្សាទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសចិនលើការសហការផ្នែកបច្ចេកទេស ទោះបីជាបក្សកុម្មុយនីស្តរបស់រដ្ឋទាំងពីរ ជារឿយៗបានសង្កត់ធ្ងន់លើសុន្ទរកថា និងព្រឹត្តិប័ត្រព័ត៌មានស្តីពីមនោគមវិជ្ជាក៏ដោយ ។ ការនាំឥទ្ធិពលរបស់ចិនចូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺតាមរយៈយោធាក្នុងកម្រិតមូលដ្ឋាន អ្នកបច្ចេកទេសផ្នែកសេដ្ឋកិច្ច ឧស្សាហកម្ម និងទីប្រឹក្សាដែលមាននៅពាសពេញប្រទេសកម្ពុជា ។

ក្នុងឆ្នាំ១៩៧៥ ព្រលានយន្តហោះយោធានៅខេត្តកំពង់ឆ្នាំង ត្រូវបានអនុញ្ញាតឲ្យសាងសង់ ។ នៅខែមិថុនា ឆ្នាំ១៩៧៦ មន្ត្រីចិនបានធ្វើដំណើរពីក្រុងភ្នំពេញទៅខេត្តកំពង់ឆ្នាំងដើម្បីពិនិត្យមើលការធ្វើតេស្តហោះហើរ ។ របាយការណ៍យោធាខ្មែរក្រហមបង្ហាញថា នៅខែសីហា ឆ្នាំ១៩៧៦ អ្នកប្រឹក្សាបច្ចេកទេសមកពីរដ្ឋាភិបាលចិន បានផ្តល់ការប្រឹក្សាយោបល់ និងការបណ្តុះបណ្តាលដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាស្តីពីរបៀបសាងសង់ព្រលានយន្តហោះ ។ មនុស្សប្រហែលមួយម៉ឺននាក់ត្រូវបានជឿថាបានធ្វើការងារដោយកម្លាំងពលកម្មនៅតំបន់នោះ ហើយមនុស្សជាច្រើនបានស្លាប់ ។ ព្រលានយន្តហោះដែលមិនទាន់សាងសង់រួចនោះ គឺជាទីតាំងមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មដែលស្ថិតក្រោមការស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅឆ្នាំ២០១១ អតីតយោធាខ្មែរក្រហមម្នាក់បាននិយាយថា យោធាដែលមិនពេញចិត្តទៅនឹងបដិវត្តន៍ ត្រូវបានបង្ខំឲ្យធ្វើការមុនពេលដែលត្រូវបានសម្លាប់នៅព្រលានយន្តហោះ ។ អតីតយោធាខ្មែរក្រហមរូបនេះបានបន្ថែមទៀតថា “មិនមានឯកសារដែលនិយាយថាតើមានមនុស្សប៉ុន្មាននាក់បានស្លាប់ ប៉ុន្តែខ្មែរក្រហមគឺជាមនុស្សឃោរឃៅហើយនាំយោធាមកទីនេះដើម្បីធ្វើការងារហើយសម្លាប់ចោល ។ ខ្មែរក្រហមបានចាប់ចងជនរងគ្រោះ

ទាំងអស់គ្នា ហើយបន្ទាប់មកដឹកតាមរថយន្ត ។ អតីតយោធាម្នាក់ទៀតនៅកងពលធំលេខ៣១០ ឡេង គីម រាយការណ៍ថា អ្នកបច្ចេកទេសនិងអ្នកប្រឹក្សាចិនរាប់រយនាក់បានមកជួយកសាងព្រលានយន្តហោះ និងរៀបចំយោធាផ្សេងៗ ។ មិនមានការបញ្ជាក់ច្បាស់លាស់ទេថា អ្នកបច្ចេកទេសជនជាតិចិននិងអ្នកប្រឹក្សាយោបល់បានឃើញការកាប់សម្លាប់ដោយផ្ទាល់ ។

ចិនបានចូលរួមចំណែកដល់ការកសាងកំពង់ផែខេត្តកំពង់សោមដល់របបកម្ពុជាប្រជាធិបតេយ្យ ដែលជាតំបន់ដ៏សំខាន់សម្រាប់ការធ្វើជំនួញទ្វេភាគីនិងការសហការផ្នែកយោធា ។ ក្នុងរបាយការណ៍ខែសីហា ឆ្នាំ១៩៧៦ ប៉ុល ពត បានផ្តល់ដំបូន្មានដល់កងកម្លាំងប្រដាប់អាវុធដើម្បីផ្តល់ការប្រឹក្សាយោបល់ដល់អ្នកបច្ចេកទេសជនជាតិចិនលើការងារប្រចាំថ្ងៃ ដូចជា ប្រភេទប្រេងសាំងដែលប្រើសម្រាប់ទូកល្បាតធម្មតា ដែលរឹបអូសបាននៅក្នុងសង្គ្រាម ។ របាយការណ៍ពីខែកញ្ញា ឆ្នាំ១៩៧៦បង្ហាញថា អ្នកប្រឹក្សាយោបល់ចិនបានបណ្តុះបណ្តាលខ្មែរក្រហមស្តីពីរបៀបប្រើកាំភ្លើងប្រឆាំងរថក្រោះ និងយន្តហោះ របៀបរក្សាកាំភ្លើងធំនិងសម្ភារយោធា និងរថយន្ត ។ ប្រទេសចិនបានផ្គត់ផ្គង់គ្រឿងបន្លាស់សម្រាប់កប៉ាល់ចម្បាំងតូចដែលមានទីតាំងនៅកំពង់សោម ។ ក្នុងឆ្នាំ១៩៧៧ យោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅខេត្តកំពង់សោមត្រូវបានបណ្តុះបណ្តាលដោយអ្នកប្រឹក្សាយោធាជនជាតិចិន ហើយបានសិក្សាអំពីរបៀបប្រើនាវាចិនដែលបានបញ្ជូនទៅឲ្យរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងឆ្នាំ១៩៧៨ អ្នកប្រឹក្សាយោបល់ចិនបានចាត់ចែងកម្ពុជាឲ្យកសាងកំពង់ផែថ្មី ។ ទូកជាច្រើនបានមកដល់ប្រទេសកម្ពុជាដោយមានសម្ភារយោធារួមមានរថក្រោះ កាំភ្លើងធំ និងកាំភ្លើងតូច ។ យោងទៅតាមអតីតយោធាក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចណាស់កម្មករចិន ១០០នាក់ បានឈរជើងនៅកំពង់ផែ ។

អ្នកប្រឹក្សាចិន ត្រូវបានបញ្ជូនទៅតាមអង្គភាពយោធាទាំងអស់ ។ មៃ អឿន ដែលជាអតីតមេបញ្ជាការកងវរសេនាតូចនៅក្នុងកងវរសេនាធំលេខ២៧០ នៅក្នុងខេត្តតាកែវ បានពន្យល់ថា



ជំនាញការចិន និងកម្មាភិបាលខ្មែរក្រហមនៅការដ្ឋានរោងចក្រមួយក្នុងរបបខ្មែរក្រហម

គាត់និងទាហានរបស់គាត់ត្រូវបានបណ្តុះបណ្តាលនិងណែនាំដោយអ្នកប្រឹក្សាចិនប្រហែលម្ភៃនាក់ ចន្លោះឆ្នាំ១៩៧៦-១៩៧៨ ។ អ្នកបច្ចេកទេសចិនបានផ្តល់ការណែនាំដល់ការប្រើប្រាស់អាវុធ ហើយពេទ្យទាហានចិនបានជួយយោធាខ្មែរក្រហមដែលរងគ្រោះ ។ ទោះបីជាទីប្រឹក្សាចិននៅតែឈរជើងនៅតាមមូលដ្ឋានហើយមិនត្រូវបានបញ្ជាឲ្យមានការអនុវត្តគោលនយោបាយនៅតាមមូលដ្ឋានក៏ដោយ ក៏យោធាខ្មែរក្រហមជាច្រើនចងចាំថា «យើងមានកាតព្វកិច្ចស្តាប់ទីប្រឹក្សា ។ ទីប្រឹក្សាគឺជាមន្ត្រីដែលមានឋានៈខ្ពស់ ហើយបានមកប្រទេសកម្ពុជាដើម្បីជួយយើង» ។ មៃ អឿន បានបន្ថែមថា កម្មាភិបាលយោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែងតែអនុវត្តតាមដំបូន្មានរបស់ទីប្រឹក្សា ទន្ទឹមពេលដែលអតីតកម្មាភិបាលរូបនេះអះអាងថា អ្នកប្រឹក្សាយោបល់ចិនមិនដែលផ្តល់យោបល់ដល់យោធាក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងការវាយប្រហារទេ ។ មិនមានភ័ស្តុតាងណាមួយជំរុញឲ្យមានការដាក់កំហិតដោយសម្អាងលើច្បាប់មនុស្សធម៌អន្តរជាតិឬសិទ្ធិមនុស្សនោះឡើយ ។ ប៉ែន យៀវនិន បានបង្ហាញភ័ស្តុតាងដែលអ្នកប្រឹក្សាយោបល់បច្ចេកទេសចិនបានចូលរួមណែនាំឲ្យមានការប្រើប្រាស់កម្លាំងយោធាក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅតាមព្រំដែន ។

វិធីសាស្ត្រផ្សេងទៀតនៃការផ្គត់ផ្គង់ផ្នែកយោធាក៏ត្រូវបានបង្ហាញក្នុងឯកសាររបស់ខ្មែរក្រហមដែរ ។ អ្នកប្រឹក្សាបច្ចេកទេសចិនបានជួយកសាងរោងចក្រដែលផ្គត់ផ្គង់សម្ភារយោធា ព្រលានយន្តហោះ និងកំពង់ផែយោធា ។ វាមិនច្បាស់សោះដែលថាចិនបានរួមចំណែកដល់ការបង្កើតឧបករណ៍សម្រាប់ការពារសន្តិសុខផ្ទៃក្នុងរបស់ខ្មែរក្រហម ។ ដេវីដ ឆេនដល័រ បានលើកឡើងជាយោបល់ថា មន្ទីរឃុំឃាំងនិងជំរំលត់ដំរបស់ចិន ទំនងជាគំរូសម្រាប់ប្រទេសកម្ពុជា ហើយ ស្ទីវ ហេដ័រ បាននិយាយថា មានភ័ស្តុតាងមួយចំនួនស្តីពីការបណ្តុះបណ្តាលផ្នែកយោធារបស់ចិនដល់ខ្មែរក្រហមដែលធ្វើការនៅគុកទួលស្លែង ។ ទោះបីជាយ៉ាងណាក៏ដោយ ភ័ស្តុតាងដែលភ្ជាប់ប្រទេសចិនទៅនឹងការគ្រប់គ្រងសន្តិសុខផ្ទៃក្នុង មិនមែនជាភ័ស្តុតាងដោយផ្ទាល់នោះឡើយ ហើយមិនមានភ័ស្តុតាងដែលគួរឲ្យចាប់អារម្មណ៍ត្រូវបានបង្ហាញតាមរយៈការជំនុំជម្រះក្តី ឌុច ដែលជាប្រធានគុកទួលស្លែងដែរ ។ ពិតប្រាកដណាស់ សេចក្តីសម្រេចប្រឆាំងនឹង ឌុច បានកត់សម្គាល់ថា ជនជាតិចិនក៏ស្ថិតក្នុងចំណោមអ្នកទោសដែលបានស្លាប់ឬត្រូវបានសម្លាប់នៅទួលស្លែងដែរ ។ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានបែងចែករវាងតម្រូវការជំនួយរបស់ចិនក្នុងការតស៊ូប្រឆាំងទៅនឹងសត្រូវស៊ីរូងផ្ទៃក្នុងនិងសត្រូវខាងក្រៅ ដែលជាសញ្ញាមួយក្នុងការភ័យខ្លាចឥទ្ធិពលបរទេស ។ នៅខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមរបស់របបកម្ពុជាប្រជាធិបតេយ្យបានសម្រេចថា ខ្លួនត្រូវការជំនួយផ្នែកយោធារបស់ចិនដើម្បីការពាររដ្ឋប្រឆាំងទៅនឹងវៀតណាម ប៉ុន្តែសម្រាប់សន្តិសុខផ្ទៃក្នុង ក្នុងរង្វង់ប្រទេសកម្ពុជា យើងអាចសម្រេចផែនការនេះបាន ។

អ្នកប្រឹក្សាយោបល់ចិនបានចូលរួមការរៀបចំរោងចក្រនិងគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅជុំវិញប្រទេសកម្ពុជា ។ ក្នុងឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជានិងស្ថានទូតចិន បានពិភាក្សាអំពីសហប្រតិបត្តិការលើការសាងសង់ព្រលានយន្តហោះ និងកំពង់ផែយោធា និងរោងចក្រ៤០កន្លែង រួមមាន រោងចក្រផលិតសម្ភារយោធា ឧស្សាហកម្ម និងរោងចក្រដទៃទៀត ។ បក្សកុម្មុយនីស្តកម្ពុជាបានស្នើសុំជំនួយបច្ចេកទេសពីចិនដើម្បីផ្គត់ផ្គង់រោងចក្រផលិតអាវុធ រោងចក្រផលិតគ្រាប់ តំបន់ផលិតដែក ឃ្លាំងអាវុធ អាកាសយានដ្ឋាន កំពង់ផែ រោងចក្រផលិតក្រដាស និងរោងចក្រផលិតជ័រកៅស៊ូ ។

ដូចគ្នានេះ ចិនបានផ្តល់ការចង្អុលបង្ហាញផ្នែកបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម ។ ក្នុងឆ្នាំ២០១២ អតីតអនុប្រធានគ្រប់គ្រងធនាគារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហមដោយបរិយាយពីរបៀបដែលចិនបានជួយផ្តល់មូលនិធិ បង្កើតធនាគារ និងបណ្តុះបណ្តាលកម្មាភិបាលខ្មែរឲ្យសម្របសម្រួលទំនាក់ទំនងផ្នែកពាណិជ្ជកម្ម ។ រីឯផលិតផលនៅរោងចក្រ កម្ពុជាត្រូវបានដឹកជញ្ជូនទៅប្រទេសចិនជាថ្នូរទៅនឹងគ្រឿងចក្រ និងការនាំចូលរបស់សាធារណរដ្ឋប្រជាមានិតចិនមកកាន់របបកម្ពុជាប្រជាធិបតេយ្យ ។ មានការបញ្ជាក់មួយចំនួនដែលកម្មាភិបាលខ្មែរក្រហមបានទប់ស្កាត់ការព្រួយបារម្ភអំពីការពឹងផ្អែកលើសេដ្ឋកិច្ច ។ ឧទាហរណ៍ នៅពេលដែលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាពិភាក្សាអំពីការសាងសង់រោងចក្រ កម្មាភិបាល



ហ្សេន ជា (ឆ្វេង) ប្រធានគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិរបស់បក្សកុម្មុយនីស្តចិន ពេលមកដល់ប្រទេសកម្ពុជា អមដំណើរដោយប្រធានទីប្រឹក្សាចិន (ស្តាំបង្អស់) ។ ទីបីរាប់ពីខាងស្តាំ សមមិត្តនារី ស៊ា អ្នកបកប្រែភាសាខ្មែរ-ចិន ។

ទាំងនោះបានលើកឡើងថា ប្រជាជនកម្ពុជាអាចសម្រេចគម្រោងហួសពីការព្យាករណ៍ និងការប៉ាន់ស្មាន ។ ខ្មែរក្រហមបានស្នើថា ការងារជាបន្តបន្ទាប់ គួរតែទុកឲ្យខាងកម្ពុជាទទួលខុសត្រូវ ហើយបានបន្ថែមថា "សម្រាប់សម្ភារដែលត្រូវដឹកជញ្ជូនពីប្រទេសចិន ដើម្បីប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា សូមបញ្ជូនសម្ភារទាំងនោះទៅប្រទេសកម្ពុជា" ។ កិច្ចព្រមព្រៀងនោះបានលើកឡើងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចង់បានជំនួយ និងតំបូន្មានពីចិន ប៉ុន្តែបន្តឲ្យតម្លៃដល់ស្វ័យភាព ។

ក្រៅពីការផ្តល់ប្រឹក្សាយោបល់ដល់ធនាគារ និងហិរញ្ញវត្ថុ អ្នកប្រឹក្សាយោបល់ចិន បានធ្វើការនៅតាមការដ្ឋាន ។ ឧទាហរណ៍ អ្នកប្រឹក្សាយោបល់ជនជាតិចិនជាច្រើនត្រូវបានរាយការណ៍ថា បានទៅមើលគម្រោងសាងសង់ប្រឡាយ និងទំនប់អាងត្រពាំងថ្មនៅភាគពាយ័ព្យប្រទេសកម្ពុជា ជាទីដែលពលករបានស្លាប់ ជួនកាលត្រូវក្រុមកងចល័តសម្លាប់ ។ អតីតកម្មាភិបាលខ្មែរក្រហមរូបនេះបានបញ្ជាក់ទៀតថា អ្នកប្រឹក្សាយោបល់ចិនបានធ្វើដំណើរទៅពិនិត្យមើលរោងចក្រផលិតជ័រកៅស៊ូនៅខេត្តកំពង់ចាម ហើយជនជាតិចិនជាច្រើនបានធ្វើការជាមួយនិងបានជួយចាត់ចែងប្រជាជនកម្ពុជានៅតាមមូលដ្ឋាន ។ អ្នករួចរស់ជីវិតពីរបបខ្មែរក្រហមម្នាក់បានចងចាំថា អ្នកប្រឹក្សាយោបល់ចិនប្រហែលជាម្ភៃនាក់បានមកធ្វើទស្សនកិច្ចហើយបានឃើញជាទៀងទាត់នៅក្រុងតាខ្មៅ ។ គ្រប់តំបន់ការដ្ឋានទាំងអស់មានទីតាំងរណ្តៅដែលខ្មែរក្រហមសម្លាប់មនុស្ស ទោះបីជាវាមិនច្បាស់ថាតើមន្ត្រីចិនបានឃើញការសម្លាប់ក្រៅប្រព័ន្ធនោះដែរឬយ៉ាងណា?

អតីតកម្មាភិបាលខ្មែរក្រហមដដែលលើកឡើងថា ជនជាតិចិន មានឥទ្ធិពលយ៉ាងខ្លាំងយ៉ាងហោចណាស់ក្នុងវង្វង់នៃតួនាទីជាអ្នកប្រឹក្សាផ្នែកបច្ចេកទេស ។ នៅឯរោងចក្រក្រជាសក្នុងទីក្រុងភ្នំពេញ អតីតកម្មាភិបាលម្នាក់ទៀតបាននិយាយថា អ្នកប្រឹក្សាយោបល់ចិនជាច្រើនត្រូវបានគោរពគ្រប់ទង្វើទាំងអស់ ។ ជាពិសេស គាត់បានអះអាងថា នរណាម្នាក់ដែលមិនគោរពទីប្រឹក្សាចិន អ្នកនោះនឹងត្រូវបញ្ជូនទៅទួលស្លែងដែលជាកន្លែងធ្វើទារុណកម្ម

និងការកាប់សម្លាប់ ។ នៅរោងចក្រផលិតជ័រកៅស៊ូក្នុងខេត្តកណ្តាល កម្មាភិបាលខ្មែរក្រហមម្នាក់ត្រូវបានមេរបស់ខ្លួនប្រាប់ឲ្យគោរពទីប្រឹក្សាចិនពីព្រោះ ប្រសិនបើយើងចង់បានការគាំទ្រពីចិន យើងត្រូវតែគោរពអ្វីដែលទីប្រឹក្សានោះបាននិយាយ ។ កម្មាភិបាលដដែលនោះរាយការណ៍ថា មន្ត្រីចិនបានផ្តល់សុន្ទរកថាដោយគូសបញ្ជាក់អំពីបទពិសោធរបស់ចិនក្នុងការកសាងប្រទេសរបស់ខ្លួននៅមហាសន្និបាតបក្សប្រចាំឆ្នាំដែលធ្វើឡើងទូទាំងប្រទេសដើម្បីរំឭកខួបថ្ងៃទី១៧ ខែមេសា ។ គ្រប់សន្និបាតទាំងអស់មានកម្មាភិបាលខ្មែរក្រហម និងសមាជិកដែលមានតំណែងខ្ពស់ជាច្រើននាក់បានចូលរួម ។ វាគ្មិនជនជាតិចិនបានប្រើប្រាស់ឱកាសនោះដើម្បីផ្តល់ជាអនុសាសន៍លើគោលនយោបាយសប្បុរសដល់របបកម្ពុជាប្រជាធិបតេយ្យនោះឡើយ ។ គោលនយោបាយថ្នាក់ក្រោមបានឆ្លុះបញ្ចាំងអំពីយុទ្ធសាស្ត្រថ្នាក់លើរបស់សាធារណរដ្ឋប្រជាមានិតចិន ។

អេនឌ្រូ មាថា បានបង្ហាញថា តាមរយៈបទសម្ភាសជាមួយអតីតបុគ្គលិកជនជាតិចិន ដែលឈរជើងនៅក្នុងប្រទេសកម្ពុជា បុគ្គលិកជនជាតិចិនជាទូទៅមានការប្រាស្រ័យទាក់ទងតិចតួចជាមួយនឹងប្រជាជនក្នុងតំបន់ ក្រៅពីការប្រាស្រ័យទាក់ទងលើជំនាញ ។ បទពិសោធនរបស់ជនជាតិចិនទាំងនោះគឺជាមិត្តភាពពោរពេញទៅដោយភាតរភាពប្តូការណែនាំពីជំនាញតិចជាងការមាក់ងាយដល់ភាពអសមត្ថភាពលើផ្នែកបច្ចេកទេសរបស់សមភាគីខ្មែរក្រហម និងការខកចិត្តលើការិយាធិបតេយ្យដែលមិនមានប្រសិទ្ធភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលអ្នកប្រឹក្សាយោបល់ចិនទាំងនោះបានយល់ដឹងអំពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរអ្នកប្រឹក្សាមួយចំនួនបានទទួលស្គាល់ថា ខ្លួនមានការប្រឆាំងខាងផ្លូវសីលធម៌ ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកដែលត្រូវបានសម្ភាសបានគូសបញ្ជាក់ថា វាអាចនឹងជាការលំបាកសម្រាប់ចិនដែលត្រូវទប់ស្កាត់ការបង្ហូរឈាម ហើយវានឹងមិនអាចទៅរួចទេ ។ បទពិសោធផ្ទាល់របស់ចិនអំឡុងបដិវត្តន៍វប្បធម៌ បានផ្តល់ការក្រើនរំឭកថា វាជា



កម្មាភិបាលជាន់ខ្ពស់ចិន និងកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមក្នុងខែតុលា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជា ៖ ពីឆ្វេងទៅស្តាំ សមមិត្ត ស៊ូ អ្នកបកប្រែភាសាខ្មែរ-ចិន, ឧត្តមសេនីយ៍ វ៉ាង សាងវ៉ុង របស់កងទ័ពចិន, សុន សេន, ខៀវ សំផន, សមមិត្ត ភូ អគ្គរដ្ឋទូតចិនប្រចាំនៅប្រទេសថៃ, អៀង សារី និងសមមិត្ត លី មន្ត្រីក្រសួងការបរទេសចិន ។



ម៉ៅ សេទុង (ឆ្វេង) ចាប់ដៃជាមួយ អៀង សារី និង ប៉ុល ពត (កណ្តាល)

ការគ្រោះថ្នាក់ដែលត្រូវសាកល្បងបដិវត្តន៍បែបនេះ ។ ប្រសិនបើការផ្លាស់ប្តូរក្នុងទំនាក់ទំនងរវាងចិន និងរបបកម្ពុជាប្រជាធិបតេយ្យកើតឡើង ការផ្លាស់ប្តូរនោះនឹងចាំបាច់ត្រូវតែកើតឡើងនៅថ្នាក់កំពូល ។

## ការបន្តថ្មីបើមានការបាត់បង់មនោគមវិជ្ជា

ការស្លាប់របស់ ម៉ៅ សេទុង នៅដើមខែកញ្ញា ឆ្នាំ១៩៧៦ និងការចាប់ខ្លួនក្រុមពួកទាំងបួនបានធ្វើឲ្យគោលនយោបាយចិនកាន់តែស្តែងឡើង និងបង្កើតនូវភាពមន្ទិលសង្ស័យដល់ខ្មែរក្រហមអំពីអនាគតនៃជំនួយរបស់ចិន ដោយសារចលនារបស់ខ្មែរក្រហមដូចគ្នាទៅនឹងនយោបាយរបស់ ម៉ៅ ។ យោងទៅតាមកំណត់ត្រានៃអង្គប្រជុំថ្ងៃទី១៦ ខែកញ្ញា របស់កម្មាភិបាលយោធាជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំពិធីដើម្បីរំឭកដល់ ម៉ៅ សេទុង ទន្ទឹមពេលដែលខ្លួនបានគូសបញ្ជាក់អំពីតម្រូវការដើម្បីធ្វើឲ្យមានតុល្យភាពលើការពឹងផ្អែកលើខ្លួនឯងទៅនឹងតម្រូវការសម្រាប់ការការពារអំណាច ។ បក្សកុម្មុយនីស្តកម្ពុជាបានអះអាងថា យើងនឹងឈរលើឯករាជភាព និងការផ្គត់ផ្គង់ខ្លួនឯង ហើយមិនត្រូវព្យាយាមពាក់ព័ន្ធទៅនឹងកិត្តិយសរបស់មនុស្សណានោះឡើយ ប៉ុន្តែពិធីរំឭកនោះគឺជាការអនុវត្តដ៏ត្រឹមត្រូវនៃគោលនយោបាយរបស់បក្សដើម្បីទទួលបានអំណាច ។ បក្សបានបន្ថែមថាៈ

> យើងធ្វើដូច្នេះដើម្បីចាប់យកឱកាសដែលប្រទេសចិនកំពុងកាន់មរណទុក្ខ ដើម្បីពង្រឹង និងពង្រីកទំនាក់ទំនងមិត្តភាពរបស់យើង និងសាមគ្គីភាពលើការធ្វើសង្គ្រាម ។ ដោយសារប្រទេសចិនពិនិត្យមើលថាតើយើងស្មោះត្រង់ចំពោះខ្លួនគេដល់កម្រិតណា វៀតណាមអាចចាប់យកឱកាសនេះដើម្បីបោកប្រាស់យើង ហើយវៀតណាមបានត្រៀមខ្លួនរួចជាស្រេចក្នុងការពង្រីកអំណាចរបស់ខ្លួន ។ តាមរយៈការប្រារព្ធពិធីរំឭកខួបនេះ យើងនឹងទទួលបានអត្ថប្រយោជន៍ពីទំនាក់ទំនងនេះក្នុងការការពារសត្រូវមិនឲ្យបំបែកបំបាក់យើងបាន ។ ស្ថានភាពបច្ចុប្បន្នទាមទារឲ្យយើងព្យាយាមពង្រឹងទំនាក់ទំនងមិត្តភាពជាមួយនឹងមិត្តភក្តិដែលល្អនិងមានឥទ្ធិពល ។

ឯកសារនេះបានអះអាងថា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងមន្ត្រីយោធា ដែលចូលរួមក្នុងពិធីនៅពហុកីឡដ្ឋាន ត្រូវតែជាមនុស្សចាស់ទុំ សុភាពរាបសា និងស្លៀកពាក់សមរម្យ ពីព្រោះវាគូសបញ្ជាក់អំពីឱកាសដំបូងរបស់បក្សយើង ក្នុងការចូលប្រជុំជាមួយជនបរទេស ដែលនេះគឺជាសូចនាករណ៍សំខាន់ដែលបក្សកុម្មុយនីស្តកម្ពុជាបានផ្សារភ្ជាប់ទៅនឹងការស្លាប់របស់ ម៉ៅ សេទុង ។

នៅខែកញ្ញា ឆ្នាំ១៩៧៦ ប៉ុល ពត បានប្រកាសថា គាត់បានលាលែងតំណែងជានាយករដ្ឋមន្ត្រី ដោយបង្កើតមន្ទិលសង្ស័យអំពីទំនាក់ទំនងផ្ទៃក្នុងនៃកងកម្លាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីការចាប់ខ្លួនក្រុមពួកទាំងបួន ប៉ុល ពត ទទួលបានមុខមាត់ឡើងវិញនៅខែតុលា ដោយថ្លែងជាសាធារណៈអំពីក្រុមក្បត់ទាំងបួនប្រឆាំងទៅនឹងបដិវត្តន៍ចិន ។ ដូច្នេះហើយ កម្មាភិបាលខ្មែរក្រហមបានគាំទ្រប្រធានថ្មីរបស់សាធារណរដ្ឋប្រជាមានិតចិនគឺលោក ហួរ ខែសាង ថ្វីបើមនោគមវិជ្ជារបស់ក្រុមទាំងបួនមានការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រចំពោះប្រទេសកម្ពុជាក៏ដោយ ។ ទិដ្ឋភាពបែបនេះត្រូវបានបញ្ជាក់នៅប៉ុន្មានសប្តាហ៍ក្រោយ នៅពេលដែលប្រទេសចិនប្រកាសអំពីកិច្ចព្រមព្រៀងផ្តល់ជំនួយផ្នែកសេដ្ឋកិច្ចថ្មីមួយនិងជំនួយផ្នែកយោធាបន្ថែមដល់របបកម្ពុជាប្រជាធិបតេយ្យ ។ ជំនួយរបស់ចិនដល់របបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេល

ការបង្រួបបង្រួមនិងការបែកបាក់មនោគមវិជ្ជា បានបង្ហាញថា ទន្ទឹមពេលដែលទ្រឹស្តីរបស់ម៉ៅនិយមបានរួមចំណែកដល់ការបង្កើតទំនាក់ទំនងរវាងប្រទេសចិននិងរបបកម្ពុជាប្រជាធិបតេយ្យ ទស្សនៈអំពីផលប្រយោជន៍ជាតិនិងកិច្ចសហការបានរឹតចំណងដល់របបទាំងពីរ ។

## អតីតកាលដែលមិនវិលត្រឡប់

នៅដើមឆ្នាំ១៩៧៧ នៅពេលដែលការសម្លាប់របស់ខ្មែរក្រហមនៅតែបន្ត ហើយយោធាខ្មែរក្រហមបន្តជម្លោះជាមួយនឹងទ័ពវៀតណាមនៅតាមបណ្តោយព្រំដែន ប្រទេសចិនបានព្រួយបារម្ភថា ឥរិយាបថរបស់របបកម្ពុជាប្រជាធិបតេយ្យនឹងបង្កសង្គ្រាមជាមួយនឹងប្រទេសវៀតណាម ។ ចិនចង់បានការដោះស្រាយតាមរយៈការចរចាចំពោះបញ្ហាព្រំដែន ប៉ុន្តែជាថ្មីម្តងទៀតសាធារណរដ្ឋប្រជាមានិតចិនសុខចិត្តការពាររបប ប៉ុល ពត ជាជាងការជំរុញឲ្យមានការដាក់កំហិត ។ រដ្ឋមន្ត្រីក្រសួងការបរទេសចិន លោក ហ័ង ហួរ បាននិយាយថា ចិននឹងគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យដែលប្រឆាំងនឹងចក្រពត្តិនិយមសូវៀត ហើយខ្លួននឹងផ្តល់ជំនួយទាំងអស់ដល់ការជួយការពារអធិបតេយ្យភាពរបស់របបកម្ពុជាប្រជាធិបតេយ្យ និងបូរណភាពទឹកដី ។ សន្ធិសញ្ញាមិត្តភាពខែកក្កដាឆ្នាំ១៩៧៧ របស់វៀតណាមជាមួយនឹងប្រទេសលាវ បានធ្វើឲ្យក្រុងប៉េកាំងមានការសង្ស័យថា ប្រទេសវៀតណាមខិតខំសាបព្រោះឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់ឥណ្ឌូចិនតាមរយៈការធ្វើអន្តរាគមន៍នៅក្នុងប្រទេសលាវ និងប្រទេសកម្ពុជា ។ បន្ទាប់ពីការសម្លាប់កម្មាភិបាលដែលគាំទ្រវៀតណាម និងការទទួលបានការគាំទ្ររបស់ចិននៅពេលដែលទំនាក់ទំនងរវាងប្រទេសចិន និងវៀតណាម បានបែកបាក់ ប៉ុល ពត បានបង្កើតជំហរកាន់តែរឹងមាំតាមរយៈប្រទេសចិន ។

ចិនបានស្នើឲ្យមានការតបស្នងចំពោះជំនួយរបស់ខ្លួនដែលប្រឆាំងទៅនឹងវៀតណាម ដោយផ្តោតលើគោលនយោបាយការបរទេស ។ អំពើអាក្រក់នៃរបបកម្ពុជាប្រជាធិបតេយ្យបានបង្កការអាម៉ាស់ដល់ចិននៅនៅសហគមន៍អន្តរជាតិនៅពេលដែលចិនប៉ុនប៉ងផ្តាច់ចេញពីទំនាក់ទំនងជាមួយនឹងពិភពលោកខាងក្រៅ ។ ទីក្រុងប៉េកាំងបានជះឥទ្ធិពលលើមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យឲ្យបោះជំហានទៅមុខក្នុងការកែលម្អមុខមាត់របស់ខ្លួន ។ អៀង សារី បានធ្វើដំណើរទៅទីក្រុងញូវយ៉ក ហើយបាននិយាយថា អ្នកកាសែតជនជាតិបរទេសនឹងត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរទៅសួរសុខទុក្ខ និងនិយាយសម្រាលស្ថានការណ៍ដល់ជនភៀសសឹក ។ អៀង សារី បានប្រកាសអំពីសេរីកម្មតិចតួច ហើយបានអញ្ជើញអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក ឃិត វលដាម មកធ្វើដំណើរទស្សកិច្ចមកកាន់របបកម្ពុជាប្រជាធិបតេយ្យ ជាការអញ្ជើញមួយដែលលោកអគ្គលេខាធិការបដិសេធ ។

ប្រទេសចិន បានស្នើសុំឲ្យប៉ុល ពត ប្រកាសការគាំទ្រចំពោះសាធារណរដ្ឋប្រជាមានិតចិន ហើយបានទទួលស្គាល់សមាជិកភាពរបបកម្ពុជាប្រជាធិបតេយ្យក្នុងចលនាកុម្មុយនីស្តអន្តរជាតិ ។ ប៉ុល ពត បានធ្វើដូច្នេះនៅពិធីមួយនៅទីក្រុងប៉េកាំងនៅខែកញ្ញា ឆ្នាំ១៩៧៧ ដែលជាការបង្ហាញមុខជាសាធារណៈលើកដំបូងរបស់ប៉ុល ពត ក្នុងនាមជារដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាលេខាបក្សកុម្មុយនីស្តកម្ពុជា ។ ទន្ទឹមពេលដែលគណៈប្រតិភូរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើដំណើរទស្សនកិច្ចទៅកាន់ទីក្រុងប៉េកាំង នាយករដ្ឋមន្ត្រី ហួរ កែសាង បានកោតសរសើររដ្ឋាភិបាលខ្មែរក្រហមចំពោះមាគ៌ាដ៏ត្រឹមត្រូវរបស់រដ្ឋាភិបាលខ្មែរក្រហម ហើយបទវិចារណកថាភាសាចិនជាផ្លូវការបានហៅទំនាក់ទំនងរវាងចិននិងរបបកម្ពុជាប្រជាធិបតេយ្យថាជា “ការដែលមិនអាចបែកបាក់បាន” ដែលពីមុនជាពាក្យនិយាយសំដៅទៅរកប្រទេសអាល់បានី ។ ចិនបានបោះពុម្ពផ្សាយទស្សនាវដ្តីមួយដែលហៅថា “របបកម្ពុជាប្រជាធិបតេយ្យនឹងឆ្ពោះទៅមុខ” ហើយបានផលិតខ្សែភាពយន្តមួយដែលបង្ហាញពីមេបញ្ជាការភូមិភាគបូព៌ា សោ ភឹម និងអ្នកស្រែដែលខស្សាហ៍ព្យាយាមក្នុងកសាងប្រទេសកម្ពុជា ។

ប៉ុល ពត នៅតែរឹងទទឹង ។ ទន្ទឹមពេលដែលគាត់នៅក្នុងប្រទេសចិន គាត់បានចាក់ផ្សាយសុន្ទរកថារយៈពេលប្រាំម៉ោងដែលបានថតរួចជាស្រេចក្នុងប្រទេសកម្ពុជាដែលបានរំឭកដល់ជ័យជម្នះថ្ងៃទី១៧ ខែមេសា និងស្នាដៃថ្នាក់ជាតិជាបន្តបន្ទាប់ ។ សុន្ទរកថានោះមិនបាននិយាយច្បាស់ៗអំពីជំនួយរបស់ចិនឡើយ ដោយសង្កត់ធ្ងន់អំពីការពឹងផ្អែកលើខ្លួនឯងរបស់ចលនាខ្មែរក្រហមដោយនិយាយថា “ជំនួយមកពីមិត្តបរទេសគ្រាន់តែជាការបំពេញបន្ថែមប៉ុណ្ណោះ ហើយថា មាគ៌ានយោបាយដែលចម្លងពីអ្នកដទៃនឹងមិន

មានផលប្រយោជន៍នោះឡើយ ។ ប្រទេសចិនបានព្រងើយកន្តើយទៅនឹងការមើលងាយនេះដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយយោធាផ្សេងទៀតអំឡុងពេលដំណើរទស្សនកិច្ចនេះ ។

នៅពេលដែល ប៉ុល ពត ធ្វើដំណើរទស្សនកិច្ចនៅប្រទេសចិនប្រហែលជាបានអនុម័តជំនួយរបស់ខ្លួនសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ ដោយមិនគិតពីសំណាង ។ លោក ហួរ បានប្រាប់ប៉ុល ពតថា គាត់បានស្វែងរកដំណោះស្រាយសន្តិភាពរវាងកម្ពុជា និងប្រទេសវៀតណាម ប៉ុន្តែគាត់បានទទួលស្គាល់អំពីសម្ពាធនៃទំនាក់ទំនងរវាងប្រទេសចិន និងសូវៀត និងរវាងប្រទេសចិន និងវៀតណាម ដែលបានលើកឡើងអំពីតម្រូវការរបស់ទីក្រុងប៉េកាំងដល់កម្ពុជា ។ ពិតប្រាកដណាស់ មន្ត្រីរបស់សាធារណរដ្ឋប្រជាមានិតចិនបានជឿថា របបកម្ពុជាប្រជាធិបតេយ្យដែលទន់ខ្សោយ នឹងដួលរំលំ ប្រសិនបើចិនកាត់ជំនួយ ហើយលើកឡើងអំពីការដែលអាចកើតឡើងនៃការធ្វើអន្តរាគមន៍របស់វៀតណាម ។ របាយការណ៍របស់សាធារណរដ្ឋប្រជាមានិតចិនឆ្នាំ១៩៧៩ បានបញ្ជាក់ថាមន្ត្រីចិនបានចាត់ទុករឿងនោះថាជាការសំខាន់ក្នុងការគាំទ្រសម្ព័ន្ធមិត្តរបស់ខ្លួន ទោះបីជាមានបញ្ហាអ្វីក៏ដោយដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តកាលពីអតីតកាល ។ របាយការណ៍ដូចគ្នានេះដែរបានកត់សម្គាល់ថា នៅខែវិច្ឆិកា ការខ្វែងគំនិតគ្នារវាងវៀតណាមនិងកម្ពុជាមិនអាចធ្វើការរាយការណ៍នៅតាមបណ្តាញសារព័ត៌មានបានតទៅទៀតឡើយ ។ កិច្ចខិតខំប្រឹងប្រែងរបស់ចិនក្នុងការទប់ស្កាត់ការខ្វែងគំនិតរវាងប្រទេសទាំងពីរទទួលបរាជ័យ ។ ដោយសារទំនាក់ទំនងរវាងចិននិងវៀតណាមកាន់តែអាក្រក់ជុំវិញការប្រព្រឹត្តរបស់វៀតណាមមកលើជនជាតិចិន និងកត្តាផ្សេងៗ ចិនបានផ្តោតចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកម្ពុជា ។

នៅចុងឆ្នាំ១៩៧៧ វៀតណាមចាប់ផ្តើមបង្កើតទំនាក់ទំនងជាមួយនឹងក្រុមខុទ្ទាមនៃរបបកម្ពុជាប្រជាធិបតេយ្យនៅភូមិភាគបូព៌ានៃប្រទេសកម្ពុជា រួមមាន សោ ភឹម ហើយវៀតណាមបានធ្វើការវាយប្រហារតាមរយៈយោធានៅតាមព្រំដែន ។ ការធ្វើដំណើរទស្សកិច្ចមកកាន់របបកម្ពុជាប្រជាធិបតេយ្យរបស់ឧបនាយករដ្ឋមន្ត្រីចិន លោក ដេន យ៉ងឌី ជាការបង្ហាញយ៉ាងជាក់ស្តែងអំពីការគាំទ្រទន្ទឹមពេលដែលមជ្ឈិមបក្សកុម្មុយនីស្តចិននៅទីក្រុងប៉េកាំងអនុញ្ញាតឲ្យបញ្ជូនអាវុធធុនធ្ងន់និងសម្ភារយោធាផ្សេងៗចូលមកកម្ពុជា ។ ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យបានចេញឯកសារជាសាធារណៈដល់មិត្តរបស់ខ្លួនទោះនៅជិតឬឆ្ងាយ ដោយប្រកាសថា វៀតណាមបានឈ្លានពានហើយខ្លួនបានរិះគន់វៀតណាមពីការបដិសេធមិនព្រមចេញពីកន្លែងលាក់ខ្លួននៅតាមព្រំដែន ហើយបានចោទប្រកាន់វៀតណាមពីបទព្យាយាមធ្វើរដ្ឋប្រហារនៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៦ ។ នៅថ្ងៃទី៣១ ខែធ្នូ របបកម្ពុជាប្រជាធិបតេយ្យបានផ្តាច់ចំណងការទូត ហើយចិនបានកាត់ផ្តាច់កិច្ចសហប្រតិបត្តិការផ្នែកយោធាជាមួយប្រទេសវៀតណាម ដោយចោទប្រកាន់វៀតណាមពីបទឈ្លានពានប្រទេសកម្ពុជា ។

នៅដើមឆ្នាំ១៩៧៨ លោក តេង ស៊ីវភីង បានបន្តឆាកនយោបាយមជ្ឈិមរបស់ខ្លួនក្នុងប្រទេសចិន ។ ចិនបានដកខ្លួនថយពីសង្គ្រាម ដោយបញ្ចប់កិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្មថ្មី ជាមួយនឹងវៀតណាម ហើយបានបញ្ជូនភរិយាលោក ជូ អេនឡាយ មកទីក្រុងភ្នំពេញក្នុងដំណើរទស្សនកិច្ចជាផ្លូវការ ។ ទោះបីជាដំណើរទស្សនកិច្ចនេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញការគាំទ្ររបស់សាធារណរដ្ឋប្រជាមានិតចិនចំពោះរបប ប៉ុល ពត លោកស្រីទំនងជាបាននាំយកសារមួយពីទីក្រុងប៉េកាំង ដែលបានផ្តល់ដំបូន្មានដល់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកែប្រែយុទ្ធសាស្ត្ររបស់ខ្លួនចំពោះជម្លោះតាមព្រំដែន ។ វាមិនច្បាស់លាស់សោះថាតើលោកស្រីបានគំរាមកាត់ផ្តាច់ជំនួយ ប៉ុន្តែលោកស្រីទទួលបានការតបស្តីបកមកវិញពីសំណាក់ខ្មែរក្រហម ។ ប៉ុល ពត និងគូកនរបស់ខ្លួនមិនចាប់អារម្មណ៍នឹងការកែប្រែ និងការសម្របសម្រួលណាមួយនោះឡើយ ។

លោក តេង ស៊ីវភីង និងទីប្រឹក្សាមួយចំនួន បានយល់ដឹងតិចតួចអំពី ប៉ុល ពត និងគោលនយោបាយ ប៉ុល ពត ។ ប៉ុន្តែឥរិយាបថតំបូងរបស់ចិនបានធ្វើឲ្យមានការស្តែងឲ្យឃើញនូវទុគ្រោះចំពោះការដែលត្រូវគំរាមកាត់ផ្តាច់ជំនួយរបប ប៉ុល ពត ឬត្រូវផ្តល់អាទិភាពក្នុងការទប់ស្កាត់ការដួលរលំ និងការឈ្លានពានរបស់វៀតណាម ។ ជាថ្មីម្តងទៀត ចិនបានជ្រើសរើសការទប់ស្កាត់ការដួលរលំរបប ប៉ុល ពត និងការឈ្លានពានរបស់វៀតណាម ។ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានសម្លាប់កម្មាភិបាលភូមិភាគបូព៌ានិងប្រជាជនដើម្បីវែកមុខជន “ក្បាលយួនខ្លួនខ្មែរ” និងសម្លាប់ខ្សែក្បត់ដោយមិន

ចាំបាច់ធ្វើការជំនុំជម្រះ ។ មនុស្សជាងមួយសែននាក់បានស្លាប់ក្នុងរយៈពេលប្រាំមួយខែក្រោយមក ដែលជាដំណាក់កាលឃោរឃៅបំផុតក្នុងសម័យខ្មែរក្រហម ។ រដ្ឋាភិបាលចិនទំនងជាបានដាក់ទណ្ឌកម្មដល់ការកាប់សម្លាប់នេះ ។ របាយការណ៍ ជីង ជៅ បង្ហាញថា ចិនបានគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ សុន សេន ក្នុងការដាក់ពិន័យដល់យោធា និងកំចាត់ចោលទ័ពដែលគាំទ្រវៀតណាម ហើយបានផ្ដល់ជំនួយចាំបាច់ដល់គាត់ដែលនេះជាការនិយាយសំដៅដោយប្រយោលទៅរកពាក្យបោសសម្អាតខ្លាំង ។

នៅខែមីនា ឆ្នាំ១៩៧៨ ការបង្ក្រាបរបស់វៀតណាមដ៏ឃោរឃៅមកលើអ្នកជំនួញឯកជនចិនបានបង្កឲ្យមានជនភៀសសឹកជាបន្តបន្ទាប់និងបង្កឲ្យមានកំហឹងកាន់តែខ្លាំង ។ ចិនបានប្រើប្រាស់ភាសាការទូតគ្រោតគ្រាត ហើយគោលនយោបាយរបស់ចិនបានកែប្រែពីការជំរុញឲ្យមានការចរចាឆ្ពោះទៅរកការទប់ស្កាត់ប្រទេសវៀតណាមពីការឈ្លានពានប្រទេសកម្ពុជា ។ ប្រទេសចិនបានបញ្ជូនស្ថាបនិកមួយក្រុមដើម្បីកសាងផ្លូវដែកឡើងវិញចន្លោះកំពង់សោមមកកាន់ភ្នំពេញ កាត់តាមជិតព្រំដែនវៀតណាម ហើយស្ថាបនិកទាំងនោះនៅតែមានវត្តមាន សូម្បីតែបន្ទាប់ពីបានបញ្ចប់កាតព្វកិច្ចរបស់ខ្លួនក៏ដោយ ។ លោក គេង បានសន្យាចំពោះ សុន សេន ថា លោកនឹងផ្គត់ផ្គង់សម្ភារគ្រប់គ្រាន់ដល់បីកងពលធំនិងស្បៀងថ្នាំពេទ្យ និងអាវុធយុទ្ធភណ្ឌដល់ទាហានប្រហែលដប់ម៉ឺននាក់នៅត្រឹមបំណាច់ឆ្នាំ១៩៧៨ ។ ដោយមានសព្វាវុធនិងអ្នកប្រឹក្សាយោបល់យោធាខ្មែរក្រហមមានលទ្ធភាពបន្ថែមក្នុងការលុកលុយប្រទេសវៀតណាម ។ ក្រុងហាណូយបានឆ្លើយតបដោយមធ្យោបាយវាយបក ហើយដោយផ្សព្វផ្សាយជាសាធារណៈថា បន អៀង សារី ប៉ុល ពត គឺជាឧក្រិដ្ឋជនដែលគួរឲ្យស្អប់ខ្ពើមបំផុតនៅក្នុងពាក់កណ្ដាលសតវត្សរ៍នេះ ហើយចិនបានប្រើប្រាស់បន ប៉ុល ពត អៀង សារី ជាអាយ៉ងរបស់ខ្លួនៈ

អ្នកដែលនៅពីក្រោយអាយ៉ងដែលប្រឡាក់ដោយ



ទីប្រឹក្សាចិនទស្សនកិច្ចការដ្ឋានជួសជុលផ្លូវរថភ្លើងនៅភូមិភាគនិរតី ដឹកនាំដំណើរទស្សនកិច្ចដោយ អៀង សារី (រូបដើរខាងមុខ) ។

> *ឈាមកម្ពុជាក៏មានជនជាតិភាគតិចចាមដែរដែលត្រូវបានសម្លាប់ដូចជនជាតិភាគតិចវៀតណាមដែរ ។ នេះមិនមែនជារឿងអាថ៌កំបាំងនៅក្នុងពិភពលោកនោះទេ ។ បន អៀង សារី ប៉ុល ពត គឺជាឧបករណ៍ថៅកែទាបរបស់ត្រូវប្រឆាំងនឹងសន្តិភាពនិងមនុស្សជាតិ ។*

នៅចន្លោះខែកញ្ញានិងខែធ្នូ ទីប្រឹក្សាយោធាជនជាតិចិនប្រហែល៦០០០នាក់ត្រូវបានប៉ាន់ស្មានថាមានវត្តមាននៅក្នុងប្រទេសកម្ពុជា រួមជាមួយនឹងអ្នកបច្ចេកទេសចិនផ្សេងទៀត ។ ចិនបន្តបង្ហាញការគាំទ្រដល់របបកម្ពុជាប្រជាធិបតេយ្យ ហើយកម្មាភិបាលរបបកម្ពុជាប្រជាធិបតេយ្យបានរាយការណ៍អំពីកិច្ចព្រមព្រៀងលើបញ្ហាទាំងអស់ ជាពិសេសការគាំទ្រក្នុងការទទួលបានជ័យជម្នះលើការឈ្លានពានរបស់ប្រទេសសូវៀតនិងប្រទេសរណបនិងប្រទេសវៀតណាមដែលកំពុងឈ្លានពានទឹកដី ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្មែរក្រហមមិនបានធ្វើតាមការបង្គាប់បញ្ជារបស់ចិននោះឡើយ ។ គេង ស៊ីវភីង បានផ្តល់ការប្រឹក្សាយោបល់ដល់អនុលេខាបក្សកុម្មុយនីស្តកម្ពុជា នួន ជា ដើម្បីកុំឲ្យសូវរករឿងប្រទេសវៀតណាម ហើយលោកបដិសេធមិនផ្តល់ទាហានចិនដែលនឹងធ្វើឲ្យមានការចំណាយច្រើនលើផ្នែកយោធានិងប៉ះពាល់ដល់កិត្តិយសរបស់ខ្លួន ហើយមិនមែនជាកម្លាំងស្នូលដល់ការប្រព្រឹត្តអំពើយង់ឃ្នងរបស់យោធាខ្មែរក្រហមនោះឡើយ ។ ដោយមិនមានឆន្ទៈបោះបង់ចោលរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមើលឃើញសង្គ្រាមថាជាការមិនអាចចៀសផុត ចិនបានបញ្ជូនជំនួយបន្ថែមរួមមានសព្វាវុធ វិទ្យុទាក់ទង អាហារកំប៉ុងដល់កម្ពុជាសម្រាប់យុទ្ធនាការទ័ពព្រៃរបស់ខ្មែរក្រហមដែលអាចបង្វែរឈាមវៀតណាមដោយមិនធ្វើឲ្យប្រទេសចិនធ្លាក់ចូលក្នុងជម្លោះ ។ នៅពេលដែលទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជាហើយបានចូលទីក្រុងភ្នំពេញនៅដើមខែមករា ឆ្នាំ១៩៧៩ ចិនបានជម្លៀសទីប្រឹក្សា និងអ្នកការទូតរបស់ខ្លួន បំផ្លាញឯកសារស្ថានទូត បញ្ជូនសម្តេច សីហនុ និងព្រះរាជវង្សរបស់ព្រះអង្គទៅប្រទេសថៃ ហើយបានបង្កើតស្ថានទូតមួយនៅជួរភ្នំក្រវាញដើម្បីជួយគាំទ្រការបះបោររបស់ខ្មែរក្រហម ។

### *សេចក្តីសន្និដ្ឋាន*

ភ័ស្តុតាងដែលអាចរកបានបង្ហាញថា ជំនួយបច្ចេកទេសនិងសម្ភាររបស់ចិនដល់របបកម្ពុជាប្រជាធិបតេយ្យ ហើយការផ្សំគំនិតក្នុងការប្រព្រឹត្តអំពើយង់ឃ្នងកាន់តែស្តែងឲ្យឃើញ ។ ប៉ុន្តែសាច់រឿងនោះមិនមែនជាទិសដៅមួយក្នុងចំណោមទិសដៅឬការយល់ស្របរបស់ចិននោះឡើយ ។ វាគឺជាភាពទន់ខ្សោយមួយក្នុងចំណោមភាពទន់ខ្សោយរបស់ប្រទេសចិន ហើយជាការដាក់ការព្រួយបារម្ភអំពីបញ្ហាមនុស្សធម៌ឲ្យស្ថិតក្រោមការប្រើប្រាស់យុទ្ធសាស្ត្រដែលទន់ខ្សោយរបស់ចិន ។ ពិតប្រាកដណាស់ ចិនមិនមែនជាតួអង្គខាងក្រៅដែលទទួលខុសត្រូវនោះឡើយ ។ ការបណ្តុះបណ្តាលរបស់វៀតណាម និងសព្វាវុធ ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ការគាំទ្ររបប លន់ នល់ ចន្លោះឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ការព្រងើយកន្តើយរបស់អន្តរជាតិចំពោះកម្ពុជាបន្ទាប់ពីការដកថយរបស់សហរដ្ឋអាមេរិកចេញពីឥណ្ឌូចិនក្នុងខែខសភា ឆ្នាំ១៩៧៥ បានរួមចំណែកដល់សោកនាដកម្មក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែ ប្រទេសចិនបានដើរតួនាទីដោយឡែកដោយសារតែទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរបប ប៉ុល ពត ។

ទំនាក់ទំនងរវាងចិននិងរបបកម្ពុជាប្រជាធិបតេយ្យនាំមកនូវមេរៀនដល់ការធ្វើទំនាក់ទំនងការបរទេសនាពេលសព្វថ្ងៃ ។ ការព្រួយបារម្ភអំពីការបរាជ័យរបស់រដ្ឋទន់ខ្សោយបង្ហាញគោលនយោបាយចិននាសម័យទំនើបចំពោះប្រទេសកូរ៉េខាងជើងនិងការធ្វើឲ្យចុះអន់ថយដល់សមត្ថភាពរបស់ក្រុងប៉េកាំងក្នុងការជំរុញឲ្យមានការធ្វើកំណែទម្រង់ក្នុងប្រទេសនោះ ។ ការបន្តគោលដៅយុទ្ធសាស្ត្ររយៈពេលខ្លី ដែលជារឿយៗលើកឡើងពាក្យសម្តីមិនជ្រៀតជ្រែក បានរួមចំណែកដល់ការគាំទ្ររបស់ចិនដល់រដ្ឋាភិបាលរំលោភបំពានដូចជាប្រទេសហ្ស៊ីមបាវេ និងស៊ូដង់ ជាពិសេសធ្វើឲ្យចិនមិនមែនជាប្រទេសឯកោនោះឡើយ ។ សហរដ្ឋអាមេរិក និងមហាអំណាចដទៃទៀតបានបង្កឲ្យមានមហន្តរាយដល់ជីវិតមនុស្សនៅពេលដែលប្រទេសទាំងនោះការពាររបបជិះជាន់ដើម្បីទទួលបានផលប្រយោជន៍ជាយុទ្ធសាស្ត្រនិងការពារកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ។ ករណីនៃរបបកម្ពុជាប្រជាធិបតេយ្យបានក្រើនរំឭកអំពីភាពលំបាកអំពីការចងសម្ព័ន្ធមិត្តជាមួយប្រទេសតូចតាចនិងហានិភ័យចំពោះរឿងបែបនោះ ។ **ចន ឆរឆីអារី**




ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់សមាជិករដ្ឋាភិបាលរួបរួមជាតិនៅប្រទេសចិន អំឡុងឆ្នាំ១៩៧៤ ឬ១៩៧៥ ៖ (១) ដៀក សាដាន់, (២) ម៉ុក សូវង់, (៣) ចាន់ សារ៉ុត, (៤) ឡូវ៉ង់ ពិក, (៥) សុ ដានីតា, (៦) ឡាយ នារី, (៧) ទុន ដោតស៊ីរិន, (៨) ឌួង សំអុល, (៩) ប្រពន្ធ ឌួង សំអុល, (១០) គាត បុប្ផា, (១១) គាត រស្មី, (១២) សមមិត្ត ឈុន, (១៣) បាន យ៉ាន, (១៤) ប្រពន្ធ បាន យ៉ាន, (១៥) រឿង ម៉ាច, (១៦) ប៉ែន សាផន, (១៧) ពុំមិកា, (១៨) សេង លី និង (១៩) សមមិត្ត ស៊ា ។

# អក្សរសាស្ត្រអ៊ីស្លាម ដែលបានកប់ទុកនៅក្នុងរបបខ្មែរក្រហម

អត្ថបទនេះអាចនិយាយបានថាជាសមិទ្ធផលមួយដែលបានមកពីការរួមបញ្ចូលការសិក្សាស្រាវជ្រាវរយៈពេលម្ភៃឆ្នាំរបស់ខ្ញុំស្តីពីការសិក្សាអំពីអ៊ីស្លាមដោយផ្អែកលើឯកសារដែលសរសេរជាភាសាអារ៉ាប់ និងតាមរយៈការសិក្សាអំពីជនជាតិអ៊ីស្លាមនៅប្រទេសកម្ពុជា ។ ខ្ញុំបានសិក្សាអំពីអ៊ីស្លាមដោយផ្តោតលើប្រវត្តិនៃការប្រែសម្រួលគម្ពីរគូរ៉ានចាប់តាំងពីខ្ញុំសរសេរនិក្ខេបបទនៅសកលវិទ្យាល័យតូក្យូមកម្ល៉េះ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានសិក្សាអំពីអ៊ីស្លាមនិងភាសាអារ៉ាប់នៅក្នុងប្រទេសមជ្ឈិមបូព៌ាមួយចំនួន ដូចជា ប្រទេសអេហ្ស៊ីប និងហ្សកដង់ ។ ទាំងនេះមានន័យថា ខ្ញុំមិនដែលរំពឹងថានឹងសិក្សាពីអ៊ីស្លាមនៅអាស៊ីអាគ្នេយ៍ទេ ទោះបីជាខ្ញុំមានចំណាប់អារម្មណ៍ ហើយបានធ្វើដំណើរទៅកាន់ប្រទេសកាន់សាសនាអ៊ីស្លាមមួយចំនួនដូចជាប្រទេសម៉ាឡេស៊ីនិងប្រទេសឥណ្ឌូនេស៊ីក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយ និយាយដោយស្មោះត្រង់ ខ្ញុំមានការយល់ដឹងតិចតួចអំពីអ៊ីស្លាមនៅប្រទេសកម្ពុជា ជាទីដែលខ្ញុំកំពុងផ្តោតលើការសិក្សា ហើយខ្ញុំយល់ឃើញថា ការសិក្សានេះមានសារសំខាន់មុនពេលដែលខ្ញុំមកទីនេះ ។

នៅពេលដែលខ្ញុំបានចាប់ផ្តើមការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះ ខ្ញុំអរគុណចំពោះការទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដល់រូបខ្ញុំ ។ ខ្ញុំបានប្រទះឃើញសំណេរជាភាសាអារ៉ាប់ដ៏មានសារសំខាន់ជាច្រើន ។ សំណេរទាំងនេះត្រូវបានកប់ទុកដើម្បីលាក់កំបាំងពីខ្មែរក្រហមដែលបានបញ្ជាឲ្យដុតគម្ពីរគូរ៉ាន និងគម្ពីរសាសនាអ៊ីស្លាមផ្សេងទៀត ដែលជាមធ្យោបាយមួយក្នុងការដាក់ទណ្ឌកម្មប្រជាជន ។ ដូច្នេះហើយ សំណេរនេះមានការពុកផុយជាខ្លាំង ។ នៅពេលដែលយើងប៉ះឯកសារទាំងនោះ ឯកសារទាំងនោះងាយនឹងរហែកណាស់ ។ ហាគីម (មេដឹកនាំសាសនាអ៊ីស្លាម) នៅភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម បានកប់សំណេរទាំងនោះក្នុងរបប ប៉ុល ពត ហើយក៏បានជីកកកាយមកវិញបន្ទាប់ពីរបបនោះដួលរលំក្នុងឆ្នាំ១៩៧៩ ។ ម្ភៃឆ្នាំក្រោយ អតីតអ្នកសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមួយរូបឈ្មោះ អ៊ីសា អូស្មាន់ ត្រូវបានប្រគល់ជូននូវឯកសារទាំងអស់នេះនៅពេលដែលគាត់ធ្វើការសិក្សាស្រាវជ្រាវនៅក្នុងភូមិនោះ ។ បន្ទាប់ពីនោះមក ខ្ញុំត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សំណេរនោះសម្រាប់ការសិក្សាស្រាវជ្រាវ ។ នេះគឺជាសំណាងសម្រាប់ខ្ញុំដោយសារខ្ញុំអាចសិក្សាអំពីអ៊ីស្លាមកម្ពុជាតាមរយៈសំណេរជាភាសាអារ៉ាប់នេះ ។

## អក្សរសាស្ត្រអ៊ីស្លាម



គម្ពីរគូរ៉ានដែលគាស់ចេញពីក្នុងដីក្រោយរបបខ្មែរក្រហមដួលរលំ

សៀវភៅរបស់អ្នកនិពន្ធ អ៊ីសា អូស្មាន់ មានចំណងជើងថា ការបះបោររបស់ជនជាតិចាម ៖ សាច់រឿងរបស់អ្នករស់រានមានជីវិត ដែលបានបរិយាយនិងវិភាគលម្អិតអំពីការប្រឆាំងរបស់ជនជាតិចាមទៅនឹងខ្មែរក្រហមនៅភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម បានបង្ហាញថា ៖

> ក្នុងឆ្នាំ១៩៧៥ ក្រដាសឯកសារនេះត្រូវបាននាំ ហើយកប់ទុកនៅក្នុងភូមិស្វាយឃ្លាំងជាមួយនឹង សៀវភៅសាសនាជាភាសាអារ៉ាប់ដទៃចាប់ពីសៀវភៅច្បាប់រហូតដល់សៀវភៅវេយ្យាករណ៍ ។ សៀវភៅទាំងនេះត្រូវបានជីកកកាយមកវិញក្នុងឆ្នាំ១៩៧៩ ។

ជាអកុសល ហាកឹម មហាម៉ាត់ កាជី ដែលជាម្ចាស់ ហើយបានកប់សៀវភៅទាំងនោះបានស្លាប់កាលពីពីរឆ្នាំមុន ។ ខ្ញុំបានធ្វើដំណើរទៅកាន់ភូមិស្វាយឃ្លាំង ដោយមានការជួយសម្របសម្រួលពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់ឈ្មោះ សា ហ្វាទីលី ហើយក៏បានសម្ភាសគ្រួសាររបស់ មហាម៉ាត់ កាជី ដែលបានយល់ដឹងតិចតួចអំពីរឿងឯកសារនោះ ។ ក្រោយមក យើងក៏បានធ្វើសម្ភាសជាមួយជាមួយ ហាកឹម យ៉ូសូវ ប៉ុនចាម៉ឹន ដែលបានដឹងយ៉ាងច្រើននិងផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់ការយល់ដឹងអំពីឯកសារទាំងនោះ ។ ហាកឹម យ៉ូសូវ ប៉ុនចាម៉ឹន បាននិយាយប្រាប់យើងថា មនុស្សជាច្រើនបានកប់វត្ថុមានតម្លៃ ដូចជា សៀវភៅ គ្រឿងអលង្ការ ដាវ ដើម្បីលាក់កំបាំងពីខ្មែរក្រហម ។ គាត់បានកប់សៀវភៅសាសនាមួយចំនួនដោយផ្ទាល់ពេលនោះដែរ ប៉ុន្តែគាត់មិនអាចស្វែងរកសៀវភៅទាំងនោះឃើញវិញទេក្រោយពីរបប ប៉ុល ពត បានដួលរលំ ។ ទាំងនេះបានធ្វើឲ្យគាត់ស្រក់ទឹកភ្នែកដោយក្តីអាឡោះអាល័យដែលបានបាត់ឯកសារទាំងនោះ ។

បន្ទាប់ពីខ្ញុំមើលឯកសារទាំងនោះដោយយកចិត្តទុកដាក់មក ឯកសារទាំងនោះបានបង្ហាញអំពីការសិក្សាស្រាវជ្រាវអំពីចាមមុនរបប ប៉ុល ពត ។

សៀវភៅជាច្រើនបានសរសេរជាភាសាអារ៉ាប់ ។ ប៉ុន្តែ



អក្សរអារ៉ាប់សរសេរដោយដៃ ដែលស្រង់ចេញពីគម្ពីរគូរ៉ាន

សៀវភៅរបស់អ្នកនិពន្ធ អាល់ ហ្វាតានី មួយចំណែកត្រូវបាន សរសេរជាភាសាចាម ហើយឯកសារដែលមិនស្គាល់អត្តសញ្ញាណផ្សេងទៀត ត្រូវបានសរសេរជាភាសាចាម ដែលជាភាសាម៉ាឡេ ចំណាស់សរសេរជាមួយតួអក្សរអារ៉ាប់ ។ ជាងនេះទៅទៀត វាគួរឲ្យកត់សំគាល់ដែលថា សៀវភៅភាគច្រើន ស្ថិតក្នុងជំពូកសៀវភៅ គីតាបកូននីង ជាភាសាម៉ាឡេ មានន័យថា «សៀវភៅលឿង» ។ ពាក្យ គីតា មានដើមកំណើតមកពីភាសាអារ៉ាប់ដែលមានន័យថា «សៀវភៅ» ហើយពាក្យ គុននីង មានន័យថា «សន្លឹកសៀវភៅពណ៌លឿង» ដែលនាំយកមកពីមជ្ឈិមបូព៌ានៅដើមសតវត្សរ៍ទី២០» ។ នៅក្នុងសហគមន៍ ម៉ូស្លីមម៉ាឡេ រួមទាំងសហគមន៍ចាមម៉ូស្លីមនៅក្នុងប្រទេសកម្ពុជា គីតាបកូននីង ឬសៀវភៅលឿង ត្រូវបានប្រើប្រាស់ជាសៀវភៅសិក្សានៅក្នុងថ្នាក់រៀនអ៊ីស្លាមនៅក្នុងសហគមន៍ម៉ាឡេ ។

ទាំងតួអក្សរ និងមាតិកានៃឯកសារទាំងនេះ មានលក្ខណៈគួរឲ្យកត់សំគាល់ ។ ឯកសារដែលមានចំណងជើងថា តាសស៊ី អាល់-ចាលឡាឡាន គឺជាឯកសារប្រែសម្រួលពីគម្ពីរកូរ៉ានដ៏ល្បីឈ្មោះមួយនៅមជ្ឈិមបូព៌ារហូតដល់សព្វថ្ងៃនេះ ។ អ្នកនិពន្ធសៀវភៅនេះគឺ ចាឡាល់ អាល់-ឌិន អាល់-ម៉ាហាលី និង ចាឡាល់ អាល់-ឌិន អាល់-សូយូទី ដែលជាអ្នកសិក្សាស្រាវជ្រាវជនជាតិអេហ្ស៊ីប ហើយសៀវភៅនេះក៏ត្រូវបានប្រើប្រាស់ជាសៀវភៅសិក្សាដែរ ។ សៀវភៅនេះបានប្រែសម្រួលគម្ពីរគូរ៉ាន់ ដែលនេះបានធ្វើឲ្យសៀវភៅនេះក្លាយជាសៀវភៅប្រែសម្រួលគម្ពីរសាសនាជាភាសាអារ៉ាប់ដ៏ ពេញនិយមបំផុតសម្រាប់ជនជាតិម៉ូស្លីមនៅអាស៊ីអាគ្នេយ៍ ។

សៀវភៅ មុនយាត អាលម៉ូសាលី របស់ អាលហ្វាតានី គឺជាសៀវភៅមួយក្នុងចំណោមសៀវភៅ គីតាបកូននីង ឬសៀវភៅលឿង ដ៏សំខាន់និងពេញនិយមបំផុត ។ សៀវភៅនេះ ពិពណ៌នាអំពីសារៈសំខាន់នៃការបន់ស្រន់របស់ជនម៉ូស្លីម ។ អ្នកនិពន្ធ អាល់-ហ្វាតានី មានស្រុកកំណើតនៅប៉ាតាន ទីក្រុងមួយស្ថិតនៅភាគខាងត្បូងប្រទេសថៃ ដែលជាកន្លែងមួយសម្រាប់សិស្សកម្ពុជាជនជាតិចាមសិក្សាអំពីអ៊ីស្លាម ។ អាល់-ហ្វាតានី បានធ្វើដំណើរទៅ មេកា



សំបុត្រសរសេរជាអក្សរម៉ាឡាយូដែលជនជាតិចាមប្រើក្នុងប្រទេសកម្ពុជា ហើយសេសសល់ពីរបបខ្មែរក្រហម

ជាទីដែលគាត់ទទួលបានកេរ្តិ៍ឈ្មោះជាអ្នកសិក្សាស្រាវជ្រាវដែលបានសរសេរសៀវភៅជាច្រើន ហើយបានបង្រៀនសិស្សជាច្រើន ។ សៀវភៅរបស់គាត់នៅតែត្រូវបានប្រើប្រាស់ជាសៀវភៅសិក្សានៅថ្នាក់រៀនអ៊ីស្លាមនៅក្នុងសហគមន៍ម៉ាឡេ ។

ណាវាវី អាល់-បានតានី ដែលជាអ្នកនិពន្ធសៀវភៅហ្វាតអាល់មាជីត និង ម៉ាដារីជ អាល់សុត គឺជាអ្នកសិក្សាស្រាវជ្រាវដ៏សំខាន់របស់ជនជាតិម៉ូស្លីមនៅអាស៊ីអាគ្នេយ៍ ។ ណាវាវីកើតនៅតំបន់ បានតីន ប៉ែកខាងលិចនៃកោះជ្វា ហើយបានផ្លាស់ទីលំនៅទៅមេកា ហើយបានទទួលកេរ្តិ៍ឈ្មោះដូច អាល់-ហ្វាតានីដែរ ។ អ្នកនិពន្ធ ប្រេងស្វី បានសម្ភាសជាមួយ ណាវាវី អាល់-បានតានី ។ ប្រេងស្វី បានរៀបរាប់ថា ណាវាវី អាល់-បានតានី ធ្លាប់ជាអ្នកនិពន្ធដ៏មានប្រជាប្រិយភាពបំផុតរបស់សិស្សម៉ូស្លីមកម្ពុជាមុនរបប ប៉ុល ពត ។ អង្គហេតុនេះ ស្របគ្នាទៅនឹងមាតិកានៃអត្ថបទដែលត្រូវបាន លើកយកមកសិក្សានៅក្នុងឯកសារនេះ ។

## សេចក្តីសន្និដ្ឋាន

អក្សរសាស្ត្រអ៊ីស្លាមនេះបានលេចឡើងសាជាថ្មីដោយសារតែសម័យកាលដ៏សោកសៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ នៅពេលដែលខ្ញុំសិក្សាកាន់ឯកសារទាំងនោះ ខ្ញុំមានអារម្មណ៍ថា ឯកសារទាំងនោះហាក់បីដូចជាមានសំឡេងឬមានវិញ្ញាណនិងព្យាយាមនិយាយអ្វីមួយ ។ ខ្ញុំមិនគិតថា ខ្ញុំគឺជាមនុស្សម្នាក់ដែលយល់ដឹងត្រឹមត្រូវអំពីពាក្យទាំងនោះឡើយ ដោយសារខ្ញុំមិនមែនជាអ្នកជំនាញយល់ដឹងអំពីរបប ប៉ុល ពត ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំអាចនិយាយបានថា ការស្រាវជ្រាវរបស់ខ្ញុំធ្វើឲ្យអង្គហេតុមួយចំនួនមានលក្ខណៈច្បាស់លាស់តាមរយៈឯកសារទាំងនេះ ។

មុនរបបខ្មែរក្រហម ជនជាតិម៉ូស្លីមកម្ពុជាដែលជាជនជាតិចាមឬជ្វាកាលត្រូវបានហៅថា «ខ្មែរអ៊ីស្លាម» មានទំនាក់ទំនងទៅនឹងប្រពៃណីរបស់ជនម៉ូស្លីមម៉ាឡេ ។ យោងតាម ហាសីម ប៊ិនហាជី «ចាប់តាំងពីសតវត្សរ៍ទី១៩ ឯកសារភាសាចាមស្តីពីការសិក្សាអំពីអ៊ីស្លាមត្រូវបានហៅថាជា គីតាបកូននីង ឬសៀវភៅលឿង ហើយត្រូវបានប្រើប្រាស់នៅពាសពេញសហគមន៍ម៉ាឡេរហូតដល់ចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០» ។ ជនជាតិចាមបានសិក្សាភាសាអ៊ីស្លាមដោយប្រើប្រាស់ គីតាបកូននីង ឬសៀវភៅលឿង ដូចសិស្សម៉ូស្លីមដទៃទៀតនៅតំបន់អាស៊ីអាគ្នេយ៍ក្រៅពីប្រទេសកម្ពុជាដែរ ។ សិស្សទាំងនោះទទួលឥទ្ធិពលពីអ្នកសិក្សាស្រាវជ្រាវរបស់សហគមន៍ម៉ាឡេ រួមមានប្រទេសថៃភាគខាងត្បូងនិងឧបទ្វីបម៉ាឡេ ចាប់តាំងពីទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២០មក ។ ដូច្នេះហើយ នៅពេលដែលខ្មែរក្រហមចាប់ផ្តើមរបបរបស់ខ្លួន ជនជាតិចាមបានសិក្សាអំពីអ៊ីស្លាមដោយផ្អែកលើ គីតាបកូននីង ឬសៀវភៅលឿងនេះ ។

យើងអាចនិយាយបានថា ចាមម៉ូស្លីមមុននិងក្រោយរបប ប៉ុល ពត មានទំនាក់ទំនងទៅនឹងអក្សរសាស្ត្រអារ៉ាប់ ដោយសារការសិក្សាអំពីសហគមន៍ម៉ាឡេ ដែលបានគូសបញ្ជាក់អំពីលក្ខណៈរបស់ជនម៉ូស្លីមនៅក្រៅប្រទេស ដោយសារវាគឺជាលក្ខណៈដ៏សំខាន់របស់ជនម៉ូស្លីមក្នុងបរិបទអន្តរជាតិ ។ ទោះបីជាយ៉ាងនេះក៏ដោយ យើងអាចនិយាយថា មានការដាក់កំហិតចំពោះជនម៉ូស្លីម ដោយសារតែស្ថានភាពក្នុងរបបប៉ុលពត ដែលប្រជាជនមិនអាចធ្វើដំណើរទៅបរទេសដោយងាយស្រួលនិងទទួលបានព័ត៌មានពីបរទេស ។

ម្យ៉ាងវិញទៀត ជនជាតិចាមនាពេលបច្ចុប្បន្ន បានបង្ហាញយើងអំពីការប្រាស្រ័យទាក់ទងជាសកលរបស់ខ្លួន ។ ក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកការងារសាសនាអ៊ីស្លាមនៅប្រទេសកម្ពុជាដែលជាស្ថាប័នមួយគ្រប់គ្រងជនម៉ូស្លីមនៅក្នុងប្រទេសកម្ពុជាក្រោមការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជា មានសៀវភៅភាសាអារ៉ាប់មួយចំនួននៅការិយាល័យរបស់ខ្លួន ។ សៀវភៅទាំងនោះរួមមាន សៀវភៅរបស់សហគមន៍ម៉ាឡេ និងសៀវភៅអារ៉ាប់ជាច្រើនដូចជា សៀវភៅប្រែសម្រួលគម្ពីរគូរ៉ាន និងសៀវភៅស្តីពីប្រពៃណី ដែលត្រូវបានចាត់ទុកថាជាមូលដ្ឋានក្នុងការសិក្សាអំពីអ៊ីស្លាមនៅមជ្ឈិមបូព៌ា ។ ទាំងនេះ មានន័យថា ដោយសារតែគីតាបកូននីង ឬសៀវភៅលឿង ជនជាតិចាមនៅក្នុងប្រទេសកម្ពុជាបានយល់ដឹងអំពីអ៊ីស្លាមតាមរយៈសៀវភៅភាសាអារ៉ាប់ ដូចដែលសៀវភៅទាំងនោះត្រូវបានយកទៅសិក្សានៅមជ្ឈិមបូព៌ាសម្រាប់ការយល់ដឹងអំពីអ៊ីស្លាម ។ ទោះបីជាយ៉ាងណាក៏ដោយ យើងអាចកត់សម្គាល់បានថា ការសិក្សាថ្មីនេះមិនអាចកើតឡើងដោយគ្មានជំនួយពីមនុស្សជំនាន់មុនដែលបានសិក្សា និងការពារសៀវភៅគីតាបកូននីង ក្នុងរបប ប៉ុល ពត នោះឡើយ ។ **រីកុ គុរុមីយ៉ារូភាវ៉ា**

# សកម្មភាពសំខាន់ៗមួយចំនួនរបស់មជ្ឈមណ្ឌ

## គម្រោងឃ្លាំមើលសាលាក្តីខ្មែរក្រហម គម្រោងស្តីពីការសិក្សា

## វេទិកាសាធារណ









# ណ្ឌលឯកសារកម្ពុជា ក្នុងខែកញ្ញា ឆ្នាំ២០១៣

## ាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង ណៈនៅតាមភូមិ









# យុត្តិធម៌ និងការអត់ឃ្លានសម័យបច្ចុប្បន្ន

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

*កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៧)*

វគ្គទី៧នេះ ផ្ដោតសំខាន់ទៅលើថាតើការយល់ដឹងរបស់មនុស្សទាក់ទងនឹងការអត់ឃ្លានមានការប្រែប្រួលដែរឬទេ ហើយថាតើការអត់ឃ្លានជាលទ្ធផលនៃកត្តានយោបាយ មនុស្ស និងការធ្លាក់ចុះនៃផលិតកម្មស្បៀងអាហារឬយ៉ាងណា ។ នៅក្នុងវគ្គនេះ យើងខ្ញុំនឹងលើកយកការអត់ឃ្លានសម័យបច្ចុប្បន្នដែលបានកើតឡើងនៅប្រទេសកូរ៉េខាងជើង ប្រទេសអេត្យូពី (Ethiopia) តំបន់ដាហ្វ័រ (Darfur) និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។

### សេចក្ដីផ្ដើម ៖ ការអត់ឃ្លានក្នុងសតវត្សរ៍ទី២០

អស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមក ការអត់ឃ្លានត្រូវបានទទួលស្គាល់ថា បានបង្កឡើងដោយគ្រោះធម្មជាតិ ឬកត្តាផ្សេងៗដែលប៉ះពាល់ទៅដល់បរិមាណស្បៀង ដែលផលិតនៅក្នុងប្រទេស ឬតំបន់មួយដែលរងគ្រោះដោយសារគ្រោះទុរ្ភិក្ស ។ និយមន័យនេះសបញ្ជាក់ឲ្យឃើញថា ការអត់ឃ្លានគឺជាហានិភ័យមួយដែលមិនអាចជៀសផុត ហើយមានការពាក់ព័ន្ធជាមួយនឹងមនុស្ស ។ ការយល់ឃើញបែបនេះត្រូវបានទទួលស្គាល់ថាជា "ទ្រឹស្ដីម៉ាលសឹស" (Malthusian) បន្ទាប់ពីអ្នកប្រាជ្ញម្នាក់ឈ្មោះ រ៉ូបឺត ម៉ាលសឹស (Robert Malthus) បានសរសេរការវិភាគដ៏មានឥទ្ធិពលមួយចំនួនទាក់ទងទៅនឹងការអត់ឃ្លាននៅចុងទសវត្សរ៍ឆ្នាំ ១៧០០ ។ នៅក្នុងទ្រឹស្ដីនៃការអត់ឃ្លានដែលបង្កើតឡើងដោយ រ៉ូបឺត ម៉ាលសឹស ដោយសារតែការអត់ឃ្លានកើតឡើងនៅក្នុង



កងកុមារកំពុងជញ្ជូនដីនៅក្នុងរបបខ្មែរក្រហម

ប្រទេសមួយដែលមានប្រជាជនច្រើនលើសលុប ឬមានការផលិតស្បៀងមិនគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ប្រជាជន ដូច្នេះដើម្បីការពារកុំឲ្យកើតមានការអត់ឃ្លាន យើងត្រូវផ្តោតសំខាន់ទៅលើការបង្កើនផលិតកម្មស្បៀង និងដោះស្រាយរាល់បញ្ហាបច្ចេកទេសផ្សេងៗ ដូចជាការពង្រីកមធ្យោបាយដឹកជញ្ជូន ឬកន្លែងស្តុកស្បៀងជាដើម ។ ទស្សនៈនេះត្រូវបានប្រើប្រាស់នៅក្នុងការសិក្សាទាក់ទងទៅនឹងគ្រោះអត់ឃ្លានរហូតដល់ចុងសតវត្សរ៍ទី២០ ។ បន្ទាប់មកមានអ្នកប្រាជ្ញថ្មីៗមួយចំនួនដូចជា អាម៉ាតយ៉ា សែន (Amartya Sen) បានចាប់ផ្តើមធ្វើការចោទសួរថាតើទ្រឹស្តីនេះពិតជាត្រឹមត្រូវគ្រប់កាលៈទេសៈដែរឬទេ ។

មូលហេតុនៃការយល់ឃើញទាក់ទងនឹងគ្រោះអត់ឃ្លានរបស់ម៉ាលសឹស ត្រូវបានចោទជាសំណួរដោយសារតែទស្សនៈនៃការអត់ឃ្លាននោះមិនបានឆ្លុះបញ្ចាំងត្រឹមត្រូវពីការអត់ឃ្លាន ដែលកើតមាននៅក្នុងសតវត្សរ៍ទី២០នោះទេ ។ បើតាមទ្រឹស្តី ម៉ាលសឹស (Malthusian) ដើម្បីទប់ស្កាត់គ្រោះអត់ឃ្លាន ត្រូវធ្វើយ៉ាងណាដោះស្រាយបញ្ហាបច្ចេកទេស ដូចជា ការផលិត និងការដឹកជញ្ជូនអាហារ ដើម្បីផ្គត់ផ្គង់ប្រជាជននៅក្នុងប្រទេសនីមួយៗ ។ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ភាពជឿនលឿនខាងបច្ចេកវិទ្យាបានដោះស្រាយបញ្ហាប្រឈមចម្បងៗមួយចំនួន ដែលជាដំណោះស្រាយក្នុងការលុបបំបាត់គ្រោះអត់ឃ្លាននៅទូទាំងសាកលលោក ឧទាហរណ៍ដូចជា ជី គ្រឿងម៉ាស៊ីន ទូរទឹកកក និងការដឹកជញ្ជូនផ្សេងៗ បានផ្តល់លក្ខណៈងាយស្រួលដល់ការបង្កបង្កើនផលក្នុងទ្រង់ទ្រាយធំ និងបានសម្រួលដល់ដំណើរការដឹកជញ្ជូនផលិតផលម្ហូបអាហារទៅកាន់តំបន់ផ្សេងៗ ដោយមិនបានធ្វើឲ្យផលិតផលទាំងនោះខូចគុណភាពទៀតផង ។ ថ្វីបើមានភាពជឿនលឿនផ្នែកបច្ចេកវិទ្យាយ៉ាងណាក៏ដោយ ការអត់ឃ្លាននៅតែកើតមានឡើងនៅក្នុងសតវត្សរ៍ទី២០ដដែល ។ មិនតែប៉ុណ្ណោះ នៅតាមតំបន់ជាច្រើន ការអត់ឃ្លានបែរជាមានសភាពធ្ងន់ធ្ងរជាងការអត់ឃ្លានដែលធ្លាប់កើតមានពីមុនៗទៅទៀត ។ ជាក់ស្តែង នៅក្នុងសតវត្សរ៍ទី២០ មានជនរងគ្រោះប្រមាណជាង៧០លាននាក់បានស្លាប់ដោយសារការអត់ឃ្លាន ។

នៅពាក់កណ្តាលសតវត្សរ៍ទី២០ អ្នកប្រាជ្ញមួយចំនួនបានចាប់ផ្តើមធ្វើការស៊ើបអង្កេតទៅលើឫសគល់នៃការអត់ឃ្លាន និងធ្វើការឆ្លើយតបទៅនឹងផ្នែកមួយចំនួននៃទ្រឹស្តីម៉ាលសឹស (Malthusian) ។ នៅពេលដែលក្រុមអ្នកប្រាជ្ញទាំងនោះ ធ្វើការពិនិត្យពិច័យទៅលើការអត់ឃ្លានដែលបានកើតឡើង ក្រុមអ្នកប្រាជ្ញទាំងនោះបានធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នាថា បម្រែបម្រួលនៃផលិតកម្មស្បៀងអាហារនៅក្នុងប្រទេស ឬតំបន់ផ្សេងៗដែលទទួលរងគ្រោះដោយសារគ្រោះអត់ឃ្លាន មិនមានជាប់ទាក់ទងទៅនឹងទីកន្លែងដែលមានគ្រោះអត់ឃ្លាននោះទេ ។ ផ្ទុយទៅវិញ ក្រុមអ្នកប្រាជ្ញទាំងនោះបានយល់ឃើញថា កត្តាមួយចំនួន ដូចជា កត្តានយោបាយ កត្តាសង្គម និងកត្តាច្បាប់ មានសារៈសំខាន់ក្នុងការទប់ស្កាត់គ្រោះអត់ឃ្លាន ។ ជាឧទាហរណ៍ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ គ្រោះអត់ឃ្លានដ៏ធ្ងន់ធ្ងរមួយបានកើតឡើងនៅក្នុង ប្រទេសអេត្យូពី(Ethiopia) ដែលនៅភាគខាងជើងនៃទ្វីបអាហ្វ្រិក ។ គ្រោះអត់ឃ្លាននេះបង្កឡើងដោយសារអាកាសធាតុមិនល្អ ដែលធ្វើឲ្យទិន្នផលស្បៀងមានការថយចុះ ។ ប៉ុន្តែ យើងសង្កេតឃើញថា គ្រោះអត់ឃ្លានធ្ងន់ធ្ងរបានកើតឡើងនៅក្នុងតែប្រទេសអេត្យូពី (Ethiopia) តែប៉ុណ្ណោះ ។ ចំណែកប្រទេសជិតខាងផ្សេងទៀតដែលទទួលរងលក្ខខណ្ឌអាកាសធាតុមិនល្អដូចគ្នានោះ កើតមានគ្រោះអត់ឃ្លានដែរ ប៉ុន្តែមិនមានលក្ខណៈធ្ងន់ធ្ងរ ដូចប្រទេសអេត្យូពី (Ethiopia) នោះទេ ។ ជាងនេះទៅទៀត គ្រោះអត់ឃ្លានដែលបានកើតឡើងនៅក្នុងប្រទេសអេត្យូពី (Ethiopia) នៅពេលនោះ ត្រូវបានរកឃើញ ថាកើតមានឡើងនៅក្នុងតំបន់មួយជាក់លាក់ដែលតំបន់នោះជាកន្លែងរបស់ក្រុមដែលប្រឆាំងនឹងរដ្ឋាភិបាល ។ រឿងរ៉ាវស្រដៀងគ្នានេះ ក៏បានកើតឡើងផងដែរនៅក្នុងរបបខ្មែរក្រហមដែរ ។ នៅពេលដែលប្រទេសថៃឡាវ និងវៀតណាម មិនបានជួបប្រទះគ្រោះអត់ឃ្លាន ដោយសារអាកាសធាតុក្តៅហួតហែងនៅឆ្នាំ១៩៧៧ ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមនៅក្នុងឆ្នាំនោះគឺមានសភាពធ្ងន់ធ្ងរ ។ ជាលទ្ធផលនៃការរកឃើញទាំងនេះ ក្រុមអ្នកប្រាជ្ញដែលធ្វើការសិក្សាពីការអត់ឃ្លាន បានសង្កេតឃើញថា កត្តានយោបាយ សង្គម និងច្បាប់ផ្សេងៗមានសារសំខាន់ក្នុងការការពារ និងបញ្ឈប់គ្រោះអត់ឃ្លាន ដែលការរកឃើញនេះខុសគ្នាពីអ្វីដែលទ្រឹស្តីម៉ាលសឹស (Malthusian) បានលើកឡើង ។

## ការអត់ឃ្លាន និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ៖ ដំណើរដែលនៅមានកម្រិតនៅឡើយ



កងកុមារធ្វើដំណើរទៅធ្វើការងារក្នុងរបបខ្មែរក្រហម

ការផ្លាស់ប្តូរការយល់ដឹងទៅលើការអត់ឃ្លាននាសម័យបច្ចុប្បន្ននេះ កើតមានឡើងស្របពេលជាមួយនឹងការបង្កើតច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិថ្មីៗ ដែលបានបង្កើតឲ្យមានតុលាការយោធាអន្តរជាតិ នៅទីក្រុងនូរិមបឺក (Nuremberg) និងតុលាការពិសេសៗមួយចំនួនផ្សេងទៀត ដូចជា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នៅប្រទេសហូឡង់ជាដើម ។

អ្នកប្រាជ្ញមួយចំនួនដែលមានវិជ្ជាជីវៈផ្សេងៗគ្នា បានលើកឡើងថា ការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិគួរតែបង្កើតជាផ្នែកមួយក្នុងការបញ្ឈប់ការអត់ឃ្លាន ។ អ្នកប្រាជ្ញមួយចំនួនក៏បានអះអាងថា ការអត់ឃ្លានដែលបានកើតឡើងមួយចំនួនមានការពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិ ដូចជា ការអត់ឃ្លាននៅក្នុងប្រទេសអ៊ុយក្រែន (Ukraine) ដែលជាផ្នែកមួយនៃអតីតសហភាពសូវៀតបានកើតឡើងចន្លោះឆ្នាំ១៩៣២-១៩៣៣ នៅក្នុងប្រទេសអេត្យូពី (Ethiopia) ចន្លោះឆ្នាំ១៩៨២-១៩៨៥ នៅក្នុងប្រទេសកូរ៉េខាងជើងចាប់ពីទសវត្សរ៍ឆ្នាំ៩០ រហូតដល់បច្ចុប្បន្ន តំបន់ដាហ្វ៊ួរ (Dafur) នៃប្រទេសស៊ូដង់ (Sudan) ចាប់ពីឆ្នាំ១៩៨៥ រហូតដល់បច្ចុប្បន្ន និងប្រទេសសូម៉ាលី (Somalia) ចាប់ពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ។ អ្នកប្រាជ្ញមួយចំនួនទៀតក៏បានលើកឡើងដែរថា ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមក៏មានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិដែរ ។

បើទោះបីជាមានការទាមទារឲ្យមានការជំនុំជម្រះជាអន្តរជាតិទៅលើបុគ្គលទាំងឡាយដែលបានបង្កឲ្យមានការអត់ឃ្លានយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា ការអនុវត្តជាក់ស្តែងក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ពាក់ព័ន្ធនឹងការអត់ឃ្លាននៅមានលក្ខណៈតិចតួចនៅឡើយ ។ ក្រៅពីការជំនុំជម្រះទោសមន្ត្រីមួយចំនួនរបស់បក្សណាស៊ីអាឡឺម៉ង់ (Nazi) ដែលជឿថាបានបង្កឲ្យការអត់ឃ្លានទៅលើជនជាតិជ្វីស (Jews) នៅអឺរ៉ុប និងផ្នែកខ្លះនៃប្រទេសប៉ូឡូញ (Poland) ក្នុងអំឡុងនៃសង្គ្រាមលោកលើកទី២ ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតទាក់ទងនឹងការអត់ឃ្លានហាក់ដូចជាពុំត្រូវបានយកចិត្តទុកដាក់សោះ ។ ផ្ទុយទៅវិញ ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិភាគច្រើនផ្តោតតែទៅលើអំពើហិង្សាដោយផ្ទាល់ រួមមាន ការសម្លាប់រង្គាល និងការធ្វើទារុណកម្មជាដើម ។

### ការអត់ឃ្លាននៅតំបន់ដាហ្វ៊ួរ (Darfur) និងសំណុំរឿងដែលទាក់ទងនឹងលោកបាហ្សៀ (Bashir) នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ

នៅតំបន់ដាហ្វ៊ួរ (Darfur) ប្រទេសស៊ូដង់ (Sudan) តុលាការព្រហ្មទណ្ឌអន្តរជាតិបានចេញដីកាចោទប្រកាន់លោកប្រធានាធិបតីអូម៉ា អាល់បាហ្សៀ (Omar Al-Bashir) និងបក្ខពួកមួយចំនួន ទៀតពីបទឧក្រិដ្ឋកម្មមួយចំនួន ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែការបង្កលក្ខខណ្ឌរស់នៅដ៏អាក្រក់ទៅលើប្រជាជនស៊ីវិលនៅក្នុងតំបន់ដាហ្វ៊ួរ (Dafur) ។ ការអត់ឃ្លានគឺជាសមាសធាតុចម្បងមួយនៃលក្ខខណ្ឌរស់នៅ ដែលបង្កឲ្យមានការរីករាលដាលនៃជំងឺនិងការកើនឡើងនៃចំនួនអ្នកស្លាប់នៅតំបន់ដាហ្វ៊ួរ ហើយនេះក៏ទំនងជាករណីដែលអាចនាំយកលោក អាល់បាហ្សៀ និងបក្ខពួកទៅជំនុំជម្រះផងដែរ ។ នៅក្នុងករណីនេះ ការជំនុំជម្រះបានចោទប្រកាន់ថា អំពើប្រល័យពូជសាសន៍បានកើតមានឡើងប្រឆាំងនឹងជនជាតិភាគតិចហ្វ៊ួរ

*(Fur) ម៉ាសាលីត (Masalit) និងហ្សាហ្គាវ៉ា (Zaghawa) នៅតំបន់ដាហ្វ៊័រ (Dafur) ដោយការបង្កឲ្យមានលក្ខខណ្ឌរស់នៅមិនសមរម្យ ដែលប៉ះពាល់ដល់រូបរាងទៅលើក្រុមជនជាតិភាគតិច ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រយោធារបស់រដ្ឋាភិបាលស៊ូដង់ ។ នៅក្នុងដីកាចាប់ខ្លួនលោក អាល់បាហ្សៀ (Al-Bashir) លើកទីពីរបានចោទលោកពីបទផ្តាច់ផ្គត់ផ្គង់ទឹកដែលមានដាក់ថ្នាំបំពុល ការបណ្តេញចេញពីទីក្រុងដោយហិង្សា និងការជំរុញឲ្យសមាជិកនៃក្រុមជនជាតិភាគតិចតាំងទីលំនៅនៅលើទឹកដីដែលមានការជម្លៀសដោយបង្ខំ ។ នៅក្នុងសំណុំរឿងដែលបានបញ្ជូនទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានលើកឡើងពាក់ព័ន្ធនឹងស្ថានភាពនៅតំបន់ដាហ្វ៊័រ (Dafur) ដែលបានអះអាងថាសកម្មភាពទាំងឡាយដែលបង្កឲ្យមានការអត់ឃ្លានកើតឡើងនៅក្នុងតំបន់ដាហ្វ៊័រ (Dafur) គឺជាផ្នែកមួយនៃគម្រោងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលរៀបចំឡើងដោយលោកប្រធានាធិបតី បាហ្សៀ (Bashir) និងបក្ខពួករបស់គាត់ ។ នៅក្នុងការចោទប្រកាន់ដែលពាក់ព័ន្ធនឹងតំបន់ដាហ្វ៊័រ (Dafur) បានលើកឡើងថា «មានជនរងគ្រោះប្រមាណប្រាំបីម៉ឺនបីពាន់នាក់បានស្លាប់ដោយសារការរងរបួស ការបង្អត់អាហារ កង្វះទឹក ឬលក្ខខណ្ឌរស់នៅអាក្រក់ផ្សេងៗ នៅក្នុងជំរំជនភៀសខ្លួន» ចន្លោះពីខែកញ្ញា ឆ្នាំ២០០៣ ដល់ខែមករា ឆ្នាំ២០០៥ ។*

## ***ការអត់ឃ្លាននៅប្រទេសកូរ៉េខាងជើង និងការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ***

*លោក ម៉ាហ្សូគី ដារូសម៉ែន (Marzuki Darusman) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកូរ៉េខាងជើងបានផ្ញើរបាយការណ៍មួយនៅដើមឆ្នាំ២០១៣នេះ ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិដោយស្នើសុំឲ្យមានការស៊ើបអង្កេតមួយទាក់ទងនឹងការរំលោភសិទ្ធិមនុស្សនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសកូរ៉េខាងជើង ។ នៅក្នុងរបាយការណ៍នោះ លោក ម៉ាហ្សូគី ដារូសម៉ែន (Marzuki Darusman) បានលើកឡើងបញ្ហាចំនួន៩ ដែលជាប់ពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិមនុស្សនៅប្រទេសកូរ៉េខាងជើងចាប់តាំងពីឆ្នាំ២០០៤ ដែលអាចឈានទៅដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការរំលោភលើសិទ្ធិទទួលបានចំណីអាហារ «ដែលផ្តោតទៅលើគោលនយោបាយរដ្ឋពាក់ព័ន្ធនឹងការចែកចាយចំណីអាហារទៅឲ្យប្រជាជន និងការរិតត្បិតការផ្តល់ជំនួយមនុស្សធម៌អន្តរជាតិនៅពេលដែលមានវិបត្តិកង្វះស្បៀងអាហារ» ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានធ្វើការបោះឆ្នោតដើម្បីបង្កើតគណៈកម្មាការស៊ើបអង្កេតមួយដែលមានរយៈពេលមួយឆ្នាំដោយធ្វើការស៊ើបអង្កេតទៅលើការរំលោភបំពាននានាដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់លោក ដារូសម៉ែន (Darusman) ។ លទ្ធផលនៃរបាយការណ៍នេះ ទំនងជាមានឥទ្ធិពលខ្លាំងក្នុងការកំណត់ ថាតើគោលនយោបាយរបស់កូរ៉េខាងជើងដែលបង្កឲ្យមានការអត់ឃ្លានកើតឡើង អាចត្រូវបានយកមកជំនុំជម្រះទោសដែរឬទេ ។*

## ***សេចក្តីសន្និដ្ឋាន***

*ការអត់ឃ្លានធ្ងន់ធ្ងរដែលបង្កឲ្យមានជនរងគ្រោះជាច្រើននាក់ស្លាប់ដោយសារការអត់អាហារ និងជំងឺដែលពាក់ព័ន្ធនឹងការអត់ឃ្លាន បានកាត់បន្ថយនៅក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។ បច្ចុប្បន្ន ការអត់ឃ្លានធ្ងន់ធ្ងរបានកើតឡើងនៅពេលមានសង្គ្រាម ពេលមានចលាចល និងរដ្ឋាភិបាលផ្តាច់ការតែប៉ុណ្ណោះ ។ ស្ថានភាពទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញថា គ្រោះអត់ឃ្លានសម័យបច្ចុប្បន្ន មានការពាក់ព័ន្ធទៅនឹងកត្តាមនុស្ស មិនមែនកត្តាធម្មជាតិ ដែលបង្កឲ្យមានការថយចុះនូវផលិតកម្មស្បៀងអាហារនោះទេ ។ ដូចដែលបានពិភាក្សានៅក្នុងវគ្គមុនរួចមកហើយថា ការអត់ឃ្លានដែលបង្កឡើងដោយមេដឹកនាំខ្មែរក្រហម អាចចាត់ទុកជាបទឧក្រិដ្ឋបានដែលប្រឆាំងនឹងប្រជាជនកម្ពុជា បើទោះបីជាបទឧក្រិដ្ឋនេះ មិនត្រូវបានលើកយកមកជំនុំជម្រះនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ ។ ការអត់ឃ្លានដែលបានកើតឡើងថ្មីៗ ដូចជា នៅក្នុងប្រទេសសូម៉ាលី តំបន់ដាហ្វ៊័រ និងប្រទេសកូរ៉េខាងជើង អាចនឹងត្រូវបានយកមកជំនុំជម្រះទោសនៅថ្ងៃណាមួយមិនខាន ។ យើងសង្ឃឹមថាកិច្ចខិតខំប្រឹងប្រែង ផ្នែកច្បាប់ នឹងអាចជួយជំរុញឲ្យមានការបញ្ឈប់ការបង្អត់អាហារប្រជាជននៅទូទាំងពិភពលោក នៅពេលអនាគតដ៏ខ្លីខាងមុខ ។*

**រ៉ានឌល ជីហ្សាល់ក្ង, ម៉ែន ពិចិត្រ និង លន់ ដាលីន**

# សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី

### ឯកសារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយបានដាក់លិខិតលាលែងពីតំណែងរបស់ខ្ញុំជូនអគ្គលេខានៃអង្គការសហប្រជាជាតិនៅខែសីហា ឆ្នាំ២០១៣ ខ្ញុំនឹងលាឈប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ ខាងមុខនេះ ដោយសារមូលហេតុផ្ទាល់ខ្លួន ។ ខ្ញុំនឹងទៅរស់នៅជាមួយគ្រួសារខ្ញុំ ដែលបានត្រឡប់មកពីប្រទេសកម្ពុជាវិញកាលពីខែមិថុនា ឆ្នាំ២០១៣ ។ តាមការរំពឹងទុក សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង នីកូឡាស កូមជីន នឹងមកដល់ប្រទេសកម្ពុជា នៅខែតុលា ឆ្នាំ២០១៣ ។

ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកទាំងអស់នៃការិយាល័យសហព្រះរាជអាជ្ញា ដែលបានខិតខំប្រឹងប្រែងធ្វើការងាររបស់ពួកគាត់ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ ក្នុងនាមជាស្ថាប័នតុលាការមួយ និងជាការិយាល័យមួយ យើងបានប្រឈមមុខជាមួយនឹងកិច្ចការលំបាកជាច្រើនជាមួយគ្នា ។ ខ្ញុំក៏ថ្លែងអំណរគុណដល់លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ លោក យ៉ែត ចរិយា សហព្រះរាជអាជ្ញារងជាតិ និងលោក វីល្លៀម ស្មិត សហព្រះរាជអាជ្ញារងអន្តរជាតិ ដែលបានផ្តល់បរិយាកាសការងារប្រកបដោយសហប្រតិបត្តិការ និងមិត្តភាពក្នុងពេលដែលយើងធ្វើការជាមួយគ្នា ។

ខ្ញុំសូមជូនពរឲ្យតុលាការនេះដំណើរការទៅមុខបានល្អ ហើយខ្ញុំពិតជាសង្ឃឹមថា បញ្ហាហិរញ្ញវត្ថុបន្ទាន់មួយចំនួនដែលតុលាការកំពុងប្រឈមមុខ នឹងអាចដោះស្រាយបានដើម្បីសំណុំរឿងបញ្ចប់បានត្រឹមត្រូវ និងតាមពេលវេលាសមស្រប ។ ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមជាផ្នែកមួយនៃដំណើរការប្រវត្តិសាស្ត្រនេះក្នុងការនាំមកនូវយុត្តិធម៌ជូនប្រជាជនកម្ពុជា ។

**អេនឌ្រូ ខេលី**



អេនឌ្រូ ខេលី ក្នុងវេទិកាសំណួរនិងចម្លើយជាមួយសិស្សនៅវិទ្យាល័យឥន្ទ្រទេវីកាលពីខែកញ្ញា ឆ្នាំ២០០៩



អេនឌ្រូ ខេលី ធ្វើបទបង្ហាញអំពីឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមដល់និស្សិតនគរបាលនៅសាលាបណ្ឌិត្យសភានគរបាលកាលពីខែវិច្ឆិកា ឆ្នាំ២០១១




អេនឌ្រូ ខេលី, ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និង ជា លាន សហព្រះរាជអាជ្ញាជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំពុងពិភាក្សាគ្នានៅវិទ្យាល័យឥន្ទ្រទេវីក្នុងខែកញ្ញា ឆ្នាំ២០០៩ ក្នុងអំឡុងពិធីសម្ពោធពាក្យស្លោកទប់ស្កាត់របបប្រល័យពូជសាសន៍។ ពាក្យស្លោកគឺនៅហោជាងផ្នែកខាងក្រោយរូបថត។

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។




















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ទីកន្លែង ៖ អាគារ "ក" ជាន់លើ ◆ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិក ចំនួន១៣៩៩ ជំនួសឱ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់

កាលពីពាក់កណ្តាលខែសីហា អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចចុងក្រោយស្តីអំពីភាពអាចទទួលបាននៃកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិក ជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ដែលជាបញ្ហាមួយមានវិវាទយូរមកហើយក្នុងសំណុំរឿង០០២/០១ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយបានកាត់បន្ថយជាច្រើននៃចំនួនឯកសារដែលធ្លាប់បានស្នើសុំឲ្យទទួលយកលើកមុន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥២០ឯកសារ ។ ចំណែកសហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយចំនួន១១០៩ឯកសារ និងប្រតិចារិកក្នុងសំណុំរឿង០០១ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន បានជំទាស់ចំពោះបញ្ជីឈ្មោះ វិសាលភាព និងភាពអាចជឿទុកចិត្តបាននៃឯកសារទាំងនោះ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ស្នើសុំស្តាប់សក្ខីកម្មដោយផ្ទាល់មាត់របស់សាក្សីជាងមួយរយនាក់ ដែលកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងនោះ គឺបញ្ជាក់អំពីការកំណត់មុខសញ្ញានៃមន្ត្រីសាធារណរដ្ឋខ្មែរ ដែលជាបញ្ហាមួយដ៏សំខាន់ទាក់ទងទៅនឹងលទ្ធភាពរបស់ជនជាប់ចោទក្នុងការទទួលខុសត្រូវ ចំពោះការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ។

យ៉ាងហោចណាស់មានកំណត់ហេតុស្តាប់ចម្លើយចំនួន២២០ ដោយរួមបញ្ចូលទាំងឯកសារភស្តុតាងពាក់ព័ន្ធត្រូវបានស្នើដាក់ដោយសហព្រះរាជអាជ្ញា ដើម្បីបង្ហាញអំពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានតវ៉ាថា យោងទៅ លើបទដ្ឋានដែលអនុវត្តដោយតុលាការមិនអចិន្ត្រៃយ៍ផ្សេងៗទៀត (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស រ៉្វាន់ដា និងអតីតប្រទេសយូហ្គោស្លាវី) អង្គជំនុំជម្រះត្រូវតែដកចេញនូវកំណត់ហេតុទាំងឡាយណាដែលត្រូវបានបញ្ចូលជាភស្តុតាង រួមទាំង “ភស្តុតាងដែលមានភាពជិតស្និទ្ធទៅនឹងជនជាប់ចោទ” ប្រសិនបើភស្តុតាងទាំងនោះជាប់ពាក់ព័ន្ធទៅនឹងគោលបំណងផ្សេងៗទៀត ។ យោងទៅ លើក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ឯកសារកំណត់ហេតុដែលត្រូវបានដកចេញ ត្រូវតែរួមបញ្ចូលទាំងឯកសារដែលពាក់ព័ន្ធទៅនឹង “បញ្ហាដែលកំពុងមានការចាប់អារម្មណ៍” របស់ភាគីទាំងអស់ ដូចជា “រចនាសម្ព័ន្ធ អត្ថិភាព និងគោលនយោបាយនៃសហខក្រិដ្ឋកម្មរួម លក្ខខណ្ឌចាប់ផ្តើមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំលាស់ទីប្រជាជន” ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា៖

> “កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារិកដែលនឹងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកលែងតែមានអញ្ញត្តកម្ម គួរចាត់ទុកថា “មិនអនុញ្ញាតឲ្យយកមកប្រើប្រាស់តាមផ្លូវច្បាប់ឡើយ” ...ហើយមិនអាចទទួលយកបានសម្រាប់គោលបំណងនេះទេ លើកលែងតែក្រុមមេធាវីការពារក្តី បានទទួលឳកាសសួរដេញដោលអ្នកដែលបានផ្តល់ចម្លើយទាំងនេះនៅក្នុងតុលាការ” ។

អញ្ញត្តកម្មនឹងត្រូវបានផ្តល់សម្រាប់កំណត់ហេតុទាំងឡាយណាដែលបានបំពេញជាបឋមនូវភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន ដើម្បីជួយសម្រួលដល់បញ្ហាផ្សេងៗទៀត ជាពិសេសនៅពេលពុំមានឳកាសសួរតទល់ដោយសារសាក្សីទទួលមរណភាព ឬមិនអាចរកឃើញ ឬភស្តុតាងដែលស្នើសុំនោះទើបប្រមូលបាន

ឬបានផ្តល់បរិបទនៃធាតុផ្សំអប្បបរមានៃឧក្រិដ្ឋកម្មអន្តរជាតិ ។

អង្គជំនុំជម្រះបានបញ្ជាក់ថា បទដ្ឋានស្តីអំពី «អំពើ និង អាកប្បកិរិយា» គឺ «អនុវត្តតែចំពោះកំណត់ហេតុ ឬប្រតិចារិកដែល "តាមលក្ខណៈរបស់វា" នឹងបង្ហាញអំពីអំពើនិងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែលត្រូវចោទប្រកាន់តែប៉ុណ្ណោះ» ហើយពុំពង្រីកទៅដល់បញ្ហា "ស្នូល" របស់សហព្រះរាជអាជ្ញា បញ្ហា "ដែលកំពុងមានការចាប់អារម្មណ៍" នៅក្នុងវិវាទ "អំពើ និង អាកប្បកិរិយានៃអង្គការនិងស្ថាប័នដែលជនជាប់ចោទធ្វើជាសមាជិក ឬបុគ្គលទាំងឡាយដែលជនជាប់ចោទបានចូលរួមជាមួយ ឬបុគ្គលនៅក្រោមបង្គាប់ "ដែលនៅជិតស្និទ្ធបំផុត" បញ្ហាទាំងនោះនឹងត្រូវបានប្រើដើម្បីថ្លឹងថ្លែងអំពីភាពមិនអាចទទួលយកបាននៃឯកសារ ។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើសុំឲ្យទទួលយក ឯកសារកំណត់ហេតុចំនួន ២៤ ដោយរកឃើញថា មានការជាប់ពាក់ព័ន្ធតែអំពើនិងអាកប្បកិរិយារបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ ហើយទទួលយកឯកសារចំនួន១១១៤ ដោយរកឃើញថា «មានលក្ខណៈត្រួតគ្នាទៅវិញទៅមក និង/ឬភ័ស្តុតាងផ្សេងៗទៀត» និងបានបំពេញជាបឋម អំពីភាពពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗទៀតនៅក្នុងសំណុំរឿង០០២/០១ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ។ ចំពោះទំហំដែលឯកសារទាំងនោះបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទអង្គជំនុំជម្រះ «នឹងមិនពឹងផ្អែកទៅលើព័ត៌មានទាំងនេះដើម្បីបង្ហាញអំពើ ឬអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ឡើយ» ។ បន្ថែមលើនេះទៀត ការជំទាស់ផ្សេងៗទៅនឹងភាពមិនអាចជឿទុកចិត្តបាននៃឯកសារទាំងនេះ ដោយហេតុថាស្ថិតនៅក្រោមកាលៈទេសៈដែលឯកសារទាំងនោះទទួលបាន ឬ ចំណាប់អារម្មណ៍របស់ស្ថាប័នដែលជាអ្នកធ្វើការសម្ភាស ដូចជា សហព្រះរាជអាជ្ញា ឬមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងត្រូវបានពិចារណាក្នុងការវាយតម្លៃប្រសិនបើមាននៅក្នុងសាលក្រម ។

ទោះបីកំណត់ហេតុ និង ប្រតិចារិក មួយចំនួនដែលស្នើដាក់ដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធ តែអង្គហេតុស្ថិតនៅក្រៅវិសាលភាពដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ក៏ដោយក៏សហព្រះរាជអាជ្ញានៅតែអះអាងថា ការទទួលយកឯកសារទាំងនោះគឺ «មានសារសំខាន់ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាងទាក់ទងនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួម និងបរិបទដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ថា ជាទូទៅភ័ស្តុតាងទាំងនោះត្រូវតែពាក់ព័ន្ធនឹងគោលនយោបាយ និងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ។ ទោះបីជាយ៉ាងនេះក្តី ព័ត៌មានដែលស្ថិតនៅក្រៅវិសាលភាពនេះ គប្បីត្រូវទទួលយក ដែល "ជាទូទៅ" នៅពេលព័ត៌មាននោះបានផ្តល់ភ័ស្តុតាងពាក់ព័ន្ធដោយផ្ទាល់ និង/ឬទាក់ទងទៅនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ» ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះដកចេញឯកសារចំនួន១២២ ដោយរកឃើញថា ជាប់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើអង្គហេតុដែលពុំមាននៅក្នុងសំណុំរឿង ០០២/០១ ។ អង្គជំនុំជម្រះសម្រេចថាឯកសារទាំងនោះ «ពុំមានសារសំខាន់» សម្រាប់សហព្រះរាជអាជ្ញា ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាង និងស្ទួនគ្នាជាមួយឯកសារផ្សេងៗទៀតដែលត្រូវបានទទួលយក» ។

សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកចំនួន១៣៩៩ឯកសារជំនួសឲ្យការមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានធ្វើការជំទាស់ជាយូរមកហើយ ដោយថា ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុម័តយកមធ្យោបាយក្នុងការទទួលយកភ័ស្តុតាង ដែលអនុវត្តដោយតុលាការមិនអចិន្ត្រៃយ៍ផ្សេងៗទៀត «នោះតម្រូវឲ្យមានការវាយតម្លៃម្តងមួយៗ ទៅលើកំណត់ហេតុនីមួយៗ មុននឹងសម្រេចទទួលយកកំណត់ហេតុនោះ» ។

សម្រាប់ហេតុផលនេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យ "វាយតម្លៃមួយបន្ទាត់ម្តងៗ" នៃឯកសារភ័ស្តុតាងដែលមាននៅក្នុងកំណត់ហេតុដែលត្រូវបានទទួលយកនោះ ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយដោយផ្ទាល់ចំពោះការតវ៉ានេះឡើយ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ក្នុងការអនុម័តយកបទដ្ឋាននៃការទទួលយកភ័ស្តុតាងរបស់តុលាការមិនអចិន្ត្រៃយ៍

"វាពុំបាន...និងអនុម័តយកដោយពុំរើសមុខនូវបច្ចេកទេស និង លក្ខខណ្ឌតម្រូវលម្អិត ឲ្យរបស់បទដ្ឋានទាំងនោះឡើយ" ។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា (ដោយផ្អែកទៅលើភាពផ្ទុយគ្នា ដែលត្រូវបានលើកឡើងនៅក្នុងសវនាការស្តាប់សក្ខីកម្មសាក្សីលើកមុន) សុំឲ្យកោះហៅសាក្សីចំនួន១១០រូប ដែលកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងនោះបានបញ្ជាក់អំពីការកំណត់មុខសញ្ញាទៅលើមន្ត្រីសាធារណរដ្ឋខ្មែរ ហើយត្រូវបានទទួលយក ។ សំណើសុំឲ្យកោះហៅសាក្សីមួយចំនួនដែលត្រូវបានបដិសេធចោលលើកមុន និងសាក្សីដែលនៅសេសសល់ ពុំត្រូវបានស្នើទាន់ពេលវេលា ។ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា "ត្រូវបានជូនដំណឹងចាប់តាំងពីខែមេសា ឆ្នាំ២០១១" អំពីកំណត់ហេតុស្តាប់ចម្លើយដែលសហព្រះរាជអាជ្ញាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ដែលទោះបីជាទីតាំង ឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ (ជាទីតាំងតែមួយ គត់ដែលនិយាយអំពីការកំណត់មុខសញ្ញាទៅលើមន្ត្រីរបស់របបសាធារណរដ្ឋខ្មែរ) មិនត្រូវបានដាក់បញ្ចូលរហូតមកដល់ខែតុលា ឆ្នាំ២០១២ និងវិសាលភាពដែលត្រូវចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ទើបតែត្រូវកំណត់ជាស្ថាពរនៅខែមុនក៏ដោយ ។

ជាច្រើនថ្ងៃមុនពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចនេះ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា តវ៉ាថា ដោយសាររយៈពេលសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កំពុងខិតជិតមកដល់ការខកខានក្នុងការកំណត់ចំពោះឯកសារដែលត្រូវទទួលយក គឺបានបង្កើតនូវ "ការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន" ។ បន្ថែមលើនេះទៀត សេចក្តីសម្រេចទាំងអស់ដែលត្រូវបានប្រកាស "ពេលវេលាដែលត្រូវការសម្រាប់ពិនិត្យមើលឲ្យសេចក្តីសម្រេចទាំងនោះ" ធ្វើឲ្យមេធាវីការពារក្តី នួន ជា ចំណាយពេលអស់ពីរសប្តាហ៍" ហើយ នៅដំណាក់កាលនេះ "បានបង្កឲ្យមានភាពលម្អៀងយ៉ាងធ្ងន់ធ្ងរទៅលើលទ្ធភាពជនជាប់ចោទ នួន ជា ក្នុងការត្រៀមរៀបចំការពារខ្លួន" ។ ដូច្នេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យបន្ថែមពេលវេលាសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់មិនតិចជាងប្រាំមួយសប្តាហ៍ ចាប់រាប់ពីកាលបរិច្ឆេទដែលសេចក្តីសម្រេចទទួលយកឯកសារនោះបានចេញ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយចំពោះសំណើសុំនេះឡើយ ។

**អាន ហាញឌុល**

# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# សហព្រះរាជអាជ្ញាស្នើសុំការបញ្ជាក់អំពីវិសាលភាពនៃបទចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១

មុននឹងឈានដល់ការធ្វើសេចក្តីសន្និដ្ឋានបិទលើសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញាបានស្វែងរកការបំភ្លឺពីអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលស្ថិតនៅក្រៅពីអង្គហេតុនៃសវនាការដំណាក់កាលដំបូងនិងក៏ប្រហែលជាដំណាក់កាលចុងក្រោយនៃសវនាការសំណុំរឿង ០០២ ក្រោមការខិតខំប្រឹងប្រែងចុងក្រោយដើម្បីពង្រីកវិសាលភាពនៃបទចោទប្រឆាំងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិត ។

ជនជាប់ចោទដែលមានឈ្មោះនៅក្នុងដីកាចោទប្រកាន់ក្នុងសំណុំរឿង០០២ សុទ្ធតែមានអាយុច្រើនជាង៨០ឆ្នាំ ហើយអ្នកទាំងនោះត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ដែលប្រព្រឹត្តឡើងក្នុងរូបភាពជាផ្នែកនៃការអនុវត្តសហឧក្រិដ្ឋកម្មរួម តាមរយៈគោលនយោបាយកម្រិតខ្ពស់ទាំងប្រាំមានដូចជា ៖ ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ការបង្កើត និងប្រតិបត្តិការងារនៅក្នុងសហករណ៍ ការអប់រំកសាង "សមាសភាពអាក្រក់" និងការសម្លាប់ "សត្រូវ" ខាងក្នុងនិងខាងក្រៅ បក្សកុម្មុយនីស្តកម្ពុជា កំណត់គោលដៅលើជនជាតិចាម វៀតណាម អ្នកកាន់សាសនាព្រះពុទ្ធនិងអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងការដាក់កំហិតឲ្យរៀបអាពាហ៍ពិពាហ៍ ។ មុនពេលចាប់ផ្តើមសវនាការ អង្គជំនុំជម្រះសាលាដំបូងបានពន្លឿនកិច្ចដំណើរការនីតិវិធីដើម្បីទទួលបាននូវសាលក្រមមួយដោយធ្វើឲ្យក្លាយជាតុលាការអន្តរជាតិដំបូងបើកសវនាការជំនុំជម្រះដោយផ្អែកលើការចោទប្រកាន់រួមគ្នា ប៉ុន្តែជាលទ្ធផល ការធ្វើដូច្នេះបណ្តាលឲ្យមានការចោទសួរជាច្រើនអំពីនីតិវិធីដែលមានភាពស្មុគស្មាញ និងមិនត្រូវបានដោះស្រាយ ។

សវនាការដំណាក់កាលដំបូង ដែលស្គាល់ថាជាសំណុំរឿង ០០២/០១ ជាប់ទាក់ទងនឹងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទនៅមុន និងក្នុងអំឡុងរបបនេះ ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចំនួនពីរលើកដែលត្រូវចោទប្រកាន់ និងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ។ អង្គជំនុំជម្រះសាលាដំបូងលើកឡើងថា សំណុំរឿងនេះមិនត្រឹមតែអាចរួមបញ្ចូល "ការពិចារណាលើអង្គហេតុដោយលម្អិត" តែទៅលើបទចោទទាំងនេះ ប៉ុន្តែក៏អាច "ផ្តល់នូវមូលដ្ឋានសម្រាប់ការពិនិត្យយ៉ាងលម្អិតថែមទៀតទៅលើបទចោទដែលនៅសេសសល់ និងអង្គហេតុដែលចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងដំណាក់កាលក្រោយៗ" ។ សម្រាប់ហេតុផលនេះ អង្គជំនុំជម្រះអាច "ផ្តល់ការពិចារណាចំពោះតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទនៅក្នុងទំនាក់ទំនងគោលនយោបាយទាំងអស់ដែលពាក់ព័ន្ធនៅក្នុងដីកាចោទប្រកាន់ទាំងមូល" ។ ដោយហេតុផលថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ចប់ពីវិសាលភាពនៃបទចោទនៅក្នុងឆ្នាំទីមួយនៃសវនាការដែលពុំបាន (ប្រសាសន៍របស់អង្គជំនុំជម្រះតុលាការកំពូល) បញ្ជាក់ឲ្យច្បាស់លាស់ពីផែនការ "ជាក់ស្តែង" សម្រាប់ការជំនុំជម្រះពីបទចោទក្នុងសំណុំរឿង០០២ ដែលនូវសេសសល់ និងពុំបានបញ្ជាក់ពីនីតិវិធីរបស់ភាគី និងភាពយុត្តិធម៌ដែលជាប់ពាក់ព័ន្ធនឹងវិធីបញ្ជាក់ពីបញ្ហាអង្គហេតុ និងអង្គច្បាប់ក្នុងសំណុំរឿង០០២/០១ អាចបម្រើដល់មូលដ្ឋានសម្រាប់ចោទប្រកាន់នៅក្នុងដំណាក់កាលទីពីរ ។ ជានិច្ចជាកាលមិនប្រាកដថាទាក់ទងនឹងការកំណត់ភ័ស្តុតាងជាក់លាក់នៃគោលនយោបាយដែលស្ថិតនៅក្រៅសំណុំរឿង០០២/០១ ។

បញ្ហាគឺថា ដើម្បីធ្វើយុត្តិកម្មលើភាពយឺតយ៉ាវក្នុងការសម្រេចចិត្តរបស់ ខៀវ សំផន ដែលមិនឆ្លើយតបសំណួរនៅពេលបិទបញ្ចប់សវនាការ មេធាវីរបស់ ខៀវ សំផន បានបង្ហាញពីកង្វល់ថា "សំណួរដែលនឹងត្រូវចោទសួរជនជាប់ចោទ ហាក់ដូចជាផាកចេញពីវិសាលភាពនៃសវនាការដំណាក់កាលទីមួយ ក្រោមលេសថា បទចោទទាំងនោះជាប់ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ឬរចនាសម្ព័ន្ធរដ្ឋបាល" ។ ក្រោយមក មេធាវីបានលើកឡើងថា ខ្លួនមានការ

“តក់ស្លុត” ដែលអង្គជំនុំជម្រះសាលាដំបូង “ជូនដំណឹងដ៏ភ្ញាក់ផ្អើលថា នោះជាការវិនិច្ឆ័យដោយមានការទទួលខុសត្រូវរបស់ ខៀវ សំផន នៅក្នុងសវនាការដំណាក់ទីមួយ ជាប់ទាក់ទងនឹងគោលនយោបាយឧក្រិដ្ឋកម្មទាំងអស់ដែលប្រព្រឹត្តដោយរបប ប៉ុល ពត” ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានសម្តែងអារម្មណ៍ភ្ញាក់ផ្អើលថា “បើទោះបីជាឯកសារជាច្រើនចេញដោយអង្គជំនុំជម្រះ និងការធ្វើសេចក្តីបង្គាប់ផ្ទាល់មាត់លើបញ្ហានេះ វិសាលភាពសវនាការដំណាក់ការទីមួយនេះហាក់ដូចជានៅតែធ្វើឲ្យភាគីមេធាវីការពារក្តីមានភាពស្រពិចស្រពិល” ។ តាមរយៈការឆ្លើយឆ្លងគ្នារវាងភាគី និងអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការកាលពីខែមុន សហព្រះរាជអាជ្ញាដាក់ជូន “សំណើសុំការបំភ្លឺនេះទាក់ទិននឹងការរកឃើញផ្នែកអង្គហេតុ និងការសន្និដ្ឋានអង្គច្បាប់ដែលនឹងត្រូវធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងស្តីពីគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលមិនទាក់ទងនឹងបទចោទដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១” ។

ភាគីដែលព្យាយាមបញ្ជាក់គោលបំណងនៃសេចក្តីសម្រេចបំបែកសំណុំរឿងបានចាប់ផ្តើមតាំងពីពេលសវនាការដំបូងនៅពេលដែលទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះលើកឡើងថា ៖

> ទាក់ទងនឹងការសួរដេញដោលពីគោលនយោបាយផ្សេងៗក្រៅពីគោលនយោបាយដែលជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ គោលបំណងនៃការរួមបញ្ចូលការលើកឡើងគោលនយោបាយផ្សេងៗទាំងនោះនៅក្នុងសវនាការដំណាក់កាលដំបូងគឺដើម្បីឲ្យមានលទ្ធភាពបង្ហាញពីរបៀបដែលគោលនយោបាយនៃការជម្លៀសប្រជាជនដោយបង្ខំត្រូវបង្កើតឡើង ។ ដូច្នេះ អ្វីដែលរំពឹងទុកគឺការបង្ហាញជាទូទៅពីគោលនយោបាយទាំងប្រាំ ទោះជាបញ្ហាជាក់ស្តែងសម្រាប់សួរដេញដោលនៅក្នុងសវនាការដំណាក់កាលដំបូងត្រូវកម្រិតនៅត្រឹមការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទី១ និងទី២) ក៏ដោយ ។ ស្របគ្នាដែរ ដែលថានឹងគ្មានការសួរដេញដោលពីការអនុវត្តគោលនយោបាយក្រៅពីការជាប់ទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទី១ និងទី២) ។ ជារួម ភាគីបានដាក់សំណើដោយផ្តោតទៅលើការតាំងសំណួរលម្អិតរបស់ខ្លួនស្តីពីអង្គហេតុពាក់ព័ន្ធនឹងសវនាការវគ្គមួយ ។ ប្រធានបទដែលត្រូវដាក់បញ្ចូលនៅក្នុងសវនាការនាពេលក្រោយពុំត្រូវអនុញ្ញាតឲ្យពិភាក្សានោះទេ ។

រយៈពេលមួយឆ្នាំនៅក្នុងកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមបទចោទប្រកាន់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ ជាកន្លែងដែលខ្មែរក្រហមសម្លាប់អតីតទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរអស់រាប់រយនាក់ ។ សេចក្តីសម្រេចនៅពេលក្រោយបានបញ្ជាក់ថា បទចោទទាំងនេះត្រូវអនុញ្ញាតឲ្យពិភាក្សាពីគោលការណ៍ចោទប្រកាន់មួយទៀតនៅក្នុងដីការចោទប្រកាន់ ៖ “ការសម្លាប់ដែលអះអាងថាជាសត្រូវនៃរបប” ។ ស្របពេលជាមួយគ្នា អង្គជំនុំជម្រះសាលាដំបូងបានអះអាងដោយមិនពេញលេញថា ៖ “ដើមដំបូង អង្គជំនុំជម្រះបានសម្រេចថា ភាគីទាំងអស់អាចបង្ហាញភស្តុតាងទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងគោលនយោបាយនៃរបបខ្មែរក្រហម” ។

ក្នុងការអនុវត្តអំឡុងពេលបើកសវនាការ អង្គជំនុំជម្រះសាលាដំបូង ជាទូទៅតែងតែកំហិតការពិភាក្សាអំពីភស្តុតាងទាក់ទងនឹងគោលនយោបាយជាងការផ្លាស់ទីលំនៅដោយបង្ខំជាមួយនឹងករណីលើកលែង ដែលគួរឲ្យកត់សម្គាល់របស់អ្នកជំនាញ និងសាក្សីមានវ័យចំណាស់ៗ ។ ជាការពិត នៅខែមុន អង្គជំនុំជម្រះបានថ្លែងថា ៖

> នៅក្នុងកិច្ចដំណើរការនីតិវិធី ភាគីទាំងអស់ត្រូវបង្គាប់ឲ្យដាក់កំហិតត្រឹមភស្តុតាងដែលមានភាពពាក់ព័ន្ធដោយផ្ទាល់នឹងសំណុំរឿង០០២/០១ប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះ អង្គជំនុំជម្រះបានទទួលយកភស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងទីតាំងឧក្រិដ្ឋកម្មនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ជាធម្មតា នៅពេលភស្តុតាងនេះទទួលបានក្នុងលក្ខណៈជាភស្តុតាងដែលពាក់ព័ន្ធដោយផ្ទាល់មួយផ្នែក និង/ឬនៅពេល

> ភ័ស្តុតាងនេះពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មលើជនរងគ្រោះ ។

យោងតាមការពិភាក្សាខាងលើ ការរួមបញ្ចូលភ័ស្តុតាងជាប់ពាក់ព័ន្ធ ដែលបង្ហាញពីអត្ថិភាព និងការបង្កើតនូវគោលនយោបាយបីដែលស្ថិតនៅក្រោមសំណុំរឿង០០២/០១ ត្រូវញែកឲ្យដាច់ពីភ័ស្តុតាងដែលបង្ហាញពីការអនុវត្តគោលនយោបាយទាំងនោះនៅមូលដ្ឋានគឺ “មិនជាប់ពាក់ព័ន្ធ” នឹងសំណុំ រឿងដំណាក់កាលដំបូងទេ ។ ប៉ុន្តែ បញ្ហឹងកសារភ័ស្តុតាងពុំទាន់មានភាពច្បាស់លាស់ និងជាក់លាក់នៅឡើយ ។ នៅថ្ងៃចុងក្រោយនៃសវនាការ ទាំងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អត្ថិភាពនៃភ័ស្តុតាងគោលនយោបាយសហឧក្រិដ្ឋកម្មរួមទាំងនេះ ចាំបាច់ត្រូវរួមបញ្ចូលភ័ស្តុតាងនៃការអនុវត្ត ។ ឧទាហរណ៍ក្នុងអំឡុងពេលសវនាការដាក់ឯកសារ សហព្រះរាជអាជ្ញាសង្កត់ធ្ងន់ទៅលើ“ការជាប់ពាក់ព័ន្ធគ្នារវាងគោលនយោបាយនិងការអនុវត្តគោលនយោបាយ” ហើយព្រះរាជអាជ្ញាបានកត់សម្គាល់ថា លក្ខណៈមួយដែលបង្ហាញអំពីគោលនយោបាយដែលមានអត្ថិភាពត្រូវបង្ហាញថា គោលនយោបាយនោះត្រូវបានយកមកអនុវត្តនៅថ្នាក់មូលដ្ឋានដោយកម្មាភិបាលថ្នាក់ក្រោម ដូចៗគ្នានៅគ្រប់ទីកន្លែង ។ មេធាវីការពារក្តីតវ៉ាថា ៖

> យើងមាននៅចំពោះមុខយើងនៅថ្ងៃនេះ នៅក្នុងពាក្យពេចន៍ច្បាស់លាស់ ស្ថានភាពដែលសហព្រះរាជអាជ្ញានិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កំពុងជម្រាបអង្គជំនុំជម្រះថា យើងមិនអាចនិយាយអំពីគោលនយោបាយបីផ្សេងទៀតដែលមិនជាប់ទាក់ទងនឹងសំណុំរឿង០០២/០១ ដោយមិននិយាយអំពីការអនុវត្តនៅតាមមូលដ្ឋានទេ ។ តើការនិយាយតាមផ្លូវច្បាប់មានន័យដូចម្តេច? វាមានន័យថា យើងត្រូវផ្តល់សិទ្ធិនៅក្នុងវិធីណាមួយឬតាមវិធីផ្សេងទៀតតាមរយៈការបង្ហាញភ័ស្តុតាងនៅក្នុងសំណុំរឿងនេះស្តីពីគោលនយោបាយដែលមិនជាប់ពាក់ព័ន្ធនឹងសំណុំ រឿង០០២/០១ ។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា ភ័ស្តុតាងមួយចំនួន ចង្អុលបង្ហាញទាំងអត្ថិភាព ឬការវិវត្តនៃគោលនយោបាយនិងការអនុវត្តគោលនយោបាយ» ។ ប៉ុន្តែអង្គជំនុំជម្រះបានលើកឡើងជាថ្មីថា មានតែអត្ថិភាពនិងការបង្កើតគោលនយោបាយដែលស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង០០២/០១ប៉ុណ្ណោះដែលអង្គជំនុំជម្រះនឹងលើកយកមកពិចារណានៅក្នុងសាលក្រម ។

នៅក្នុងសំណើសុំឲ្យមានការបញ្ជាក់ សហព្រះរាជអាជ្ញាបានផ្តល់យោបល់បន្ថែមដើម្បីស្វែងរកការពង្រីកចំនួននៃគោលនយោបាយនៅក្នុងការវិនិច្ឆ័យសំណុំរឿង០០២/០១ ដោយលើកអំណះអំណាងថា ដើម្បីឲ្យយល់ច្បាស់ពីបរិបទនៃការផ្លាស់ទីលំនៅដោយបង្ខំលើកទីពីរ ចាំបាច់ត្រូវយល់ច្បាស់ពីគោលនយោបាយការងារនៅក្នុងសហករណ៍ ដែលមានការជាប់ទាក់ទងដោយផ្ទាល់ ។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងច្រានចោលសំណើរបស់សហព្រះរាជអាជ្ញាដោយបញ្ជាក់ជាថ្មីថា មានគោលនយោបាយតែពីរគត់នៅក្នុងការពិភាក្សាសំណុំរឿង០០២/០១ គឺការផ្លាស់ទីលំនៅដោយបង្ខំ និងការកំណត់គោលដៅសម្លាប់សត្រូវនៃរបប ។ ដើម្បីមានភាពច្បាស់លាស់លើបញ្ហានេះ អង្គជំនុំជម្រះលើកឡើងវិញនូវការណែនាំរបស់អ្នកប្រឹក្សាផ្នែកច្បាប់របស់អង្គបុរេជំនុំជម្រះថា ៖ “ការបង្ហាញលក្ខខណ្ឌទូទៅនៃគោលនយោបាយទាំងប្រាំអាចអនុញ្ញាតឲ្យមានលទ្ធភាពពិចារណាពីលក្ខណៈដែលគោលនយោបាយត្រូវបង្កើត” ។ នៅក្នុងទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូង “ពុំមានការបន្ថែមភាពជាក់លាក់ ដូចជាការតម្រូវឲ្យចាត់ថ្នាក់គោលនយោបាយសហឧក្រិដ្ឋកម្មរួមនៅពេលនេះទេ ។

**អាន ហាញឌុល**





# ទណ្ឌិត ផ្លែល្ពៅ

រូបគំនូរដោយអ្នកនិពន្ធ ឆាយ ស៊ីផាត្រ

**(តពីលេខមុន)**

**២៧) មន្ទីរពេទ្យវណ្ណៈអធន កសិករ កម្មករ**

ដោយត្រូវទឹកភ្លៀង និងការត្រាំក្នុងទឹកជារៀងរាល់ថ្ងៃ ជាមួយនឹងពលកម្មហួសកម្លាំង និងកង្វះអាហារ ខ្ញុំចុះស្គមយ៉ាងខ្លាំង រហូតដល់ថ្ងៃមួយខ្ញុំធ្លាក់ខ្លួនឈឺទៅធ្វើការពុំរួច ។ ប៉ុន្តែមិត្តសិន បានមកពិនិត្យខ្ញុំដល់កន្លែងដើម្បីឲ្យដឹងថា តើជាជំងឺសតិអារម្មណ៍ឬជាជំងឺមែនទែន ។ នៅទីនោះ បើយើងឈឺហើយហូបបាននោះគឺពុំជឿទេ អង្គការនឹងចោទថា យើងដេកជ្រុំជ្រួលរមួលជ្រុំគ្រេច ហើយនឹងកាត់របបអាហាររបស់យើង ។ នៅទីនេះគឺមិនដែលនិយាយពីមនោសញ្ចេតនាទេ មានតែនិយាយតែពីការប្រយុទ្ធសម្រុកការងារសស្រាកសស្រាំ ព្រោះគ្រប់គ្នាជាឧបករណ៍ផ្តាច់ការ វណ្ណៈអធនមិត្ត សិន ស្ទាបខ្ញុំឃើញក្តៅខ្លាំងទើបបញ្ជាឲ្យយុវជនបួននាក់រៀបអង្រឹងសែងខ្ញុំយកទៅពេទ្យ ។

មន្ទីរពេទ្យឃុំនៅឆ្ងាយពីដីរំប្រហែល១៥គីឡូម៉ែត្រ យុវជនទាំងបួននាក់ដែលមានមាឌមាំៗ បានគ្រាខ្ញុំដាក់លើអង្រឹងហើយសែងខ្ញុំ ។ ការសែងខ្ញុំរបៀបនេះ ពុំមែនជាការងាយស្រួលទេ ព្រោះគាត់ទាំងអស់គ្នាត្រូវរត់បណ្តាក់គ្នា ម្យ៉ាងទៀតក៏ហត់នឿយ និងហូបមិនគ្រប់គ្រាន់ដូចខ្ញុំដែរ ។ ខ្ញុំនឹកស្មានថា នៅមន្ទីរពេទ្យច្បាស់ជាមានអគារពិសេសធ្វើពីបេតុង និងមានកន្សាទឹក ហើយបុគ្គលិកពេទ្យស្លៀកពាក់ពណ៌ស ពាក់មួកកន្ទប វេជ្ជបណ្ឌិតពាក់វ៉ែនតាស នៅនឹងកមានស្តេតូស្កុប ដូចពេទ្យនៅទីក្រុងដែរ ។ ខ្ញុំស្មានទៀតថា ខ្ញុំនឹងទទួលការព្យាបាលដោយថ្នាំវេជ្ជសាស្ត្រ ព្រមទាំងទទួលការថែបំប៉ន ដោយ

ម្ហូបអាហារល្អៗដែរ ។ នៅពេលទៅដល់មន្ទីរពេទ្យ ខ្ញុំមានការខកចិត្តជាខ្លាំងពេលដឹងថាមន្ទីរពេទ្យស្ថិតនៅក្នុងបរិវេណវត្តមួយឈ្មោះថា វត្តដំរីស គឺយកកុដិលោកធ្វើជាសាលដាក់អ្នកជំងឺ ចំណែកគ្រែដេក ធ្វើអំពីឫស្សី ។ នៅទីនោះ មានអ្នកជំងឺប្រហែលជាងមួយរយនាក់ ដេកត្រៀបត្រាលើគ្រែឫស្សី ។ នៅក្បែរគ្រែឃើញតែកំអួត និងធុំក្លិន ស្អុយឆ្អាបលាមកដែលមិនបានលាងជម្រះ ។ អ្នកជំងឺដណ្តប់ភួយ កញ្ចាស់ប្រុកនុបដែលមិនបានបោកសម្អាត ។ អ្នកទាំងបួនបានដាក់ ខ្ញុំលើគ្រែឫស្សីមួយដែលក្រាលកន្ទេលស្លឹកត្នោតប្រឡាក់ដោយ ស្នាមខ្មៅ រីឯខ្នើយដេកក៏មានក្លែលយ៉ាងក្រាស់ ។ ពេទ្យបដិវត្តន៍ដ៏ ក្មេងអាយុប្រមាណ១៨ឆ្នាំ កាន់ថាស សឺរ៉ាំងបានអង្គុយក្បែរខ្ញុំ ហើយចាប់ដៃខ្ញុំដោយប្រាប់ឲ្យដេកស្ងៀមរួចយកសឺរ៉ាំងបូមថ្នាំ ដែលស្ងួនៅក្នុងឃុំមូលដ្ឋាន រុំដោយថង់ ប្លាស្ទិក និងចងកៅស៊ូ ។ ខ្ញុំ ភ្ញាក់យ៉ាងខ្លាំង ហើយដកដៃចេញព្រោះមិនធ្លាប់ឃើញការចាក់ របៀបនេះ ។ មិត្តនារីបើកភ្នែកធំៗសម្លក់មកខ្ញុំ ហើយស្រែកជិតាល ខ្លាំងថា «ទីនេះជាមន្ទីរពេទ្យវណ្ណៈអធនរបស់កសិករ កម្មករ មិត្តឯង គ្មានសិទ្ធិនឹងមើលស្រាលបានទេ យ៉ាងម៉េចមិត្តឯងស្មានថា បដិវត្តន៍ គ្មានពេទ្យ ដែលសម្បូរបែបដូចរបស់សក្តិភូមិឬ?»

ខ្ញុំឆ្ងល់ណាស់ មិត្តនារីសុទ្ធតែមិនចេះអក្សរ តែសំនួនវោហារ របស់មិត្តនារីពេទ្យនេះខ្ពង់ខ្ពស់ណាស់ ដូចអ្នកដែលមានការអប់រំ ខ្ពង់ខ្ពស់អ៊ីចឹង ។ ខ្ញុំនៅស្ងៀមបណ្តោយឲ្យមិត្តនារីចាក់ថ្នាំតាមចិត្ត របស់គាត់ ។ ខ្ញុំសន្លប់ជាច្រើនម៉ោងដោយប្រតិកម្មថ្នាំដប ។ ពេល ដឹងខ្លួនឡើងក៏ឃើញកំអួតនៅពាសពេញខ្លួន និងខ្នើយ ។ មិត្តនារី ដែលចាក់ថ្នាំឲ្យខ្ញុំនោះឈ្មោះថា មិត្ត គួន ។ គាត់មានរូបរាងមិនស្អាត ទេ តែសម្តីអាក្រក់គ្រោតគ្រាតណាស់ ។ គាត់បានដាក់បបរនៅក្បែរ ខ្ញុំហើយដើរចេញទៅបាត់ទៅ ។ នៅក្បែរខ្ញុំ យុវជនម្នាក់ដេកស្តូកស្តឹង ដោយស្ថានភាពជំងឺធ្ងន់ធ្ងរពេក ។ រីឯអ្នកជំងឺស្ត្រីម្នាក់ទៀតនៅ ខាងស្តាំក៏ក្អួតពេញដីផងដែរ ។ ក្លិនបបរលាយទ្បំ និងក្លិនកំអួតមិន បានធ្វើឲ្យខ្ញុំឃ្លានសោះឡើយ ក៏ប៉ុន្តែ ឆន្ទៈមោះមុតចង់រក្សាជីវិត ដើម្បីយកដំណឹងអំពីឪពុកម្តាយប្រាប់ដល់បងប្អូនដទៃទៀត បង្ខំឲ្យ ហុតបបរនោះទាំងលំបាក ។

តាមពិតនារីពេទ្យក្មេងទាំងនោះ សុទ្ធតែត្រូវជ្រើសរើសពី វណ្ណៈកសិករដែលមិនបានរៀនសូត្រអ្វីទេ អ្នកទាំងនោះមិនចេះអក្សរ និងមិនស្គាល់ពីភាពស៊ីវិល័យនៃទីក្រុងឡើយ ហើយចង់ចេះចង់ដឹង ណាស់ ។ អង្គការបានបណ្តោយឲ្យពេទ្យវ័យក្មេងទាំងនេះយកអ្នកជំងឺ សម្រាប់អនុវត្ត ការព្យាបាល និងចាក់ថ្នាំ ។ ហេតុដូច្នេះហើយបាន ជាម្នាក់ៗចង់ចាក់ថ្នាំខ្លាំងណាស់ ទោះជាជំងឺនោះជាជំងឺ អ្វីក៏ដោយ ចំណែកថ្នាំទៀតសោត គឺជាពពួកឫសឈើសំបកឈើយកមក ចម្រាញ់ក្នុងឡដែលមិនត្រឹមត្រូវតាមក្បួនឱសថសាស្ត្រអ្វីឡើយ ។

នៅមន្ទីរពេទ្យអធនវត្តដំរីសនេះ ខ្ញុំសង្កេតឃើញមានពេទ្យ នារីប្រហែលជាងដប់នាក់ ។ ប្រធានមន្ទីរពេទ្យដែលមានអាយុ ប្រមាណ២៨ឆ្នាំជានារីស្រគត់ស្រគំពុំសូវនិយាយស្តី តែកម្រឃើញ វត្តមានរបស់គាត់នៅទីនេះណាស់ ។ ខ្ញុំតែងព្យាយាមគេចចេញពី ការចាក់ថ្នាំដបនេះដោយខ្ញុំផឹកថ្នាំឫសឈើវិញ ។ ចំពោះរបបអាហារ មានបបរមួយវែក មួយថ្ងៃពីរដង ។ ខ្ញុំក៏លួចចេញទៅក្រៅរបងវត្ត ក៏ប្រទះឃើញផ្លែត្របែក ទុំចោលក្លិនក្រអូប ខ្ញុំក៏ដើររើសផ្លែត្របែក នោះបរិភោគរហូតឆ្អែតក៏ទទួលអារម្មណ៍ថា មានកម្លាំងព្រោះរសជាតិ ផ្អែម វាមានវិតាមីនជំនួសជាតិស្ករដែលយើងមិនដែលទទួលបាន ជាយូរណាស់មកហើយ ។

ជារៀងរាល់ថ្ងៃក្រោយពេលផឹកថ្នាំរួច ខ្ញុំតែងតែលបចេញ ទៅក្រោយដើម្បីរើសផ្លែត្របែកទុំបរិភោគ ។ វាបានជួយឲ្យខ្ញុំមាន កម្លាំងជាងមុន ចំណែកអ្នកជំងឺដទៃទៀតដែលពុំបានដឹងពីអាថ៌កំបាំង នេះក៏បានស្លាប់បន្តបន្ទាប់ ។ ជារៀងរាល់ថ្ងៃ ខ្ញុំតែងឃើញឈ្លប សែងសពចេញមកទៅកប់នៅរបងវត្តដំរីស យ៉ាងតិចដប់ប្រាំនាក់ ហើយការដឹកជញ្ជូនអ្នកជំងឺចូលតាមរទេះគោនិងសែងអង្រឹក៏ចូលជា ហូរហែ ។

ក្នុងចំណោមមិត្តនារីពេទ្យក្មេងៗទាំងនោះមានអ្នកខ្លះស្លូត បូតក៏ប៉ុន្តែ មិត្ត គួន ពុំដែលមានអារម្មណ៍ល្អជាមួយខ្ញុំទេ គាត់តែងតែ ស្តីឲ្យខ្ញុំដេកទ្រមក់ ជំងឺសតិអារម្មណ៍ ជាពិសេសគឺ ខ្ញុំរកលេសពុំឲ្យគាត់ ចាក់ថ្នាំ ។ មិត្ត គួន តែងតែតាមដានខ្ញុំជានិច្ចរហូតដល់ពេលមួយ គាត់ចាប់ខ្ញុំបាន នៅពេលខ្ញុំដើររើសផ្លែត្របែកនៅក្រៅរបងវត្ត ។ មិត្ត គួន ស្តីឲ្យខ្ញុំដោយពាក្យអសុរសថា មិត្តឯងជាខ្មាំងប្រឆាំងបដិវត្តន៍ ជាជំងឺសតិអារម្មណ៍មកណេះ ទៅជួបនឹងបងធំជាមួយខ្ញុំ ។ ពេលនោះ ខ្ញុំត្រូវ មិត្ត គួន ចាប់អូសដៃយកទៅជួប មិត្ត លីម ជាប្រធានមន្ទីរ ពេទ្យ ។ មិត្ត លីម សម្លឹងមុខខ្ញុំដោយហួសចិត្ត ។



នារីពេទ្យនៅក្នុងរបបខ្មែរក្រហម

តើមិត្តឯងដឹងទេ ផ្លែត្របែកវាធ្វើឲ្យយើងលាប់ជំងឺ រឹងថ្គាមស្លាប់ នោះបើខ្ញុំរាយការណ៍អំពីមិត្តទៅអង្គការថ្នាក់លើនោះវាសនារបស់មិត្តមិនដឹងទៅជាយ៉ាងណា ។ ខ្ញុំស្តាប់ មិត្ត លីម កសាងដោយស្ងៀមស្ងាត់ ។ នៅស្រុកនេះជឿថា បើយើងគ្រុនហើយ គឺត្រូវតមនំបញ្ចុក ត្របែកទុំ ដំឡូងជ្វា ទឹកត្នោតផ្អែម ។ល ។ ព្រោះវានឹងនាំឲ្យលាប់ជំងឺរឹងថ្គាមស្លាប់ ប៉ុន្តែខ្ញុំពុំដែលជឿជំនឿអស់នោះទេ ។ ខ្ញុំគិតថា ការដែលតមអាហារដែលសម្បូរទៅដោយប្រូតេអ៊ីន និងវីតាមីននេះហើយដែលធ្វើឲ្យអ្នកជំងឺកាន់តែខ្សោយ ហើយឆាប់ស្លាប់ណាស់ទៅទៀត ។ មិត្ត លីម បន្តថា ឥឡូវនេះមិត្តបានគ្រាន់បើហើយអាចដើរបាន ខ្ញុំនឹងចេញសំបុត្រឲ្យមិត្តចាកចេញពីមន្ទីរពេទ្យព្រោះពុំអាចទុកមិត្តឲ្យដើរហើរសេរីតទៅទៀតទេ ។ មិត្ត លីម បានឲ្យក្រដាសប៉ុនបាតដៃមកខ្ញុំហើយក៏ចាកចេញពីមន្ទីរពេទ្យ ។ នៅទីនោះ មិត្ត លីម ជាអ្នកចេះអក្សរគ្រាន់បើជាងគេ ទោះបីជាគាត់សរសេរខុសខ្លះក៏ដោយ ។ មន្ទីរពេទ្យនេះគ្មានឯកសារតាមដានជំងឺ ឬក៏ជាប្រវត្តិរបស់អ្នកជំងឺថាមកពីទីណា ឈ្មោះអ្វីនោះទេ នោះគឺជាកន្លែងដែលយកអ្នកជំងឺពីការដ្ឋានឬសហករណ៍យកមកបោះចោលតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែនោះក៏ល្អម្យ៉ាង ដែរសម្រាប់ខ្ញុំ ខ្ញុំបានសម្រេចចិត្តថា នឹងមិនវិលត្រឡប់ទៅមណ្ឌលយុវជនឈានមុខដាច់ខាតវិញទេ ខ្ញុំធ្វើដំណើរយឺតៗដៃកាន់ឈើច្រត់សំដៅទៅសហករណ៍កោះកណ្តាល ជាទីកន្លែងដែលឪពុកម្តាយខ្ញុំបានចែកឋាន ។

## ២៨) អាក្បត់

នៅសហករណ៍កោះកណ្តាល គ្មាននរណាមើលខ្ញុំស្គាល់ឡើយ ។ សក់ក្បាលខ្ញុំត្រូវកោរត្រងោលព្រោះមានចៃច្រើនពេក ដងខ្លួនពោរពេញទៅដោយស្នាមរមាស់ ឯមុខមានស្នាម ។ ដោយសារខ្ញុំស្លៀកពាក់ខោអាវដែលបានបន្សល់ដោយសពឪពុក អ្នកទាំងអស់មើលមកខ្ញុំដូចជាអ្នកសុំទានយ៉ាងកញ្ចាស់ម្នាក់ ។ ខ្ញុំបានឡើងទៅលើខ្ទមដែលត្រូវបានបោះបង់ចោល ព្រោះបង សុីណេ បានទៅធ្វើការនៅកងស្រ្តីនៅឯតាំងព្រេចបាត់ទៅហើយ ។ នៅលើផ្ទះមានសុទ្ធតែកណ្តុរ រីឯក្អមទឹក និងចានឆ្នាំងនៅរាយប៉ាយរុំដោយធូលីក្រោមផ្ទះមានស្មៅដុះទ្រុបទ្រុល ។ ខ្ញុំបានរុះរើការ៉ុងលុយ សម័យ លន់ នល់ ដែលឥឡូវឈប់ចាយទៅហើយ វាបានបន្សល់ទុកដោយឪពុកម្តាយខ្ញុំ ទីបំផុតខ្ញុំឃើញខ្សែកខ្សែដៃនិងចិញ្ចៀនមាសដែលម្តាយខ្ញុំបានលាក់ទុកក្នុងប្រហោងសរសរ សំណាងល្អ កម្មាភិបាលពុំបានឆែកឆេរផ្ទះនេះ ក្នុងរយៈពេលដែលខ្ញុំមិននៅ ។ កាលដែល

យើងចាកចេញពីផ្ទះមិនមានការព្រួយបារម្ភប៉ុន្មានទេ ព្រោះយើងជឿថា អាចទិញម្ហូបអាហារសម្លៀកបំពាក់នៅទីណាក៏បាន ។ យើងពុំបានដឹងថា អង្គការបានបញ្ឈប់មិនឲ្យមានផ្សារ មានការចាយលុយដូច្នេះសោះ ។

ខ្ញុំបានចូលទៅជួបមិត្ត សឿន ដើម្បីសុំការអនុញ្ញាតមកនៅសហករណ៍វិញ ហើយគាត់ក៏យល់ព្រមដោយចាត់ទុកខ្ញុំជាកម្លាំងទីបី ។ មិត្ត សឿន បានអនុញ្ញាតឲ្យខ្ញុំដេកនៅផ្ទះបាយសហករណ៍ដើម្បីជួយធ្វើការចុងភៅ ។ ភារកិច្ចរបស់ខ្ញុំគឺបរទេះដឹកខសផ្គត់ផ្គង់ផ្ទះបាយសហករណ៍ ពេលខ្លះ ខ្ញុំដឹកបន្លែ ទឹក ឬអង្ករយកមកផ្ទះបាយវិញ ។ ជីវិតនៅសហករណ៍មានភាពប្រសើរជាងកងយុវជនឈានមុខដាច់ខាតឆ្ងាយណាស់ ។ ថ្វីត្បិតតែហូបបបរមួយវែក ក៏ប៉ុន្តែការងារមិនសូវជាបង្ខំហួសហេតុពេកឡើយ គឺមានឱកាសដាំដំឡូង រកក្តាមដាក់ទ្រូ ចាប់ត្រី ។ ចំពោះអ្នកស្រែចម្ការពុំមានអ្វីលំបាកទេ តែចំពោះអ្នកដែលធ្លាប់មានជីវភាពធូរធារក៏ចេះតែឈឺស្លាប់ជាបន្តបន្ទាប់ ។ មានជំងឺម្យ៉ាង ដែលខ្ញុំពុំធ្លាប់ជួបប្រទះគឺពោះឡើងប៉ោងធំ ឯដៃជើងហើមដូចសប់ដើរពុំរួច អ្នកជំងឺស្លាប់ក្នុងរយៈពេលមួយសប្តាហ៍ទៅដប់ថ្ងៃ ។ ប្រហែលជាខែកក្កដា ឆ្នាំ១៩៧៥ ពេលដែលខ្ញុំត្រឡប់មកសហករណ៍វិញ ខ្ញុំសង្កេតឃើញថា យុវជនក្មេងៗស្រករខ្ញុំបានចាកចេញទៅធ្វើការទីឆ្ងាយអស់ហើយ នៅសល់តែកម្លាំងទីពីរ និងទីបីប៉ុណ្ណោះ ។ ភ្លៀងរដូវវស្សាបានធ្លាក់ជោគជាំ អង្គការក៏សម្រុកភ្ជួររាស់ដកស្ទូង គ្មាននរណាបាននៅផ្ទះទេ លើកលែងតែមនុស្សចាស់ជរាដែលជាកម្លាំងទីបីប៉ុណ្ណោះ ។

ជារៀងរាល់ថ្ងៃ យើងឃើញតែសែងខ្មោចយកទៅកប់ ហើយថ្ងៃមួយនោះ មនុស្សមួយគ្រួសារប្រាំបីនាក់ទាំងចាស់ ទាំងក្មេងស្លាប់ទាំងអស់ ខ្លះដេកលើគ្រែល ខ្លះដេកលើរនាប ខ្លះមានកំសៀវ ទឹកនៅក្បែរខ្លួន ខ្លះនៅក្បែរមាត់ទ្វារ ។ មនុស្សទាំងសហករណ៍ភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍នេះ ។ ក្នុងនោះ មានតាចាស់ យាយចាស់ដែលកូនប្រុសជាវេជ្ជបណ្ឌិត ប្រពន្ធ និងកូនប្រុសស្រីបួននាក់ តាមការស្មានរបស់ខ្ញុំ ក្នុងនោះមាននរណាម្នាក់បានដាក់ថ្នាំបំពុលក្នុងអាហារ ព្រោះជីវិតរបស់អ្នកទាំងអស់គ្នាវេទនាខ្លាំងពេក ក៏ដាច់ចិត្តបញ្ចប់ជីវិតឲ្យផុតពីទុក្ខលំបាកទាំងនេះ ។

នៅសហករណ៍ អង្គការបានលើកទឹកចិត្តឲ្យប្រជាជនដាំដំឡូងឈើ ឬដំឡូងជ្វា និងចិញ្ចឹមមាន់ដែរ ក៏ប៉ុន្តែមិនអនុញ្ញាតឲ្យហូបឯកជនទេ ។ បើនរណាចង់ហូបត្រូវរាយការណ៍ជូនថ្នាក់លើ ឬស្នើទៅអង្គការ លុះត្រាណាអង្គការអនុញ្ញាតទើបអាចហូបបាន ។ នៅពេលយប់ ឈ្លបតែងតែដើរឃោមល្បាត និងចូលក្រោមផ្ទះដើម្បីស្តាប់ការនិយាយគ្នា និងស៊ើបការណ៍ក្រែងនរណាលួចគាស់ដំឡូង ឬកាប់មាន់ហូប ។

ប្រាកដមែន ថ្ងៃមួយខ្ញុំបានឮមាន់គក និងសំឡេងស្រែកដេរនៅផ្ទះជិតខាងម្នាក់ ។ ខ្ញុំស្ទុះចេញមក ក៏ស្គាល់នោះជាសម្រែកបុរសម្នាក់ គាត់មានឈ្មោះថា តាអ៊ិត ដែលត្រូវកងឈ្លបចងក្រពាត់ដៃទៅក្រោយ ។ តាអ៊ិត ស្រែកដេរឈ្លបទាំងនោះឡូងៗថា ពួកអាទេវតាសំរាម! អញស៊ីដំឡូងដែលអញបានដាំ តើអញមានបានលួចពួកអែ្ហងឯណា តើនេះខុសច្បាប់ដែរឬ? អង្គការពួកឯងជាអង្គការស្អី? ជាពួកឆ្កែមែនទេ? ។ ពេលនោះឈ្លបម្នាក់វ័យប្រហែល១៦ឆ្នាំ បានវាយមាត់ តាអ៊ិត ភូសៗបែកឈាមខ្ទាយ រីឯម្នាក់ទៀតដកកាំបិតសាំងគីមចុងស្រួចចង្អុលក្បាលហើយនិយាយថា នៅឲ្យស្ងៀមអាក្បត់! ប្រយ័ត្នកាត់អណ្តាតចោល! ។ នៅមិនឆ្ងាយពីទីនោះប៉ុន្មាន ប្រពន្ធ និងកូនរបស់គាត់ឈរសម្លឹងមើលឪពុក និងប្តីដែលត្រូវចង ហើយវាយដោយឥតមេត្តា ។ កងឈ្លបបានយកក្រណាត់មកចងមុខហើយអូសកាត់សំដៅព្រៃខាងក្រោយផ្ទះ ។ តាអ៊ិត មិនព្រមឈប់ប្រទេចផ្តាសាឡើយ ទោះបីជាគាត់ត្រូវវាយដំនិងអូសច្រវាប់ច្រវិលក៏ដោយ ។ កន្លះម៉ោងក្រោយមក ឈ្លបទាំងបីនាក់បានបណ្តើរគ្នាត្រសងចេញពីព្រៃ ដៃកាន់កាំបិត ដបង និងកាំភ្លើងមានម្នាក់យកអណ្តាតលិទ្ធឈាមដែលប្រឡាក់ជាប់ដបងដោយប្រៀងចម្រៀងបដិវត្តន៍ផង ហើយដើរសើចលេងយ៉ាងសប្បាយប្រៀបដូចជាបានត្រីផ្ទក់មួយក្បាលដូច្នោះដែរ ។ គិតទៅការសម្លាប់ជីវិតមនុស្សគឺជាសេចក្តីសប្បាយ ។ គ្មានច្បាប់អ្វីទេច្បាប់គឺស្ថិតនៅលើមាត់របស់ឈ្លបក្មេងៗទាំងនោះមាននាទីជាសន្តិសុខផង និងជាតុលាការផង ហើយអាចសម្រេចជោគជ័យនៃជីវិតមនុស្សដោយដំបងឬកាំបិតដោយមិនចាំបាច់មានចៅក្រម ឬមេធាវី ទេ ។ ស្អែកឡើងក្រុមគ្រួសារ តាអ៊ិត គឺត្រូវបញ្ជូនចេញបាត់អស់ ខ្ញុំជឿថាអ្នកទាំងអស់ត្រូវសម្លាប់ ហើយកប់ក្នុងអន្លង់តែមួយ ក្រោមពាក្យស្លោក «ដឹកស្មៅត្រូវដឹកទាំងឫស» ។

## ជំពូក៤ សមរភូមិក្តៅ

### (២៩) កងចល័ត

ខែកក្កដា ឆ្នាំ១៩៧៥ នៅសហករណ៍ភូមិកោះកណ្តាល ឃុំជៀប ស្រុកទឹកផុស ឬស្រុក១៤ តំបន់៣១ "កំពង់ឆ្នាំង" ខ្ញុំដេកនៅផ្ទះបាយសហករណ៍អស់រយៈពេលជាងបីខែ ជាអ្នកបរទេះគោដឹកខស អង្ករ និងបន្លែក្នុងឋានៈជាកម្លាំងទីបី ។ ចំពោះយុវជន យុវនារីដែលមានវ័យស្មើខ្ញុំភាគច្រើន ត្រូវបានអង្គការបញ្ជូនទៅធ្វើការឆ្ងាយៗ ។ វាសនារបស់ខ្ញុំក៏មិនស្ថិតនៅក្នុងភាពប្រាកដប្រជាប៉ុន្មានទេ ថ្ងៃមួយគណៈសហករណ៍បានហៅខ្ញុំប្រាប់ថា អង្គការស្នើកម្លាំងដើម្បីលើកទំនប់ទឹក ។ គាត់បានប្រាប់ឲ្យរៀបចំចេញដំណើរនៅពេលរសៀលនេះ ។

អង្គការបានចាត់តាំងយុវជនយុវនារីចំនួន១៥នាក់ ។ យើងបានមកជួបជុំគ្នានៅសហករណ៍ដើម្បីចេញដំណើរ ។ ក្នុងក្រុមមានម្នាក់ជាអ្នកមូលដ្ឋានចាស់ ជាអ្នកដឹកនាំក្បួនដោយមានរទេះដឹកចបកាប់ ប៉ែល ខ្ទះធំនិងអង្ករ ។ មេក្រុមបរទេះខាងមុខរីឯក្រុមយើងដើរដើងទទេ ស្មាស្ពាយបង្វិចមានខោអាវមួយសម្រាប់ និងសម្ភារប្រើប្រាស់បន្តិចបន្តួច ។

បញ្ញាដាច់ខាតរបស់អង្គការគឺមិនត្រូវត្អូញត្អែរថាហត់ ថាឆ្ងាយ ថាលំបាកទេ គឺមិនត្រូវឲ្យអ្នកណាម្នាក់ធ្វើមុខក្រញ៉ូវ ឬស្រពាប់ស្រពោនឡើយ ត្រូវញញឹម ឬសើចនិយាយលេងពីចលនាបដិវត្តន៍ ឬច្រៀងចម្រៀងបដិវត្តន៍ ។ យើងដើរឥតឈប់ឈរទោះបីក្តៅ ឬភ្លៀងរហូតដល់ពេលបាយ ។ បាយរួចហើយដើរបន្តទៀតរហូតដល់ព្រលប់ ។ ទោះអ្នកណាឈឺជើងឬមុតបន្លាក៏ត្រូវតែដើរគ្មាននរណាឈប់ចាំនរណាទេ ព្រោះនេះជាការពង្រឹងជំហរបដិវត្តន៍ វណ្ណៈផ្តាច់ការអធន ។ យើងដើរពីរថ្ងៃទើបបាន ដល់ទំនប់"បដិវត្តន៍" នាស្រុក១២ គឺស្រុករលាប្អៀរ ។ ជាងបួនខែកន្លងមកហើយ ដែលខ្ញុំរស់នៅក្នុងព្រៃភ្នំ ឥឡូវនេះខ្ញុំបានឃើញទីវាលនិងការដ្ឋានដ៏ធំ ។ នៅទីនោះខ្ញុំបានឃើញប្រជាជនរាប់ម៉ឺននាក់ដែលបានមកដល់មុនយើង ហើយខ្ញុំបានឮចម្រៀងបដិវត្តន៍ដែលចាក់ផ្សាយបន្តពីស្ថានីយ៍វិទ្យុភ្នំពេញ ។ ខ្ញុំបានជួបសុទ្ធតែពួកយុវជនដែលត្រូវបានបញ្ជូនមកពីសហករណ៍នានាទូទាំងតំបន់៣១ កំពង់ឆ្នាំង ។ យើងត្រូវបានបញ្ចូលជាមួយក្រុមផ្សេងទៀតដើម្បីឲ្យបានក្លាយជាកងពលធំមួយដែលមានកម្លាំងប្រហែលជាងបីរយនាក់ ។ យើងមានមេកងម្នាក់ មានវ័យប្រហែលសាមសិបឆ្នាំ ឈ្មោះ មិត្តឌី ។ នៅទីនោះ ខ្ញុំក៏បានជួបនឹងអតីតមិត្តរួមថ្នាក់ពីរនាក់ដែលធ្លាប់រៀននៅវិទ្យាល័យព្រះបាទសុរាម្រិត គឺ ប៊ូឆុន អតីតនិស្សិតនៅមហាវិទ្យាល័យគរុកោសល្យ និង ជា ប៊ុនប៉ា អតីតនិស្សិត ។ ក្នុងកងរបស់យើងមានពាក់កណ្តាលជាយុវនារីដែលគ្រប់គ្រងដោយមេក្រុមនារីម្នាក់ នៅអគារផ្សេងតែធ្វើការរួមគ្នា ។

មិត្តឌី មានរូបរាងសង្ហាស្លៀកពាក់ពណ៌ខ្មៅពាក់មួកកន្ទឹប និងស្បែកជើងកង់ឡាន ។ គាត់បានយកសម្លៀកបំពាក់ពណ៌ខ្មៅមកចែកឲ្យយើង និងបានចែកកម្លាំងជាបីគឺក្រុមសង់ផ្ទះ ក្រុមធ្វើបង្គីដងរែក និងក្រុមសម្រុកការងារ ។ រគាំងវាយលើកទីមួយ វេលាម៉ោងបួនភ្លឺជាសញ្ញាឲ្យភ្ញាក់ពីដំណេក ។ មិត្តឌីដុកញ្ញែឲ្យយើងលុបមុខស្លៀកពាក់ និងត្រៀមចប បង្គី ប៉ែល ។ រគាំងលើកទីពីរម៉ោងបួនកន្លះជាសញ្ញាថាអ្វីៗបានរៀបចំរួចហើយ ។ រគាំងលើកទីបីម៉ោងប្រាំ ទាំងអស់គ្នាត្រូវរត់សំដៅការដ្ឋានដោយច្រៀងចម្រៀងបដិវត្តន៍ ពេលនោះមេក្រូនៅការដ្ឋានក៏ចាក់បទចម្រៀងបដិវត្តន៍ ។ គ្មាននរណាមានសិទ្ធិដើរទេ ទិសដៅរបស់យើងគឺសម្រុកប្រយុទ្ធលើសមរភូមិក្តៅគគុក ដើម្បីសម្រេចភារកិច្ចដែលអង្គការបានប្រគល់ឲ្យ យើងត្រូវស្មោះស្ម័គ្រជានិច្ចចំពោះអង្គការដ៏ភ្លឺស្វាងមហាលោតផ្លោះ មហាអស្ចារ្យ ។ យើងទាំងអស់ត្រូវធ្វើការដោយរត់ផងច្រៀងផង ត្រូវបញ្ចេញភាពសប្បាយរីករាយទឹកមុខញញឹមជានិច្ច តាំងពីម៉ោងប្រាំព្រឹករហូតដល់ម៉ោងដប់មួយ ហើយត្រូវទុកសម្ភារនៅកន្លែងធ្វើការហើយរត់មករោងបាយរួម ។ របបអាហារនៅទីនេះ គឺបបរមួយចាន និងសម្លមួយចានសម្រាប់បួននាក់ ដែលគ្មានសាច់ត្រីអ្វីទេ គឺបន្លែត្រកួន ព្រលិត ល្ពៅ ត្រប់ ស្ងោរចំរុះនឹងអំបិលសម្រាប់អាហារថ្ងៃត្រង់រួច ហើយត្រូវរង់ចាំស្តាប់រគាំងនៅវេលាម៉ោងមួយត្រូវរត់សម្រុកទៅរកការដ្ឋានដើម្បីបន្តការងារ ។ យើងត្រូវផ្លាស់ប្តូរគ្នា ខ្លះកាន់ចប ប៉ែល ខ្លះរែកបង្គីដែលដាក់ដីពេញប្រៀប ។ មេកងលើកដៃរាប់ជាចង្វាក់តាមបទភ្លេងដែលច្រៀងតាមមេក្រូនៅលើខ្នងទំនប់ ។ រគាំងវាយនៅម៉ោងប្រាំល្ងាចយើងសម្រាក និងហូបបបរ ហើយសម្រាករហូតដល់ម៉ោងប្រាំបីយប់ ទើបបន្តធ្វើការងាររហូតដល់ម៉ោងដប់ ។

នៅយប់ទីមួយនៃការដ្ឋាននោះខ្ញុំហត់នឿយខ្លាំងណាស់ ព្រោះ

ការងារដប់ប្រាំមួយម៉ោង ប្តូរបបរមួយវែកនោះពុំមែនជាការងារងាយស្រួលប៉ុន្មានឡើយ ខ្ញុំដេកលក់ដូចងាប់រហូតដល់រតាំងចាប់ផ្តើមវាយនៅព្រឹកថ្ងៃទីពីរ ។ ព្រឹកនេះគ្មាននរណាទេ ទោះបីជាមិត្ត ឌី ដុំកញ្ចែយ៉ាងណាក៏ដោយ ។ ពេលនោះមិត្ត ឌី ដុំកញ្ចែកាន់រំពាត់នៅនឹងដៃផង ។ សំឡេងមិត្ត ឌី លាយឡំនឹងកម្មាភិបាលដទៃទៀត ។ ក្រោកឡើង! ក្រោកៗ បំពេញភារកិច្ចបដិវត្តន៍ ប្រយ័ត្នកង់ប្រវត្តិសាស្ត្រវិលជាន់ ។ ពេលនោះ ជើងរបស់ខ្ញុំហាក់បីដូចជាធ្ងន់រាប់រយគីឡូ ។ ខ្ញុំប្រឹងងើបទាំងលំបាក លើកនេះ យើងទាំងអស់រត់មិនលឿនដូចពីម្សិលមិញទេ រីឯចម្រៀងបដិវត្តន៍នៅតែពុំចេះហត់នឿយ ។ ចម្រៀងរៀបរាប់ពីការពិតតស៊ូរបស់កម្មាភិបាល និងយុទ្ធជនដែលខ្ញុំចាំបានខ្លះរហូតដល់សព្វថ្ងៃដូចជា ៖

*"ឱកូនពន្លក សូមកូនចាំស្តាប់ ពុកម៉ែរៀបរាប់ប្រាប់ដល់មាសថ្លៃ កូនអើយ យុទ្ធជន កម្មាភិបាលយើងពលិក្ខុងភ្លើងច្រើនឥតគណនា ។ កូនអើយ ទម្រាំបានដូចសព្វថ្ងៃ យុទ្ធជនប្រុសស្រី យុទ្ធជនក្មេងក្លា ។ ពេលថ្ងៃលាក់លួចហូបក្តួចបបរ ពេលយប់ចុះមកដឹកនាំសព្វគ្រប់"*

ចម្រៀងនេះបញ្ជាក់ប្រាប់យើងថា កម្មាភិបាលទាំងនោះមានការតស៊ូខ្លាំងណាស់ ដូច្នេះយើងត្រូវតែចេះតស៊ូអត់ទ្រាំអត់ឃ្លានដូចកម្មាភិបាលទាំងនោះដែរ គ្រប់ម៉ោងគឺលើកសរសើរតែពីស្នាដៃដឹកនាំមហាក្លៀវក្លារបស់អង្គការ មហាលោតផ្លោះ មហារុងរឿង មហាអស្ចារ្យ ។

កម្លាំងទំនប់ទឹកមានរយៈពេលបួនខែ មានកម្លាំងប្រហែលពីរម៉ឺនប្រាំពាន់នាក់ មកពីគ្រប់បណ្តាស្រុកទាំងប្រាំ ស្រុក១០ ស្រុក១២ ស្រុក១៤ ស្រុក១៦ និងស្រុក១៨ ។ យើងលើកទំនប់ទប់ទឹកភ្លៀង និងស្ទឹងក្រាំងតាមុំ ដើម្បីបង្វែរទឹកស្ទឹងទៅស្រោចសព្វដីស្រែដែលមានជាច្រើនពាន់ហិចតានៅព្រៃមូល ចំបក់កន្ទ្រាញតាលោ ដើងគ្រាវ ។ តាមខ្ញុំស្មានមានប្រហែលជាប៉ែតសិបអង្គភាពដែលហៅថា កងចល័ត ។ ក្នុងមួយកងចល័តមានកម្លាំងប្រហែលពីររយនាក់ ទៅបីរយនាក់ដែលដឹកនាំដោយប្រធានកងម្នាក់ជាកម្មាភិបាលដែលមានជីវប្រយុទ្ធមោះមុត និងដាច់ខាត ។ ខ្ញុំបានស្ថិតនៅក្នុងកងចល័តមួយដែលមានកម្លាំងជាងបីរយនាក់សុទ្ធតែជាយុវជន យុវនារី ដែលមានអាយុពីដប់ប្រាំទៅម្ភៃប្រាំឆ្នាំដែលអង្គការចាត់ទុកជាកម្លាំងទីមួយ ។

## ៣០) ភ្នែកម្នាស់

នៅលើខ្នងទំនប់យើងបានឃើញមិត្តឌីរង់ចាំយើងជាស្រេច ។ មិត្ត ឌី បានឲ្យយើងទាំងអស់គ្នាអង្គុយចុះដើម្បីបើកអង្គប្រជុំ និងបានណែនាំយើងកុំឲ្យយឺតយ៉ាវដូចពេលនេះ ។ មិត្តទាំងអស់ដឹងទេចលនាបដិវត្តន៍ខ្លាំង ហើយរហ័សដូចផ្គរបន្ទោរ គ្មានអ្វីអាចទប់ចលនាបដិវត្តន៍បានទេ ។ សូមមិត្តទាំងអស់ជំរុញឲ្យអស់ស្មារតីអសកម្មដែលធ្វើឲ្យស្ទះដល់ចរន្តបដិវត្តន៍ ដូចជាការខ្ជិលច្រអូស ការស្ពឹកស្រពន់ប្រតិកិរិយា និងការយកជើងរាទឹក កុំថាអង្គការមិនដឹង ព្រោះអង្គការមានភ្នែកម្នាស់ ។ នេះជាពាក្យថ្មីមួយទៀតដែលខ្ញុំទើបនឹងបានស្គាល់ "ភ្នែកម្នាស់" បានន័យថា មិនដូចជាភ្នែកមនុស្ស ។ ម្នាស់គឺផ្លែឈើម្យ៉ាងវាគ្មានវិចារណញ្ញាណទេ ក៏ប៉ុន្តែវានៅគ្រប់ទិសទីវាសម្លឹងនិងតាមដានយើងគ្រប់ទាទីគ្រប់ជំហាន ស៊ើបការណ៍ពីអ្នកគ្រប់គ្នាគ្រប់សកម្មភាពប្រឆាំងបដិវត្តន៍ ។ បងប្អូនរាយការណ៍ពីគ្នាទៅវិញទៅមក ។ ខ្លាំងស៊ីរូងផ្ទៃក្នុងត្រូវអង្គការភ្នែកម្នាស់ មើលឃើញយ៉ាងងាយស្រួលដូចជា អ្នកដែលធ្វើពុតជាឈឺ អ្នកដែលធ្វើឲ្យបាក់ដងចបបាក់ដងវែកបង្គី អ្នកទៅនោមញឹកញាប់ ព្រមទាំងអ្នកដែលនិយាយរម្លឹកពីរបបចាស់អ្នកដែលត្អូញត្អែរអំពីរបបអាហារប្រចាំថ្ងៃជាដើម ។

ក្រោយការប្រជុំ យើងទាំងអស់គ្នាត្រូវធ្វើការតទៅទៀត ។ យើងត្រូវវែកដីយកទៅចាក់លើខ្នងទំនប់ដែលមានចម្ងាយមួយរយហាសិបម៉ែត្រ ក្នុងបង្គីមួយមានដីទម្ងន់យ៉ាងតិចដប់ប្រាំគីឡូដោយរត់យ៉ាងលឿន ។ ក្នុងរយៈពេល១៦ម៉ោងក្នុងមួយថ្ងៃ យើងរត់ឡើងនិងចុះយ៉ាងតិចក៏រាប់រយត្រឡប់ដែរ រីឯរបបអាហារគឺបបរមួយវែក អង្ករមួយកំប៉ុងសម្រាប់មនុស្សប្រាំនាក់ ។ យើងសម្រាកបានដប់នាទីនៅម៉ោងប្រាំបួនព្រឹក ។ ក្រៅពីម៉ោងសម្រាកដែលកំណត់អង្គការមិនអនុញ្ញាតឲ្យទៅនោមឬផឹកទឹកទេ ។

## ៣១) កម្មាភិបាលអសកម្ម

ថ្ងៃបន្ទាប់ ចម្រៀងបដិវត្តន៍ក៏កាន់តែខ្សោយ យើងរត់លែងរួចក៏វែកដីដើរតែម្តងយូរៗកាន់តែយឺតទៅៗ ចំណែកឯនៅក្នុងរោងក៏មានមនុស្សជាច្រើនដែលដេកមិនក្រោកមិនព្រមទៅធ្វើការ ។ មិត្តឌី ពុំសប្បាយចិត្តទាល់តែសោះ ។ ពេលរតាំងគោះនៅម៉ោងបួនព្រឹក មិត្តឌីដុំកញ្ចែស្ទើរតែបែក ក៏ប៉ុន្តែគ្មាននរណាច្រៀងចេញទៀតឡើយ

មិត្ត ឌី ខិតខំបើកអន្លុងប្រជុំទិតៀន និងស្ម័យទិតៀន ដើម្បីគៀសបន្ទុះ ឲ្យភ្លឺឡើងដើម្បីផុសខាត់ខួរក្បាល ក៏ប៉ុន្តែពុំទទួលលទ្ធផលអ្វីសោះ ព្រោះយើងអស់កម្លាំងយ៉ាងខ្លាំង ថ្ងៃនេះមានកម្លាំងជាងម្តៃនាក់ ដែលដេកមិនចេញទៅធ្វើការ ទោះបីមិត្ត ឌី កាន់រំពាត់កំញើញយ៉ាង ណាក៏ដោយ ។ មានអ្នកខ្លះគឺដេកពុំកម្រើកតែម្តង ។ ពេលនោះខ្ញុំចង់ រត់នឹងព្រៀងដូចពេលមុនដែរ ប៉ុន្តែព្រៀងពុំចេញទាល់តែសោះ ។ ពេលដែលហត់ខ្លាំង យើងផ្លាស់គ្នាកាប់ដីម្តងម្នាក់ ទោះយ៉ាងណាក្នុង មួយថ្ងៃ យើងវែកបានប្រហែលហាសិបដើង រីឯដីក្នុងបង្គីក៏ថយ បរិមាណមកពាក់កណ្តាលដែរ ពេលកំពុងតែវែកដី ស្រាប់តែ មិត្ត ឌី បានចង្អុលមកខ្ញុំ ហើយនិយាយថា យើងត្រូវការកម្លាំងបួននាក់ ដើម្បីធ្វើបង្គី វេញខ្សែ និងចាំងដងវែក តើមិត្តឯងចេះធ្វើបង្គីឬ ទេ? ខ្ញុំអល់អែក មិត្តឯង និងយុវជនបីនាក់ទៀត ។ ដូច្នេះមិត្តត្រូវ នៅកន្ទែងត្បាញបង្គីឲ្យបានម្ភៃក្នុងមួយថ្ងៃ ម្នាក់ៗត្រូវឈរលើជីហរ បដិវត្តន៍ខ្ពស់ឯករាជ្យម្ចាស់ការ ហើយពុំចាំបាច់ទៅការដ្ឋានទេ ត្រូវ ធានាថា មានបង្គីគ្រប់គ្រាន់សម្រាប់យុទ្ធមិត្តយើង ។

ដោយសារតែជំនាញថ្មីនេះហើយ ដែលបានជួយឲ្យខ្ញុំមាន ជីវិតរហូតដល់សព្វថ្ងៃ ព្រោះខ្ញុំបានរួចចាកផុតពីការវែកដីហាសិប ដើងក្នុងមួយថ្ងៃ ។ រត់ផងព្រៀងផងក៏ប៉ុន្តែគួរអាសូរដល់អ្នកដទៃ ទៀតបានស្លាប់ជាបន្តបន្ទាប់ជារៀងរាល់ថ្ងៃ ។ ចំពោះខ្លួនខ្ញុំផ្ទាល់ពុំ ដឹងថាហេតុអ្វីបានជា មិត្ត ឌី បានជ្រើសរើសរូបខ្ញុំដែលគ្មានជំនាញ ទាល់តែសោះឲ្យត្បាញបង្គីបែបនេះ ។ រហូតពេលនេះ ទើបខ្ញុំបាន ដឹងថា មិត្ត ឌី ជាអតីតសាស្ត្រាចារ្យដែលធ្លាប់បង្រៀននៅវិទ្យាល័យ ព្រះសុរិយាវង្ស៊ននៅខេត្តស្វាយរៀង ។ គាត់បានចូលរួមចលនា តស៊ូជាមេបញ្ជាការយ៉ាងអង់អាចក្លាហាន និងជាអ្នកប្រយុទ្ធប្រឆាំង នឹងអំពើពុករលួយ ។ មានជ័យជម្នះលើរបបសាធារណរដ្ឋនៃសេនា ប្រមុខលន់នល់ មិត្ត ឌី គឺជាមេបញ្ជាការកងពលធំនៃរណសិរ្សរំដោះ ជាតិកម្ពុជាទិសត្រើយខាងកើតក្រុងភ្នំពេញ ក៏ប៉ុន្តែក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មិត្ត ឌី ត្រូវអង្គការដកសេចក្តីទុកចិត្តដោយសារ និន្នាការជាអនុធនបញ្ញវន្ត ជាអតីតសាស្ត្រាចារ្យដែលតែងតែមាន យោបល់ជំទាស់នឹងអង្គការ ។ គាត់ត្រូវអង្គការរំសាយពីជួរកងទ័ព ដោយសារតែគាត់មាននិន្នាការសេរី ។ និន្នាការសេរីគឺសំដៅអតីត អ្នករាជការនៃសម័យសង្គមរាស្ត្រនិយមជំនាន់សម្តេច ហើយគឺជា មនុស្សដែលដោតជាំទៅដោយឥទ្ធិពលសេរីនៃរបបសក្តិភូមិ និង រាជាធិបតេយ្យផ្តាច់ការ ។

តាមបញ្ជារបស់មិត្ត ឌី ខ្ញុំត្រូវដើរចូលក្នុងព្រៃដើម្បីកាប់ឬស្សី ប្រោចវល្លិ៍សម្រាប់ការផាតម្បាញរបស់ខ្ញុំ ។ យើងទាំងបួននាក់បាន ជួបប្រទះផ្សិត ខ្ទងដំឡូងព្រៃ ។ ពេលខ្លះយើងបរបាញ់បានសត្វកំប្រុក ទន្សាយ សំពោច ដែលអាចធ្វើជាអាហារបុស្ទទំពាំងជាមួយសាច់ កណ្តុរ កង្កែប ក្តាម ហើយចែកគ្នាបរិភោគជារៀងរាល់ថ្ងៃ ចំណែក អ្នកដទៃទៀតដែលគ្មានដោតវាសនាបែបនេះ ក៏ត្រូវតែវែកដី និង ព្រៀងចម្រៀងបដិវត្តន៍មួយថ្ងៃ១៦ម៉ោងដើម្បីប្តូរយកបបរមួយ វែក ។ ថ្ងៃមួយមិត្ត ឌី បានហៅខ្ញុំទៅនិយាយស្ងាត់ៗតែពីរនាក់ ។ គាត់ប្រាប់ថា គាត់បានសម្គាល់ដឹងថា ខ្ញុំជាអតីតនិស្សិត ។ ពាក្យសម្តី នេះធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង មិត្ត ឌី បានទះស្មាខ្ញុំតិចៗ ហើយប្រាប់ ថា ខ្ញុំជាអតីតនិស្សិតម្នាក់ ខ្ញុំដឹងច្បាស់លាស់ បើឯងធ្វើការដូចគេនោះ ឲ្យរបស់ឯងមិនបានវែងឡើយ ដូច្នេះហើយបានជា ខ្ញុំចាត់តាំងឯង អាយុធ្វើបង្គី ។ មិត្ត ឌី បានពន្យល់ខ្ញុំឲ្យចេះអត់ធ្មត់ និងលាក់ការ សម្ងាត់ ហើយត្រូវបញ្ចេញអាប្បកិរិយាដូចកូនកសិករពិតៗ និងត្រូវ តស៊ូការងារ ។ គាត់បន្ថែមថា ខ្ញុំជួយឯងបានតែប៉ុណ្ណឹងទេ ថ្ងៃក្រោយ គឺឯងត្រូវចេះជួយខ្លួនឯង ។ មិត្ត ឌី ក៏បានចាកចេញទៅ ព្រោះគាត់ ត្រូវត្រួតពិនិត្យការដ្ឋានបន្តទៅទៀត ។ នៅទីនោះ ក្រុមយុវជន យុវនារី កំពុងតែវែកដីឥតមានឈប់សម្រាក ។

ស្អែកឡើងប្រហែលជាម៉ោងប្រាំបួនព្រឹក ខ្ញុំបានឃើញឡាន ម៉ាកឡង់រ៉ូវែរ ពណ៌ខ្មៅមួយបានបើកចូលក្នុងការដ្ឋានហើយឈប់ នៅអគាររបស់យើង ។ ពេលនោះខ្ញុំឃើញបុរសបួននាក់ហៅឈ្មោះ មិត្ត ឌី ឲ្យចេញមកក្រៅ ។ ពេលដែលមិត្ត ឌី ដើរចេញមកដល់សមមិត្ត ម្នាក់បានស្ទុះមកវាយ មិត្ត ឌី ចំក្បាលជង្គង់នឹងស្ម័យកាំភ្លើង មិត្ត ឌី ក៏ដួលផ្កាប់មុខទៅនឹងដី រីឯសមិត្តពីរនាក់ទៀតបានស្ទុះមកជាន់ក ហើយចាប់ដៃ មិត្ត ឌី ចងស្លាបសេកទៅក្រោយខ្នង និងយកក្រណាត់ ខ្មៅមកចងភ្នែករួចចាប់ដាក់ក្នុងឡានបើកចេញទៅ ។ មិត្ត ឌី បានចាក ចេញពីយើងហើយ ។ គាត់បានបន្សល់ទុកនូវមុខរបរដែលជួយឲ្យខ្ញុំ រស់រានមានជីវិតធ្វើឲ្យខ្ញុំចងចាំជានិច្ចក្នុងជីវិតនេះ ។ ក្រោយមក ទើប ដឹងថា មិត្ត ឌី ត្រូវបញ្ជូនទៅទីក្រុងភ្នំពេញ និងចោទមិត្ត ឌី ថា កម្មាភិបាលអសកម្ម ឬជនក្បត់ ។ **(នៅមានត) ឆាយ ស៊ីឆាត្រ**

# សាច់រឿងរបស់ឪពុកម្ដាយខ្ញុំ

ខ្ញុំបាទឈ្មោះ ជូ ជុំបូរ៉ា ជានិស្សិតឆ្នាំទី៤ ផ្នែកប្រវត្តិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ខ្ញុំមានស្រុកកំណើតនៅឃុំកំពង់ហ្លួង ស្រុកអង្គរបុរី ខេត្តតាកែវ ។

ពេលរៀននៅវិទ្យាល័យទួលទំពូង ខ្ញុំឃើញពាក្យស្លោកមួយឃ្លាដែលព្យួរជាប់ជញ្ជាំងនៅក្នុងថ្នាក់រៀនរបស់ខ្ញុំក្នុងអត្ថន័យរៀបរាប់ថា «អ្នកដែលមិនចេះប្រវត្តិវិទ្យាបីដូចជាមិនស្គាល់ប្រវត្តិខ្លួនឯង» ។ ពាក្យស្លោកនេះហើយដែលធ្វើឲ្យខ្ញុំជ្រើសរើសមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ កត្តាដែលធ្វើឲ្យខ្ញុំរៀនមុខវិជ្ជាប្រវត្តិវិទ្យា ពីព្រោះខ្ញុំចង់ចេះដឹងពីប្រវត្តិសាស្ត្រខ្មែរ និងប្រទេសផ្សេងទៀត ។

ពេលទំនេរពីម៉ោងសិក្សា ខ្ញុំតែងតែឆ្លៀតឱកាសធ្វើការសិក្សាស្រាវជ្រាវកិច្ចការដែលគ្រូដាក់ឲ្យនៅក្នុងបណ្ណាល័យ ។


ជូ ជុំបូរ៉ា ជាមួយនឹងប្អូនពីរនាក់ និងឪពុកម្ដាយ

ក្រៅពីនោះ ខ្ញុំចូលចិត្តអានសៀវភៅទាក់ទងទៅនឹងសង្គមខ្មែរ សីលធម៌ និងជាពិសេសរបបខ្មែរក្រហម ។ តាមរយៈការអាននេះ បានធ្វើឲ្យខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះរបបខ្មែរក្រហម រហូតដល់ខ្ញុំដាក់ធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

តាមការសិក្សាពីសាលារៀន និងការនិយាយប្រាប់ពីអ្នកជិតខាង ខ្ញុំបានដឹងពីហេតុការណ៍មួយចំនួនដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហម ដូចជា ៖ ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការងារហួសកម្លាំង ការមិនទទួលបានការព្យាបាលត្រឹមត្រូវ ការបំបែកសមាជិកក្រុមគ្រួសារ និងការកាប់សម្លាប់ ដែលជាសោកនាដកម្មដែលបានកើតមានលើប្រជាជនកម្ពុជា ។ គ្រួសារខ្ញុំក៏មិនខុសពីប្រជាជនកម្ពុជាទាំងនោះដែរ គឺខ្ញុំបានបាត់បង់តាខាងឪពុករបស់ខ្ញុំក្នុងរបបខ្មែរក្រហម ដោយអង្គការបានហៅគាត់ទៅរៀនសូត្រ ព្រោះស៊ើបដឹងពីជីវប្រវត្តិរបស់ជីតាខ្ញុំដែលជាអតីតមន្ត្រីរដ្ឋការក្នុងរបប លន់

នល់ ។ តាមការនិយាយប្រាប់ពីឪពុករបស់ខ្ញុំ ជីតាខ្ញុំមិនបានត្រឡប់មកផ្ទះវិញមកទល់នឹងសព្វថ្ងៃ ហើយឪពុកម្តាយខ្ញុំក៏លើករឿងពិតរបស់គាត់ក្នុងសម័យខ្មែរក្រហមប្រាប់ខ្ញុំដូចខាងក្រោម ៖

ឪពុកខ្ញុំឈ្មោះ ជូ ស៊ីណា កើតនៅឃុំគោកព្នៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ម្តាយខ្ញុំឈ្មោះ ម៉ៃ គឹមហេង កើតនៅឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ឪពុកម្តាយខ្ញុំបានរៀបការនៅឃុំកំពង់ហ្លួង ស្រុកអង្គរបុរី ខេត្តតាកែវ នៅឆ្នាំ១៩៨៧ ។

ក្នុងសម័យខ្មែរក្រហម ឪពុកម្តាយខ្ញុំមានវ័យក្មេងនៅឡើយគឺឪពុកខ្ញុំមានអាយុ១៧ឆ្នាំ ។ ខ្មែរក្រហមមិនជម្លៀសគ្រួសារគាត់ទៅកន្លែងផ្សេងទេគឺឲ្យនៅក្នុងស្រុកភូមិដដែល ។ ប៉ុន្តែបានបំបែកគាត់ចេញពីឪពុកម្តាយ និងបងប្អូនទាំងអស់ប្រាំនាក់ និងឲ្យនៅទីកន្លែងផ្សេងៗគ្នា ។ ឪពុកខ្ញុំនិយាយថា កងឈ្លបតាមលបស្តាប់គ្រួសារនៅក្រោមផ្ទះជារៀងរាល់យប់ និងបានបង្ខំឲ្យប្រជាជនធ្វើការងារធ្ងន់ធ្ងរ និងឲ្យហូបតែបបរប៉ុណ្ណោះ ។ គាត់បានបន្តទៀតថា ក្រុមចាស់ៗ ខ្មែរក្រហមបង្ខំឲ្យជីកប្រឡាយ លើកទំនប់ ចំណែកក្មេងៗបង្ខំឲ្យរើសអាចម៍គោដាក់ស្រែ ។ ឪពុកខ្ញុំមិនខុសពីក្មេងដទៃទៀតទេគឺដើររើសអាចម៍ ក្រៅពីនោះកម្មាភិបាលខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅកងឃ្វាលគោ រហូតដល់ម៉ោងសម្រាកទើបឲ្យហូបបបរ ។ គាត់បន្តថា នៅសម័យខ្មែរក្រហម គាត់មិនបានចេញពីស្រុកភូមិទេរហូតដល់ពេលវៀតណាមចូលមក ទើបគាត់និងប្រជាជនក្នុងភូមិភៀសខ្លួនចេញព្រោះព្រួថាវៀតណាមចូលមកអារកសម្លាប់ ។ គាត់រត់ឆ្លងកាត់ពីភូមិមួយទៅស្រុកមួយដោយមិនមានគោលដៅ ។

គាត់បានបន្តទៀតថា បន្ទាប់ពីគេចខ្លួនបានមួយរយៈ ទើបព្រួគេនិយាយតៗគ្នាថា ស្រុកបានរំដោះហើយ ។ ឪពុកខ្ញុំបានជួបជុំគ្រួសារ និងបានត្រឡប់មកភូមិវិញ ។ ឪពុកខ្ញុំបានចូលរៀននៅសាលាព្រៃល្វា ។ បន្ទាប់មក ទើបគាត់ប្រឡងចូលធ្វើគ្រូបង្រៀននៅទីរួមខេត្តតាកែវ ។ ការប្រលងនៅពេលនោះមានបេក្ខជនច្រើនតែជាប់បានតែប្រាំនាក់ប៉ុណ្ណោះ ។ ក្រោយពីរៀនចប់ មន្ទីរអប់រំបានចាត់តាំងឲ្យគាត់ទៅបង្រៀននៅសាលាបឋមសិក្សានៅក្នុងវត្តកំពង់ហ្លួង ស្រុកអង្គរបុរី ខេត្តតាកែវ ។

រីឯម្តាយខ្ញុំដែលទើបតែអាយុប្រហែល១២ឆ្នាំ នៅក្នុងសម័យខ្មែរក្រហម ត្រូវកម្មាភិបាលខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅកងកុមារ ។ ខ្មែរក្រហមឲ្យគាត់រើសអាចម៍គោជារៀងរាល់ថ្ងៃ និងហូបតែបបររាវៗប៉ុណ្ណោះ ។ ម្តាយខ្ញុំនៅក្នុងកងកុមាររហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបគាត់បានជួបជុំគ្រួសារវិញ ។ នៅឆ្នាំ១៩៨១ យាយតាខាងម្តាយខ្ញុំបានចេញរកស៊ីនៅស្រុកអង្គរបុរី ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ហើយក្រោយមកគាត់បានផ្លាស់ទីលំនៅទៅរស់នៅស្រុកអង្គរបុរីតែម្តង ។ នៅពេលនោះជីតារបស់ខ្ញុំប្រកបរបរជាជាងដេរខោអាវ រីឯយាយរបស់ខ្ញុំរកស៊ីលក់សំពត់ហូល ។

តាមរយៈបទពិសោធរបស់ឪពុកម្តាយ និងយាយតារបស់ខ្ញុំបានធ្វើឲ្យខ្ញុំយល់ដឹងកាន់ច្រើនពីរឿងរ៉ាវឃោរឃៅនៅក្នុងរបបខ្មែរក្រហម ដែលបណ្តាលឲ្យប្រជាជនស្លូតត្រង់ស្លាប់អស់ប្រមាណពីរលាន នាក់ ។ ដូច្នេះខ្ញុំមិនចង់ឲ្យរបបនេះមានកើតឡើងវិញទេ ។

**ជូ ជុំបូរ៉ា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី “សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្មាន” ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

# ខ្ញុំចង់រៀនសូត្រពីប្រវត្តិខ្មែរក្រហមឱ្យបានច្បាស់

នាងខ្ញុំឈ្មោះ អៀង ណារី ជានិស្សិតឆ្នាំទី៣ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកប្រវត្តិសាស្ត្រ ។ នាងខ្ញុំមានស្រុកកំណើតនៅឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង ។

បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យរួចមក នាងខ្ញុំក៏បានបន្តការសិក្សានៅសាកលវិទ្យាល័យ ។ ខ្ញុំបានសម្រេចចិត្តជ្រើសរើសយកមុខវិជ្ជាប្រវត្តិវិទ្យា ជាមុខវិជ្ជាមួយដែលខ្ញុំស្រឡាញ់ពេញចិត្តជាងគេ ។ ក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជានេះ នាងខ្ញុំតែងតែមានចម្ងល់ចំពោះរឿងរ៉ាវដែលបានកើតមានឡើងពីអតីតកាល ។ ជាងនេះទៅទៀត មុខវិជ្ជានេះនឹងជួយឲ្យខ្ញុំបានសិក្សាស្វែងយល់ដឹងកាន់តែច្បាស់លាស់ពីមេរៀនមិនល្អពីអតីតកាលដើម្បីទប់ស្កាត់ និងជៀសវាងការអនុវត្តខុសនៅពេលបច្ចុប្បន្ន ។

ការសិក្សារបស់នាងខ្ញុំនៅសាលារៀនគឺជាផ្នែកមួយនៃការទទួលបានចំណេះដឹងជាទ្រឹស្តី ។ ដូច្នេះ ដើម្បីផ្សារភ្ជាប់គ្នាជាមួយការអនុវត្តការងារជាក់ស្តែង នាងខ្ញុំក៏សម្រេចចិត្តដាក់ពាក្យធ្វើជាបុគ្គលិកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីបានឃើញសេចក្តីប្រកាសព័ត៌មាននៅសាកលវិទ្យាល័យរបស់នាងខ្ញុំ ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងទទួលបានធ្វើការងារដែលខ្ញុំពេញចិត្ត ព្រោះនាងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការងារចងក្រងឯកសាររបបខ្មែរក្រហម ហើយនាងខ្ញុំចង់រៀនសូត្រពីរបបខ្មែរក្រហមនេះណាស់ ។ ជាការពិតណាស់ តាមរយៈការងារស្ម័គ្រចិត្តជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាងខ្ញុំបានចំណេះដឹងថ្មីៗ ហើយក៏ជាបទពិសោធន៍លើកទីមួយសម្រាប់នាងខ្ញុំដែលចូលប្រលូកការងារក្នុងសង្គម ។

កម្ពុជាប្រជាធិបតេយ្យគឺជារបបមួយដ៏សាហាវព្រៃផ្សៃដែលបានធ្វើឲ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបមានការចងចាំគ្រប់ៗគ្នា ។ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា នៅសម័យនោះគាត់មានការលំបាកណាស់ ។ ខ្មែរក្រហមឲ្យគាត់ហូបតែបបរ ហើយឲ្យធ្វើការមិនមានម៉ោងសម្រាក ។ គាត់បន្តទៀតថា បើអ្នកណាមិនព្រមធ្វើតាមខ្មែរក្រហមនឹងយកទៅសម្លាប់ចោលភ្លាម ។ ម្តាយរបស់ខ្ញុំមានបងប្អូនដប់នាក់ និងបានស្លាប់ជាបន្តបន្ទាប់ ។ បងប្អូនរបស់គាត់មួយចំនួនបានស្លាប់នៅក្នុងរបប លន់ នល់ របបខ្មែរក្រហម និងក្រោយពេលដែលខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ។


អៀង ណារី កំពុងអានទស្សនាវដ្តីស្វែងរកការពិតនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

ម្តាយខ្ញុំបានរៀបរាប់រឿងរ៉ាវប្រាប់ខ្ញុំថា ក្នុងរបបខ្មែរក្រហមគាត់ហូបមិនឆ្អែតទេ ដូច្នេះនៅពេលអង្គការឲ្យគាត់ទៅកាប់ខសនៅក្នុងព្រៃ គាត់តែងតែលួចយកពងមាន់ដែលប្រជាជនចិញ្ចឹមយកមកកប់ដី ហើយយកចំបើងមកដុតពីលើ ។ គាត់ថា សំណាងណាស់ដែលគ្មាននរណាម្នាក់ឃើញ ហើយបើសិនជាអង្គការបានឃើញគាត់ធ្វើបែបនេះ

ប្រហែលជាយកខ្មែរក្រហមយកគាត់ទៅសម្លាប់ចោលមិនខានឡើយ ព្រោះថាទង្វើទាំងនេះជាអំពើមួយដែលក្បត់សមូហភាព ។ ខ្ញុំបានសួរគាត់ថាតើបានរស់នៅជួបជុំឪពុកម្ដាយទេកាលសម័យនោះ? គាត់ឆ្លើយថា គាត់រស់នៅជាមួយម្ដាយឪពុកព្រោះគាត់នៅជាកុមារនៅឡើយ ។ លើកលែងតែយុវជនយុវនារីទើបអង្គការបំបែកចេញពីម្ដាយឪពុក ។

គាត់បានបន្ថែមថា គាត់ជាប្រជាជនចាស់ ដូចនេះ គាត់មិនសូវមានការរឹតបន្តឹងដូចប្រជាជនថ្មីទេ ។ គាត់ថា ចំពោះប្រជាជនថ្មីគឺមានការគាបសង្កត់ខ្លាំង ព្រោះទាំងនោះមានការតវ៉ាប្រឆាំងនឹងប៉ុល ពត ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ គាត់សប្បាយចិត្តណាស់ ព្រោះគាត់មិនដែលសង្ឃឹមថានឹងមានជីវិតរស់នៅទេ បើរបបនេះនៅតែបន្ត ។ គាត់ថា ទោះបើគេមិនយកទៅសម្លាប់ដោយហេតុផលអ្វីមួយទេ ក៏គាត់ស្លាប់ដោយសារតែភាពអត់ឃ្លានដែរ ។

ក្រោយពីបានស្ដាប់ការរៀបរាប់របស់ម្ដាយខ្ញុំ ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់គាត់ និងក្រុមគ្រួសារយ៉ាងខ្លាំង ហើយក៏សឹងតែមិនជឿថារបបនេះកើតឡើងដែរ ។ របបខ្មែរក្រហមបានបង្កការឈឺចាប់ច្រើនណាស់ដល់ប្រជាពលរដ្ឋកម្ពុជាច្រើនណាស់ ។ ដូច្នេះក្នុងនាមខ្ញុំជាកូនខ្មែរមួយរូបខ្ញុំត្រូវខិតខំសិក្សាស្រាវជ្រាវ និងយល់ដឹងអំពីរបបនេះឲ្យកាន់តែច្បាស់លាស់ដើម្បីការពារកុំឲ្យរបបនេះកើតឡើងសាជាថ្មីទៀត ។ **អៀង ណារី**

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩» ចាប់តាំងពីឆ្នាំ ២០០៧មកនិងបានចែកចាយដល់សិស្ស-និស្សិតនិងសាធារណជនទូទាំងប្រទេសជាងមួយលាននាក់ ។ ជាមួយគ្នានោះដែរសៀវភៅនេះត្រូវបានបកប្រែជាច្រើនភាសា ហើយអាចរកបានតាមរយៈ ***http://www.d.dccam.org/Projects/Genocide/A%20History%20of%20DK%202007.htm***



*អៀង ណារី កំពុងសម្ភាសអ្នកភូមិនៅខេត្តកំពតក្នុងខែកញ្ញា ឆ្នាំ២០១៣*

# អតីតទាហាន លន់ នល់ រួចរស់ជីវិត ពីរបបខ្មែរក្រហម

*សារិន ញ៉េប វ័យ៧៦ឆ្នាំ ជាជនរងគ្រោះមួយរូបក្នុងរបបខ្មែរក្រហម បច្ចុប្បន្នរស់នៅខេត្តកំពត ។ ញ៉េប បានរស់នៅភូមិកំណើតរបស់គាត់តាំងពីរបប លន់ នល់ និងសម័យខ្មែរក្រហម ដោយមិនត្រូវបានជម្លៀសទៅណាដែរ ។*

*ដោយលាបាតដៃបន្លាញ ញ៉េប បានបន្តថា កាលពីរបបខ្មែរក្រហមគាត់ទទួលបានរបបអាហារក្នុងមួយពេលបានត្រឹមតែមួយក្តាប់ដៃតែប៉ុណ្ណោះ ។ គាត់បានអះអាងបន្តទៀតថា បើប្រៀបធៀបទៅនឹងការរស់នៅក្នុងរបបផ្សេងៗ ការរស់នៅក្នុងរបបខ្មែរក្រហមមានការលំបាកវេទនាជាងគេ ព្រោះការផ្តល់ជាអាហារនោះមិនគ្រប់គ្រាន់ឡើយចំពោះកម្លាំងពលកម្មដែលរូបគាត់ត្រូវធ្វើការក្នុងមួយថ្ងៃៗ ។*

*សំណាងល្អ រូបគាត់អាចរស់រានមានជីវិតក្នុងចំណោមទាហាន លន់ នល់ ជាច្រើនទៀតដែលត្រូវបានអង្គការយកទៅសម្លាប់ចោល ។ ញ៉េប បញ្ជាក់ថា «មកដល់ត្រឹមឆ្នាំ១៩៧៧ អង្គការដឹងថាខ្ញុំជាអតីតទាហានកាលពីសម័យ លន់ នល់ ទើបដកមុខដំណែងខ្ញុំ តែសំណាងហើយដែលអង្គការអត់សម្លាប់ខ្ញុំ កាលនោះឲ្យតែជាទាហានលន់នល់អង្គការយកទៅសម្លាប់ចោលទាំងអស់» ។ រីឯបងប្អូនជីដូនមួយ ជីទួតមួយ និងក្មួយៗរបស់គាត់ប្រមាណដប់នាក់ត្រូវបានអង្គការយកទៅសម្លាប់ចោលទាំងអស់ ។*

*ក្រោយមក ញ៉េប ត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការផ្នែកសេដ្ឋកិច្ច (ខាងដឹកជញ្ជូនឥវ៉ាន់ ឬអាហារពីកន្លែងមួយទៅកន្លែងមួយទៀត) ។ ចំណែកការងាររបស់ប្រជាជននៅក្នុងភូមិនេះនៅពេលនោះរួមមាន រែកដី ទប់ទំនប់ ដកស្ទូង និងដាំដំណាំជាដើម ។ ប្រជាជនភាគច្រើនក្នុងសម័យនោះមិនបានដឹងថាថ្នាក់ដឹកនាំជានរណាទេគឺស្គាល់ត្រឹមតែឈ្មោះថា «ម៉ុក» តែប៉ុណ្ណោះ ដែលគាត់មាននាទីជាអ្នកប្រមែប្រមូលយកទិន្នផលដំណាំទាំងអស់របស់ប្រជាជន ប៉ុន្តែបែរជាមិនឲ្យប្រជាជនបានហូបគ្រប់គ្រាប់ទៅវិញ ។ ញ៉េប អះអាងថា «ឃើញតែគេដឹកពេញៗឡានមានទាំងស្រូវ និងបន្លែ ផ្លែឈើផ្សេងៗផង តែមិនដឹងគេដឹកយកទៅណាទេ» ។*

*គាត់បានត្អូញត្អែរចំពោះរបបអាហារដែលខ្វះជីវជាតិក្នុងសម័យនោះ ពោលគឺបរិមាណអាហារមានតិច ពេលខ្លះមានតែបបររាវៗ ឬដំឡូងមីប៉ុណ្ណោះ ។ ទោះបីស្ថិតក្នុងសភាពអត់ឃ្លានខ្វះខាតយ៉ាងណាក្តី ក៏ប្រជាជននៅក្នុងភូមិពុំហ៊ានស្វែងរកអាហារមកបំពេញបន្ថែមក្រពះខ្លួនដែរ ។ ការលួចជាបម្រាមដាច់ខាតរបស់អង្គការ ហើយទណ្ឌកម្មចេញពីការលួចនឹងអាចឈានដល់ការយកទៅសម្លាប់ចោល ។ ញ៉េប បានបន្ថែមថា «របបអាហារដែលអង្គការផ្តល់ឲ្យប៉ុណ្ណា គឺត្រូវញ៉ាំតែប៉ុណ្ណោះ» ។*

*ញ៉េប និយាយទៀតថា គាត់ហូបដំឡូងមីបណ្តើរ ស្រក់ទឹកភ្នែកបណ្តើរដោយសារតែការទទួលទានអាហារប្រភេទនេះពុំអាចជួយទ្រទ្រង់សុខភាពរបស់គាត់បានទេនៅពេលនោះបាន ។ ជាលទ្ធផល មានប្រជាជននៅក្នុងភូមិរបស់គាត់ជាច្រើននាក់បានធ្លាក់ខ្លួនឈឺ និងបាត់បង់ជីវិតជាបន្តបន្ទាប់ ។ ជំងឺឆ្លងផ្សេងៗកើតឡើងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ប៉ុន្តែពុំឃើញអង្គការខ្មែរក្រហមយកចិត្តទុកដាក់ផ្នែកសុខភាពនោះឡើយ ។ ទោះបីជាឈឺជំងឺអ្វី ក៏ពេទ្យព្យាបាលនៅសម័យនោះអាចផ្តល់បានត្រឹមតែការចាក់ទឹកដូងទៅក្នុងខ្លួនអ្នកជំងឺ ឬឲ្យថ្នាំគ្រាប់ខ្មៅៗ (ដែលមិនបានដឹងថាជាថ្នាំអ្វីនោះ) ដើម្បីផឹក ។*

*ការលំបាកវេទនាដែលគ្មានអ្វីអាចប្រៀបធៀប និងការឆ្លងកាត់ភាពភ័យខ្លាច ហាក់ដូចជានៅក្នុងភាពស្រពេចស្រពិលសម្រាប់ ញ៉េប ដែលមិនគិតថាខ្លួនគាត់អាចនៅមានជីវិតរហូតដល់ពេលនេះទេ ។*

*បច្ចុប្បន្ន ញ៉េប ធ្វើស្រែចម្ការ និងរស់នៅជួបជុំប្រពន្ធព្រមទាំងកូនបីនាក់ដែលនៅសេសសល់ពីរបបខ្មែរក្រហម ។*

**ហ៊ាន សុជាតា**

# ក្រោយរបបខ្មែរក្រហម បួសជាសង្ឃដើម្បីរៀន

អ៊ួន សំអឿ មានអាយុ៤៩ឆ្នាំ បច្ចុប្បន្នរស់នៅស្រុកពាមរក៍ ខេត្តព្រៃវែង ។ គាត់បានរៀបរាប់អំពីប្រវត្តិគាត់ឆ្លងកាត់របបខ្មែរក្រហមថា កាលសម័យនោះ គាត់នៅកងកុមារ ដូច្នេះហើយទើបបានដឹងរឿងរ៉ាវបានតិចតួចប៉ុណ្ណោះ ។

សំអឿ បាននិយាយប្រាប់ខ្ញុំថា កាលសម័យនោះគាត់រស់នៅភូមិព្រៃភ្វា ឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ កាលពីគាត់នៅក្មេង ឪពុកម្តាយរបស់គាត់តែងតែប្រើឲ្យគាត់ទៅឃ្វាលគោជារៀងរាល់ថ្ងៃ ពេលរដូវប្រាំងចូលមកដល់ ។ កាលនោះគាត់មិនសូវដឹងអំពីសភាពការណ៍ក្នុងប្រទេសច្បាស់លាស់ទេ គាត់បានចេញទៅឃ្វាលគោដូចសព្វដង ។ ប៉ុន្តែ នៅថ្ងៃមួយនោះគាត់មានការតក់ស្លុតយ៉ាងខ្លាំងព្រោះតែមានការទម្លាក់គ្រាប់បែកពីសំណាក់កងទ័ពអាមេរិកកាំងនៅជិតភូមិរបស់គាត់ គឺភូមិព្រៃភ្វា ។ គាត់បានបន្ថែមទៀតថា បន្ទាប់ពីនោះមកអ្នកភូមិមានភាពភ័យខ្លាចយ៉ាងខ្លាំង និងត្រៀមខ្លួនជាប់ជានិច្ច ។



អ៊ួន សំអឿ ពេលបួសជាព្រះសង្ឃ ថតនៅក្នុងឆ្នាំ១៩៨៣

ទោះជាមានការទម្លាក់គ្រាប់បែកយ៉ាងណាក៏ដោយ ក៏គាត់មិនបានរត់ចេញពីទីកន្លែងដែលគាត់ធ្លាប់បានរស់នៅដែរ ព្រោះហេតុការណ៍នោះស្ងប់ស្ងាត់ទៅវិញជាធម្មតា ។ កន្លងមកបានមួយរយៈ នៅឆ្នាំ១៩៧៥ ក៏ស្រាប់តែមានកម្មាភិបាលខ្មែរក្រហមមកប្រាប់ឲ្យប្រជាជននៅទីនោះប្រុងប្រៀបរៀបចំរបស់របរប្រើប្រាស់ដែលមានក្នុងផ្ទះទាំងប៉ុន្មានយកមកដាក់ជារបស់រួម ចំណែកមាសប្រាក់លុយកាក់ត្រូវប្រគល់ជូនអង្គការទាំងអស់ ។

ពេលនោះគាត់មិនដឹងថាខ្មែរក្រហមមានវិធានការអ្វីទេ ព្រោះគាត់នៅក្មេង ដូចនេះហើយគាត់មិនសូវដឹងអំពីគោលការណ៍អ្វីទេ ។ គាត់គ្រាន់តែឮពាក្យថា សហករណ៍គឺជាអ្នកដែលត្រួតត្រាលើប្រជាជននៅសម័យនោះតែប៉ុណ្ណោះ ។ គាត់ក៏បាននិយាយទៀតថា ក្នុងមួយគ្រួសារអង្គការចែកគោឲ្យពីរក្បាលដើម្បីទុកយកទៅភ្ជួរស្រែ ។ នៅតំបន់នោះ គាត់មិនសូវមានការលំបាកប៉ុន្មានទេ ព្រោះគាត់ជាប្រជាជនចាស់ ដោយឡែកមានតែប្រជាជនថ្មីទេដែលមានការលំបាក ។ ប្រជាជនថ្មីគឺជាប្រជាជនដែលអង្គការជម្លៀសមកពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ដូច្នេះអង្គការគិតថា ប្រជាជនទាំងនោះជាប្រជាជនដែលពិបាកគ្រប់គ្រង ។

អង្គការបានសួរចម្លើយដោយប្រើទារុណកម្ម ឬសម្លាប់វាយចោលចំពោះនរណាដែលត្រូវបានរកឃើញថាធ្លាប់ជាមន្ត្រីរាជការ អ្នកធ្វើការ ព្រមទាំងអ្នកមានចំណេះដឹង ។ ចំណែកជនជាតិវៀតណាមគឺត្រូវសម្លាប់ចោលតែម្តង ។ ប្រជាជនថ្មីទាំងនោះ មានការងារធ្វើដូចជាប្រជាជនចាស់ដែរ គឺការជីកប្រឡាយ និងធ្វើស្រែ ។ ចំពោះគាត់ផ្ទាល់ គាត់

នៅក្នុងវ័យកុមារ ដោយពេលនោះសហករណ៍បានឲ្យគាត់ដើរឃ្វាលគោ ។ ប៉ុន្តែមានពេលខ្លះ គាត់ត្រូវបានចាត់តាំងឲ្យទៅលើកភ្លឺស្រែ ហើយនៅពេលយប់គាត់មិនបាននៅផ្ទះទេ គឺគាត់ស្នាក់នៅកងកុមាររហូតដល់ពេលព្រឹកឡើងទើបត្រឡប់មកផ្ទះវិញ ។ កាលនោះ ឪពុករបស់គាត់ធ្វើការក្នុងរោងបាយ ហើយម្តាយធ្វើស្រែដូចអ្នកភូមិដែរ ។

គាត់បន្តថា ចំពោះការហូបចុក គឺរាល់ពេលត្រូវគោះជួងគាត់ត្រូវតែសំដៅទៅកាន់រោងបាយដើម្បីទទួលបបរហូប លើកលែងតែនៅខែប្រាំងអង្គការឲ្យហូបបាយ ។ គាត់ទទួលបានរបបបបរពីរកាប៉ុណ្ណោះក្នុងមួយពេល ។ គាត់មិនសូវរវីរវល់ពីរឿងអីទេ គាត់គ្រាន់តែធ្វើតាមអ្វីដែលអង្គការដាក់មកឲ្យគាត់ធ្វើប៉ុណ្ណោះ ។

ក្រោយមក គាត់បានដឹងថា ប្រហែលជាកំឡុងឆ្នាំ១៩៧៨ អង្គការមានវិធានការជម្លៀសប្រជាជនថ្មីទាំងនោះទៅកាន់តំបន់ផ្សេង គឺខេត្តបាត់ដំបង ឬក៏ពោធិ៍សាត់ ដោយដំបូងអង្គការបានដឹកប្រជាជនទាំងនោះតាមកាណូតតាមបណ្តោយទន្លេមេគង្គឆ្ពោះទៅកាន់ទីក្រុងភ្នំពេញសិន ។ ប៉ុន្តែក្រោយការជម្លៀសអ្នកថ្មីទាំងនោះមិនបានប៉ុន្មានខែផង ស្រាប់តែមានកងទ័ពវៀតណាមបានចូលមករំដោះប្រទេសកម្ពុជា ។ គាត់បន្តថា ពេលនោះកងទ័ពរំដោះបានជួយការពារ ហើយគាត់ក៏រត់ទៅតាមកងទ័ពទាំងនោះដែរ ។

បន្ទាប់ពីរបប ប៉ុល ពត ដួលរលំ គាត់សប្បាយចិត្តយ៉ាងខ្លាំង ហើយអ្នកស្រុករបស់គាត់ ក៏រីករាយដូចជាគាត់ដែរ ។ ប៉ុន្តែ ពេលដែលសង្គ្រាមចប់ភ្លាម គ្រួសារគាត់ជួបប្រទះការលំបាក យ៉ាងខ្លាំង ព្រោះមិនមានសេសសល់ទ្រព្យសម្បត្តិអ្វីទេ ។ ទ្រព្យសម្បត្តិទាំងប៉ុន្មានត្រូវអង្គការប្រមូលយកអស់ ។ គ្រួសារគាត់បានចាប់ផ្តើមពីបាតដៃទទេឡើងវិញ ។ ចំណែកគាត់នៅពេលនោះ គាត់ជួយឃ្វាលគោ ព្រោះគាត់ជាកូនច្បងក្នុងគ្រួសារ ។ តែទោះបីជាយ៉ាងនេះក្តី ក្រោយមកគាត់បានចូលរៀននៅផ្ទះមួយខ្នង ដែលលោកគ្រូឈ្មោះ តាយ៉ាន ជាអ្នកបង្រៀន ។ សំអឿ និយាយថា លោកគ្រូរបស់គាត់កាចណាស់ គាត់តែងតែវាយសិស្សណាដែលរៀនមិនចេះ ។ នៅខណៈនោះ ដោយសារតែគ្រួសារមានជីវភាពខ្វះខាតផងឪពុករបស់គាត់ក៏បានសម្រេចចិត្តយកគាត់ទៅបួសធ្វើជាព្រះសង្ឃនៅឆ្នាំ១៩៨១នៅវត្តសិរីសារពេជ្រ ស្ថិតក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង រហូតដល់ឆ្នាំ១៩៩៣ ទើបគាត់សឹកមកជាប្រជាជនធម្មតាវិញ ។ រហូតមកដល់បច្ចុប្បន្ន គាត់មិនដែលភ្លេចពីអតីតកាលដែលបានឆ្លងកាត់ដែរ ។ **អឿង ណារី**

# ដំណឹងស្វែងរកគ្រួសារ



ខ្ញុំបាទឈ្មោះ ញ៉ាន ស៊ី ធ្វើការនៅក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ សូមប្រកាសរកឈ្មោះ អៀវ អៀង ភេទប្រុស អាយុ៨២ឆ្នាំ កើតឆ្នាំ១៩៣៣ នៅភូមិត្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ មុនឆ្នាំ១៩៧៥ អៀង ជានាវិក បម្រើការងារនៅកប៉ាល់ក្រុមហ៊ុនមួយនៅប្រទេសសិង្ហបុរី ។ ក្រោយមក អៀង បានមករស់នៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ។ អៀង បាត់ខ្លួនក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅស្រុកកំពង់ត្រាច ខេត្តកំពត ។ តាមដំណឹងពីប្រជាជនថា អៀង បានត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ព្រោះបានប្រទះឃើញគាត់នៅតាមផ្លូវក្នុងស្រុកកំពង់ត្រាចខេត្តកំពត ។ ក្រោយឆ្នាំ១៩៧៩ ប្រពន្ធ និងកូន អៀង បានទៅរស់នៅប្រទេសអាល្លឺម៉ង់រហូតមកដល់សព្វថ្ងៃនេះ ។ ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះ អៀង សូមទាក់ទងមកខ្ញុំបាទតាមរយៈអាសយដ្ឋានលេខ៨៧/៦G មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៤៦ អ៊ីម៉ែល: nhansy04@yahoo.com ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ។

***សូមអរគុណ!***

# សៀវភៅរំឮកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ *truthkokthay@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។




**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក USAID
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 165, September 2013 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.